ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 02-Apr-2012, 10:41
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២**

**ម៉ោង ០៩:០១ នាទី**

**សវនាការលើកទី៤៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវណ្ណី

លោក រ៉ូជើ ហ្វីលីព *(Mr.Roger PHILLIP)*

លោក ដាវ អានសាន

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

លោក ប៉ាក ច័ន្ទលីណូ

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ *(Mr Jasper PAUW)*

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកកែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ពេជ អង្គ

លោក គឹម ម៉េងឃី

លោកស្រី ជេត វណ្ណលី

កញ្ញា លី ម៉ាញៀន *(Ms.Lyma NGUYEN)*

លោក បាណាបេ ណេគ្វី

*(Mr. Barnabé NEKUIE)*

លោក ឡោ ជុនធី

លោក វ៉ែន ពៅ

លោក ហុង គឹមសួន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| កញ្ញា លី ម៉ាញឿន | អង់គ្លេស |
| លោក កាំង ហ្កេកអ៊ាវ | ខ្មែរ |
| លោក អាកទួរ វែកគែន | បារាំង |
| លោក គង់ សំអុន | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី: លោក កាំង ហ្កេកអ៊ាវ ហៅ ឌុច**

សួរបន្តដោយលោក វីល្លៀម ស្មីត ផ្តើមពី៖..................................................................ទំព័រ ០១

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:៥៨]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ។ នៅថ្ងៃនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលនឹងបន្តការតាំងសំណួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា។ អង្គជំនុំជម្រះសូមផ្តល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីអាចបន្តការសួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញ!

**លោក វ៉ែណ្ឌៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម មេធាវីការពារ ហើយនិងសាក្សី ព្រមទាំងសាធារណជនផងដែរ។

លោក កាំង ហ្គេកអ៊ាវ ពីម្សិលមិញនេះ ដើម្បីយើងចាប់ផ្តើមថ្ងៃនេះ ឥឡូវនេះ យើងនឹងសួរលោកតទៅទៀត គឺថាជាច្រើនថ្ងៃមកហើយ បើសិនជាលោកនឿយហត់នៅពេលល្ងាចនេះ សូមលោកជម្រាបតុលាការផង បើសិនជានឿយហត់មែន។ ក្នុងករណីថា នឿយហត់ពេលល្ងាចនោះ គឺថានៅក្នុងសប្តាហ៍នេះ ឬក៏លោកនៅតែមានសុខភាពល្អមិនអស់កម្លាំង ក៏អាចនឹងជម្រាបផងដែរ បាទ។

**លោក កាំង ហ្គេកអ៊ាវ៖**

មិនអីទេ ខ្ញុំបន្តបាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក វ៉ែណ្ឌៀម ស្មីត៖**

**ស៖** សូមអរគុណ។ កាលពីម្សិលមិញ យើងបានពិភាក្សាអំពីការប្រជុំដែលលោកបានជួបជាមួយ សុន សេន ហើយនិងកងពលផ្សេងទៀត ជាកន្លែងដែលលោកបានពិភាក្សាអំពីស្ថានការណ៍ទាក់ទង

ទៅនឹងខ្មាំង ហើយនិងការស្វែងរកខ្មាំង។ ជាពិសេស ទាក់ទងទៅនឹងបុគ្គលណាមួយចំនួន ដែលបោះខិត្តប័ណ្ណនៅក្នុងភ្នំពេញ ហើយគេបានប្រជុំដើម្បីពិភាក្សាអំពី ថាតើយើងកំណត់មុខសញ្ញាអ្នកដែលចែកខិត្តប័ណ្ណហ្នឹង អ្នកណាខ្លះ? តើលោកនៅចាំការប្រជុំដែលស្ដីអំពីរឿងនេះដែរឬទេ?

[០៩:០៥:០៨]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ ខ្ញុំនៅចាំ។

**ស៖** ហើយលោកក៏បានបញ្ជាក់ផងដែរថា លោកក៏មានការប្រជុំស្រដៀងគ្នានេះជាមួយនេះ ជាមួយនឹងកងពលផ្សេងៗទៀត។ ឥឡូវនេះខ្ញុំចង់ឱ្យលោកពិនិត្យមើលឯកសារមួយ គឺ D248/6.1.5។ ហើយខ្ញុំពិនិត្យទៅឃើញថា មានការប្រជុំមួយផ្សេងទៀតដែលនៅក្នុងការប្រជុំនោះលោកបានចូលរួមដែរ ហើយក៏បានពិភាក្សាស្រដៀងនឹងមុននោះដែរ។

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតជូនឯកសារលើក្រដាសទៅសាក្សី ហើយនិងសូមបង្ហាញនៅលើអេក្រង់ផងដែរ បាទ។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត សូមអញ្ជើញ!

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** សាក្សីសូមលោកអាន មើលឯកសារ ហើយគឺកំណត់ហេតុនៃអង្គប្រជុំ គឺកងពល១៧០ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៧៦ ហើយនៅខាងក្រោមនិយាយថា សមមិត្ត ឌុច បានផ្ដល់មតិ។ តើលោកបានឃើញឯកសារនេះទេ កាលពីមុននោះ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ឯកសារនេះដែលបង្ហាញឱ្យខ្ញុំពន្យល់ នៅពេលលើកនេះជាលើកទីបីហើយ។ លើកទីមួយ នៅការិយាល័យសហចៅក្រមស៊ើបអង្កេត។ លើកទីពីរ នៅអង្គជំនុំជម្រះ-- សវនាការនេះយើងនេះតែម្ដង ហើយនេះជាលើកទីបី។

[០៩:០៧:៣៩]

**ស៖** តើលោកអាចពន្យល់ដោយសង្ខេប ថាតើកិច្ចប្រជុំនោះពិភាក្សាពីអ្វី? ហើយក្រោយពីប្រជុំ

ចប់ មានចាត់វិធានការដូចម្ដេចដែរ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា ការប្រជុំនុំងគេពិភាក្សាគ្នាអំពីមនុស្សណាខ្លះនៅក្នុងកងពល១៧០ ដែលជាខ្សែរបស់ ចាន់ ចក្រី។ ដល់ចុងបញ្ចប់ គេជ្រើសរើស-- ខ្ញុំសូមនិយាយពីរឿងមេវិញ ដំបូងនៅជុំគ្នាបង៨៩ គឺ សុន សេន នេះមួយ ហើយនិងបង៨១ គឺ ស៊ាត ឆែ ហៅទុំ នេះពីរ នៅជុំគ្នា មេទាំងពីរនៅជុំគ្នា។ ដល់ប្រជុំមួយសន្ទុះទៅ បង៨៩ គាត់ត្រូវចេញក្រោយពី មិត្តសុខ មានយោបល់ហើយ ថាខ្សែនេះៗ ចេញទៅ។ ដល់ បង៨៩ គាត់ចេញទៅ នៅសល់បង៨១ គាត់ចេញ-- អំ! គាត់ដឹកនាំការប្រជុំ។ ដល់សល់ បង៨១ គាត់នៅដឹកនាំការប្រជុំ ពេលហ្នឹងហើយដែលវាមានរឿងមួយដែលមិត្ត សោម ទាមទារឲ្យខ្ញុំសុំយោបល់ខ្ញុំ ឲ្យខ្ញុំនិយាយ។ ហើយខ្ញុំ ដល់ទៅ បង៨១ គាត់កាត់ មតិទាំងអស់ដែលចារហ្នឹង គឺជាមតិរបស់ បង៨១ ទេ មិនមែនមតិខ្ញុំទេ។ ដល់ចុងបញ្ចប់គេសរុបគ្នា រៀបចំវិធានការដើម្បីយកមនុស្សពីកង១៧០។ យកយ៉ាងម៉េច បើគ្នាច្រើនយ៉ាងនេះ? ដូច្នេះគេសម្រេចយកតាមវិធីឲ្យខាងនោះចាប់ ហើយខាងណេះចាំតែទៅទទួល កុំឲ្យផ្អើល។ នេះរឿងប៉ុននុំង។

[០៩:០៩:៥៧]

**ស៖** សូមអរគុណ។ នៅក្នុងខាងក្រោយនៃឯកសារនោះបាននិយាយថាកងពល១៧០ កងពលស-២១ ត្រូវតែពិភាក្សាផែនការជាក់ស្ដែង ដើម្បីយកអ្នកទាំងអស់នេះ។ ថាតើបុគ្គលទាំងអស់នោះគឺត្រូវបាន ចុងបញ្ចប់ហ្នឹងត្រូវបានគេចាប់ ហើយបញ្ជូនមកស-២១ ដែរឬទេ?

**ឆ៖** អរគុណ។ ចុងបញ្ចប់ខាងកងពល១៧០ គេចាប់ ហើយខាងណេះចាំតែទៅទទួលពីគេទេ យើងទៅដល់កន្លែងហ្នឹងចាំតែទៅយកមក មនុស្សដែលគេចាប់ហើយ។

**ស៖** ហើយអ្នកទាំងនោះត្រូវបានចាប់ខ្លួនដោយកងពល ប៉ុន្តែពួកយោធាជាអ្នកចាប់ពួកគេ តើត្រូវទេ?

**ឆ៖** ត្រឹមត្រូវហើយ គឺកងពល១៧០ គ្នាគេ គេចាប់គ្នាគេ។

[០៩:១១:២២]

**ស៖** ការប្រជុំនេះគឺធ្វើឡើងនៅថ្ងៃទី១៦ កញ្ញា ឆ្នាំ១៩៧៦ ហើយនៅចុងនៃបញ្ជីឈ្មោះនោះគឺអ្នកណាដែលគេសង្ស័យថា ជាខ្មាំងនៅចំណុចមួយ គឺថាមានមនុស្ស២៩នាក់ នៅនោះ។ ផ្ដែកទៅលើ ស-២១ ហើយកងពលនឹងបញ្ជាក់ ហើយសកម្មភាពដែលគេបានឃើញម្ដងហើយ ម្ដងទៀតនោះ ហើយ ផ្អែកទៅតាមផែនការដែលអង្គការបានបញ្ជូនចេញនោះ។ ចក្រី-- អ្នកខ្សែចក្រីទាំងអស់ត្រូវតែបានចាប់

ខ្លួនទាំងអស់។ សំណួរខ្ញុំចំពោះលោកគឺថា តើៗផែនការនេះត្រូវបានបញ្ជូនទៅដល់លោកហ្នឹងដោយវិធីណា? អនុលោមទៅតាមអង្គការដែលបញ្ជូន តើលោកបានទទួលផែនការនោះដែរឬទេ?

**ឆ៖** ដំបូង ខ្ញុំសូមបញ្ជាក់ថា ចក្រី គេចាប់ហើយ។ ចម្លើយអ្នកផ្សេងទៀតប៉ះពាល់មនុស្សមួយចំនួន។ ដល់ទៅពេលនុ៎ង ដូចមេសួរ មិត្តសុខៗ លេខាថ្មីរបស់កងពល១៧០។ ដល់ទៅ មិត្តសុខ ថា ឈ្មោះនេះខ្សែគេ ទេមិនមែនខ្សែ ចក្រី ទេ ឈ្មោះនេះបានខ្សែ ចក្រី។ ដូច្នេះបើកាលណា មិត្តសុខ គេប្រកែកថាខ្សែរបស់អ្នកផ្សេងទៀត មេឲ្យទុកតែ មិត្តសុខ ត្រូវទទួលខុសត្រូវ។ ដូច្នេះ ឈ្មោះប៉ុន្មានហ្នឹងដូចជាចាប់២៩ហ្នឹង តែបញ្ជីដែលស-២១ ប្រគល់ទៅឲ្យសេនាធិការ ទើបទៅឲ្យអង្គការអាចច្រើនជាងនេះ។ ដូច្នេះឈ្មោះនេះ គេជម្រើសរួចមកហើយ។ ក្នុងអង្គប្រជុំហ្នឹង ដែលសម្រេចជម្រើសឈ្មោះប៉ុណ្ណឹង។

**ស៖** ដូច្នេះនៅក្នុងឯកសារនៅពេលដែលនិយាយ គឺថាតាមផែនការដែលអង្គការបានបញ្ជូនចេញនោះ តើផែនការនៅទីនេះមានន័យដូចម្តេច?

[០៩:១៤:១៥]

**ឆ៖** ទេ ផែនការនេះប្រហែលជាបកប្រែខុសហើយ។ ដូច្នេះ ខ្ញុំសូមអាន ហើយបកប្រែជូនលោកព្រះរាជអាជ្ញា ដែលស្រួលទៅ។ "ឈរលើហេតុផលបញ្ជាក់របស់ស-២១ និងកងពល ឃើញថាសកម្មភាពជាក់ស្តែងជាបន្តបន្ទាប់ ព្រមទាំងឈរលើគោលការណ៍អង្គការកំណត់។ ពួកខ្សែស្រឡាយអា ចក្រីត្រូវយក អង្គប្រជុំយល់ស្របសម្រេចយកឈ្មោះទាំង ២៩នាក់នេះទៀត"។ ដូច្នេះ គ្មានពាក្យផែនការទេ មានពាក្យគោលការណ៍ ដែលបារាំងហៅថា *ប្រាំងស៊ីត*។ ដូច្នេះ គោលការណ៍ដែលអង្គការកំណត់ទីមួយមានចម្លើយចេញពីស-២១។ ទីពីរ អង្គភាពរបស់គេទទួលស្គាល់ថាវាមានសកម្មភាពជាក់ស្តែង។ ព្រោះ មិត្តសុខ គាត់ប្រកែកចំពោះមនុស្សខ្លះមួយចំនួន។ ហើយដល់ក្រោយមកបានៗសម្រេចចាប់យកមនុស្ស២៩នាក់នេះ។ ដូច្នេះបញ្ជីដែលស-២១ ឲ្យទៅហ្នឹងមានដកឈ្មោះខ្លះចេញបាត់ហើយ។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំបានបញ្ចប់ជាមួយឯកសារនេះហើយ។ ឥឡូវនេះ ខ្ញុំសូមសួរលោកសំណួរមួយចំនួនទាក់ទងទៅនឹងឯកសារដែលលោកបានឃើញម្សិលមិញ គឺជាឯកសារ D248/3/3.3។ តើលោកនៅចាំចំណងជើងឯកសារនោះទេ? គឺថាការណែនាំរបស់គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជានិយាយអំពីគោលនយោបាយ អំពីអ្នកភ័ន្តច្រឡំចូលរួម សេ.អ៊ី.អា ហើយនិង កា.ហ្សេ.បេ ហើយនិងបានប្រឆាំងបក្ស បដិវត្តន៍ប្រជាជន និងកម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី២០ មិថុនា ឆ្នាំ១៩៧៨

ឯកសារហ្នឹងចុះកាលបរិច្ឆេទអ៊ីចឹង។ សក្ខីកម្មម្សិលមិញនោះលោកនិយាយថា លោកបានឃើញឯកសារ ហើយក៏លោកបានឃើញអ្វីដែលលោកយល់ថាជាឯកសារកត់ត្រានៅក្នុងទង់បដិវត្តផងដែរ។ តើអ៊ីចឹងត្រូវឬទេ?

[០៩:១៦:៤៥]

**ឆ៖** អរគុណ។ ត្រឹមត្រូវ ខ្ញុំផ្តល់សក្ខីកម្មម្សិលមិញ ខ្ញុំអត់កែប្រែទេ។

**ស៖** ខ្ញុំគិតថាសក្ខីកម្មរបស់លោកពីម្សិលមិញហ្នឹង គឺស្របទៅនឹងគំនិតមួយទោះបីជាគោលនយោបាយទំនងជាមានភាពទន់ស្រាលក៏ដោយ ប៉ុន្តែជាវិធីសាស្ត្រគឺដើម្បីការចាប់ខ្មាំង។ ប៉ុន្តែលោកយល់ថាវាមិនមែនជានយោបាយពិតប្រាដកយកមកអនុវត្ត វាមិនមែនជាការសម្រាលចំពោះខ្មាំងនោះទេ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** អរគុណ។ គំនិតដែលខ្ញុំរាយការណ៍ជូនអង្គប្រជុំម្សិលមិញ លោកព្រះរាជអាជ្ញាយកមកសរុប ត្រឹមត្រូវតាមគំនិតរបស់ខ្ញុំហើយ។

**ស៖** ក្រោយពីឯកសារហ្នឹងត្រូវបានចេញនៅថ្ងៃទី២០ មិថុនា ឆ្នាំ១៩៧៨ តើលោកមានការពិភាក្សាជាមួយមេដឹកនាំជាន់ខ្ពស់ណាទេអំពីថា តើឯកសារនោះមានអត្ថន័យដូចម្តេចនោះ?

[០៩:១៨:១៦]

**ឆ៖** អរគុណ។ ខ្ញុំអត់មានយកឯកសារនេះទៅពិភាក្សាឯណាទៀតទេ។

**ស៖** នៅពេលដែលឯកសារហ្នឹងចេញមក ឬក៏លោកបានទទួលឯកសារ តើលោក-- សូមចាំថាលោកបានការទទួលខុសត្រូវក្នុងការអនុវត្តនយោបាយសម្លាប់ខ្មាំង តើលោកយល់ដូចម្តេចនៅពេលដែលនយោបាយនោះត្រូវបានចេញមក? ហើយដែលលោកឃើញបានជាក់ស្តែងនៅក្នុងឯកសារនោះ លោកអានទៅឃើញថាជាការសម្រាលដល់ខ្មាំង ប៉ុន្តែតើលោកយល់ដូចម្តេចកាលណោះ?

**ឆ៖** អរគុណ។ ដំបូងខ្ញុំឃើញឯកសារនេះភ្លាម ខ្ញុំអរ។ យ៉ាងម៉េចបានជាអរ? ពីព្រោះក្នុងប្រជាជនជម្លៀស ខ្ញុំគិតទៅដល់នុ៎ងវិញទេ។ ប្រជាជនជម្លៀស ដែលគេហៅថា ប្រជាជន១៧ មេសាហ្នឹង គ្នាជាអនុប្រជាជនទេ មិនមានសិទ្ធិពេញលេញដូចគេទេ។ កូនចៅគ្នាមិនអាចចូលជនបង្គោលមិនអាចចូលសម្ព័ន្ធ មិនអាចចូលបក្សបានទេ។ បើសិនជាមានការអនុគ្រោះឲ្យគ្នាអាចទៅនុ៎ងបាន គ្នាចូលធ្វើកងទ័ពក៏បានដែរ។ ហ្នឹងវាចេះតែទៅមុខហើយ។ នេះខ្ញុំយកមកមួយឆាប ដំបូងអ៊ីចឹង។ ប៉ុន្តែដល់មើលទៅ ខ្ញុំថាឯកសារនេះដូចមិនជាមិនបង្រៀននៅក្នុងន័ៃ ស-២១ ទេព្រោះគ្មានសមាសភាពអស់

ហ្នឹងនៅក្នុងស-២១។ ដូច្នេះ ខ្ញុំក៏ទុកឯកសារហ្នឹងទៅ មិនបង្រៀនទេ។ ប៉ុន្តែដូចជានិយាយជាមួយពួកអ្នកសួរ ពីគោលការណ៍លើកលែងនេះ ខ្ញុំមិនច្បាស់ទេ។ ដូចជាហៅពួកអ្នកសួរមកប្រជុំអំពីគោលការណ៍លើកលែងនេះ។ នេះខ្ញុំសូមសរុបប៉ុណ្ណឹង។ ការយល់ដឹងរបស់ខ្ញុំពេលនុ៎ង ត្រឹមប៉ុណ្ណឹងទេ។ ហើយដល់ក្រោយមកបាន១ខ្ញុំគិតតទៅទៀត ក្នុងឆ្នាំនុ៎ងដែរថា ឯកសារនេះរបៀបដូចជាពីលើកមុនទូទាំងប្រទេស ទូទាំងសកលលោកនៅចាំហើយ។ ប្រហែលជាក្នុងខែកុម្ភៈ ១៩៧៥ គេឲ្យប្រកាសតាមវិទ្យុថាយើងឲ្យប្រាំពីរនាក់ដែលជនមហាក្បត់ជាតិប្រឈមនឹងតុលាការ។ ក្រៅពីនោះអត់មានទោសពៃរ៍ ដល់ចុងបញ្ចប់ គេលេងទាំងអស់។

ដូច្នេះអ៊ីចឹង នេះគេធ្វើនេះដើម្បីឲ្យប្រជាជនសម្រាល កុំភ្ញាក់ផ្អើល កុំភ័យព្រួយអី គេអត់ធ្វើអីទេអ្នកដែលខុសពីឆ្នាំនេះ១ហើយ ក៏គេអនុគ្រោះ។ អាហ្នឹង ខ្ញុំគិតឃើញរបៀបនុ៎ងទៅវិញទេ។ សូមបញ្ជាក់ថាទស្សនៈនេះ វាកើតមានតាំងពីសម័យនោះ ដូចខ្ញុំបាននិយាយអ៊ីចឹង ខ្ញុំលើកឡើងបង្ហាញអំពីថ្ងៃខែម្សិលមិញហ្នឹង ថាថ្ងៃ២០ ខែមិថុនា ឆ្នាំ១៩៧៨ បើលោកព្រះរាជអាជ្ញាបើកមើលពួកខ្សែបូព៌ាទាំងប៉ុន្មានដែលចាប់ គឺភាគច្រើន ច្រើនតែមុនថ្ងៃ២០ មិថុនាហ្នឹង។ នេះខ្ញុំសូមបញ្ចប់បញ្ហានេះប៉ុណ្ណេះ។

[០៩:២១:៥១]

**ស៖** រហូតទៅដល់ចុងបញ្ចប់នៃឆ្នាំ១៩៧៨ តើលោកបានចូលរួមវគ្គនយោបាយណាទេ ដែល ប៉ុល ពត ឬក៏អ្នកផ្សេងបានវត្តមាននៅក្នុងវគ្គសិក្សានយោបាយនោះដែរឬទេ?

**ឆ៖** ខែខ្ញុំមិនចាំទេ ក៏ប៉ុន្តែខ្ញុំជឿថាមុនថ្ងៃ៣០ កញ្ញា ១៩៧៨ ដែលជាថ្ងៃកំណើតបក្ស។ ប៉ុល ពត, នួន ជា ទៅនៅនុ៎ង។ ប៉ុល ពត គាត់ឧទ្ទេសនាមវគ្គសិក្សាថ្មីហ្នឹងឲ្យកម្មាភិបាលមធ្យម នួន ជា នៅអង្គុយពីខាងស្តាំគាត់។ ដូច្នេះ វគ្គសិក្សាឆ្នាំ១៩៧៨នេះ ខ្ញុំអត់បានរៀនជាមួយនឹង សុន សេន ទេ ខ្ញុំរៀនជាមួយ ប៉ុល ពត។

**ស៖** សូមអរគុណ។ វគ្គនយោបាយនោះ តើរយៈពេលប៉ុន្មាន រយៈពេលប៉ុន្មានថ្ងៃដែរ?

**ឆ៖** វគ្គនយោបាយហ្នឹង ដូចជាមិនយូរ ដូចត្រឹមប្រាំថ្ងៃអីប៉ុណ្ណឹងទេ ហើយជីវទស្សន៍ប្រវត្តិរូបយកមកធ្វើឯកន្លែងខ្លួនឯងណោះ ម្ចាស់ការអីយ៉ាងម៉េចទេ ភ្លេចហើយ។

**ស៖** នៅក្នុងវគ្គសិក្សានយោបាយនេះ ជាពិសេសនយោបាយជាក់លាក់នេះ តើគេបានពិភាក្សាទេបាទ?

**ឆ៖** សំណួរនេះអត់ទាន់ច្បាស់ទេ សូមលោកព្រះរាជអាជ្ញាបញ្ជាក់បញ្ហា។

**ស៖** នៅក្នុងវគ្គសិក្សានយោបាយនោះ ថាតើគោលនយោបាយដែលថាបន្ធូរបន្ថយទាក់ទងទៅនឹងខ្មាំងមួយចំនួន ដែលហៅថាសេចក្ដីណែនាំរបស់គណៈមជ្ឈិមនេះ ដែលយើងបង្ហាញអំមិញនេះ តើគេពិភាក្សាពីចំណុចហ្នឹងដែរឬទេ?

**ឆ៖** អរគុណ។ គេមិនយកបញ្ហានេះទៅពិភាក្សា ឯកសារនេះទៅលើកឡើងចំពោះមុខ ហើយពិភាក្សាទេ។ ក៏ប៉ុន្តែគេនិយាយពីសភាពការណ៍មួយចំនួន ដូចតទៅ៖

ទី១) ត្រូវកុំហៅប្រជាជន ១៧ មេសា ទៀត ព្រោះទាំងអស់នេះ មហាជ័យជម្នះ ១៧ មេសា ជារបស់យើង ជារបស់បក្សបដិវត្តន៍កម្ពុជា។ ដូច្នេះ ហៅធម្មតា អ្នកនេះ អ្នកនោះអីចឹង។ នេះជាលទ្ធភាពទីមួយ។

ហើយទីពីរ កុំស្អីក៏ខ្មែរស កុំស្អីក៏ចោរព្រៃ។ គ្នាខ្ជិលធ្វើការរត់ទៅដេកក្នុងព្រៃ ទៅហៅគ្នាចោរព្រៃហ្នឹងមិនត្រូវទេ។ ហើយហៅគ្នាយកមកឲ្យបាយហូបធ្វើការតទៅទៀតទៅ ជាមួយគ្នាតទៅទៀតទៅនេះជាអនុវត្តបែបនេះ។ ប៉ុល ពត បញ្ជាក់ទៀតពេលហ្នឹង ជាពេលមួយដែល ប៉ុល ពត បញ្ជាក់ថាប្រជាជនក្រុងភ្នំពេញយើងជម្លៀសយកទៅនៅក្នុងសហករណ៍ ទៅលត់ដំក្នុងសហករណ៍ តែពីរបីឆ្នាំក៏ទៅដូចគេដូចឯងទៅហើយ។ នេះជាគោលការណ៍មួយដែលនិយាយ។ ហើយដល់ពេលក្រោយមកគាត់និយាយទៀត គាត់ថាយើងលុបបំបាត់ពុទ្ធសាសនា បានជោគជ័យ ឡេ យន់ សួរខ្ញុំថាមិត្តធ្វើយ៉ាងម៉េចបានជាមិត្តធ្វើបានជ័យជម្នះ។ ឯចំណែកវៀតណាមក៏ពិបាកម្ល៉េះ។ ប៉ុល ពត គាត់និយាយប្រាប់ ឡេ យន់ គាត់និយាយក្នុងលក្ខណៈថា គាត់ប្រាប់ ឡេ យន់ ថាលុបបំបាត់ពុទ្ធសាសនានៅកម្ពុជា ជាចលនារបស់មហាជន។ លោកសង្ឃធ្វើទំនប់អីចឹងទៅ ដោយយូរទៅវាភ្ញាក់រំពួកខ្លួនឯង ចង់ទៅច្បាំងនៅខាងមុខវាមានកាំភ្លើង វាមានអីកាន់ វាមានកិត្តិយស ហ្នឹងគេ។

[០៩:២៦:១០]

ហើយស្រីៗជាពិសេសក្រមុំៗគេទៅបបួលលោកសង្ឃណាដែលគេចាប់អារម្មណ៍ឲ្យសឹក ដូច្នេះគាត់និយាយប្រាប់ ឡេ យន់ អីចឹង។ ដូច្នេះ រឿងដែលគេឧទ្ទេសនាមហ្នឹងអីចឹង។ ហើយក៏ប៉ុន្តែសូមបញ្ជាក់មួយម៉ាត់ទៅទៀត នៅពេលមួយហ្នឹង ប៉ុល ពត គាត់ណែនាំឲ្យខ្ញុំឧទ្ទេសនាម អ៎! នែ៎គាត់សួរខ្ញុំពីរឿងសភាពការណ៍ខ្លាំង ដល់ទៅខ្ញុំរាយការណ៍។

**ស៖** សូមអរគុណ។ បន្ទាប់ពីវគ្គសិក្សានយោបាយនេះ តើលោកធ្លាប់បានសន្ទនាអ្វីជាមួយលោកនួន ជា ទេ អំពីគោលនយោបាយមួយនេះ ដែលថាឃើញជាក់ស្ដែងសរសេរហ្នឹង ដូចជាសម្រាលចំពោះ

វណ្ណៈខ្លាំងមួយចំនួន? តើលោកបានពិភាក្សាជាមួយគាត់ទេ?

[០៩:២៧:០១]

**ធ៖** អរគុណ។ នៅពេលក្នុងវគ្គសិក្សានេះ ប៉ុល ពត ណែនាំមិនឲ្យទាំងស-២១ សួរចម្លើយខ្លាំងផង នេះជាចំហអ៊ីចឹង។ ប៉ុន្តែដល់ក្រោយមកប្រហែលជាបីថ្ងៃ បងនួន គឺ នួន ជា នេះគាត់ហៅខ្ញុំទៅធ្វើការ។ ដល់ទៅខ្ញុំនិយាយពីរឿងថា ខ្ញុំអត់បានសួរផង។ ដល់អត់បានសួរផង បងនួន គាត់ហៅខ្ញុំ អ្ហែ! មិត្តឌុច ឥឡូវគាត់ចេះមាត់សម្បើមណាស់ណ៎ា! មិនឲ្យ-- បើបក្សណែនាំមកមិនឲ្យ ឌុច ស-២១ សួរ។ រួច ស-២១ វាអត់សួរ ស្រាប់តែ បងនួន បងអនុលេខាគាត់ថា អ្ហែ! មិត្តឌុច ឥឡូវគេចេះមាត់សម្បើមណាស់ណ៎ា! ខ្ញុំក៏ដើមផ្តើមសួរតទៅទៀត នេះក្រោយៗពីវគ្គសិក្សាហ្នឹងបីថ្ងៃ វាមានបញ្ហាហ្នឹងមួយ។ ដូច្នេះស-២១ គឺចាប់ផ្តើមសួរតទៅទៀតទៅ។

[០៩:២៨:០២]

**ស៖** ហេតុអ្វីក៏បានលោកគិតថា គោលនយោបាយនោះវាមិនពិតប្រាកដដូចដែលសរសេរ?

**ធ៖** អរគុណ។ លោកសហព្រះរាជអាជ្ញា និយាយគោលនយោបាយដែល ប៉ុល ពត ឧទ្ទេសនាម ឬក៏គោលនយោបាយនៅក្នុងឯកសារនេះ?

**ស៖** បាទ និយាយអំពីគោលនយោបាយដែលកត់ត្រានៅលើឯកសារ។

**ធ៖** អរគុណ។ ក្នុងជីវិតនយោបាយយើងផ្ទុះបញ្ចាំងបច្ចុប្បន្នទៅអតីតកាល យករឿងអតីតកាលមកបំភ្លឺបច្ចុប្បន្ន។ ខ្ញុំគិតដល់អាមហាក្បត់ជាតិទាំងប្រាំពីរនាក់ដែល ប៉ុល ពត ឲ្យ ខៀវ សំផន ថ្លែងតាមវិទ្យុ ហើយដល់ចុងបញ្ចប់ក្រោយ ១៧ មេសា កម្ទេចគេអស់មួយគរគោក ហើយដល់ពេលនេះ ប៉ុល ពត ណែនាំឲ្យស-២១ កុំសួរចម្លើយ។ ស្រាប់តែ នួន ជា គាត់ថា អ្ហែ! មិត្តឌុច ឥឡូវចេះមាត់សម្បើមណាស់។ បញ្ហាអស់នេះដែលធ្វើឲ្យយល់ឃើញថា ឯកសារនេះ ដើម្បីលួងលោមប្រជាជនកុំឲ្យភិតភ័យកុំតក់ស្លុត ហើយកុំធ្វើការបះបោរអីប៉ុននុ៎ង។ ខ្ញុំយល់ឃើញអ៊ីចឹង។

**ស៖** តើលោកនួន ជា និយាយយ៉ាងដូចម្តេច នៅពេលដែលលោកពន្យល់ទៅគាត់ថា ៗលោកនឹងឈប់ធ្វើការសួរចម្លើយអ្នកទោសហើយនោះ?

**ធ៖** ខ្ញុំមិននិយាយថា នឹងឈប់ទេ។ ខ្ញុំជម្រាបគាត់ថា "ខ្ញុំអត់បានសួរផងបង"។ ខ្ញុំនិយាយខ្លីប៉ុននុ៎ង "ខ្ញុំអត់បានសួរផងបង"។ ខ្ញុំអត់មានអាងទៅវគ្គសិក្សាអីទេ ខ្ញុំគ្រាន់តែជម្រាបគាត់ប៉ុណ្ណឹង។ ខ្ញុំថា "ខ្ញុំអត់បានសួរផងបង"។ នេះខ្ញុំនិយាយប៉ុណ្ណឹងខ្លី។ ហើយបងគាត់ៗមានប្រសាសន៍ស្តីឲ្យខ្ញុំអ៊ីចឹង។

**សៈ** ថាតើគាត់ព្រមាន ឬក៏រំឭកលោកពីអ្វី ហើយគាត់និយាយអ្វីថែមទៀតទេ?

**ឆៈ** បង នួន ជា បងនួន គាត់មានប្រសាសន៍ខ្លីតែប៉ុននុ៎ង "អ្ហឺ! មិត្តឌុច ឥឡូវគេចេះមាគ៌ាសម្បើមណាស់ហ្ន៎!" គាត់មានប្រសាសន៍តែប៉ុណ្ណឹង។ ហើយខ្ញុំក៏ឈប់ទៅ។ ដល់ក្រោយមកចប់ការពិភាក្សាគ្នាទៅ ខ្ញុំលាគាត់ចេញមក។

**សៈ** ក្រោយពីការពិភាក្សានេះរួចមក ថាតើលោកមានបន្តសួរចម្លើយអ្នកទោសរហូតដល់ចុងបញ្ចប់នៃរបបនេះដែរឬទេ ជាមួយនឹងបុគ្គលិករបស់លោកនោះ?

[០៩:៣១:៣៦]

**ឆៈ** អរគុណ។ ច្បាស់លាស់ណាស់ហើយ គឺខ្ញុំបន្តការសួរដូចធម្មតា មកដល់ខ្ញុំដាក់ម៉ូតូភ្លាម ហៅពួកអ្នកសួរចម្លើយមកប្រជុំភ្លាម រួមទាំង មិត្តហ៊ី ផង។ ហើយដាក់ផែនការសួរតទៅទៀត។

**សៈ** តើមានអ្នកណាម្នាក់បញ្ជាឲ្យលោកបន្តសួរចម្លើយអ្នកទោសនេះដែរឬទេ?

**ឆៈ** គ្មានអ្នកណាម្នាក់ក្រៅពីនេះទេ គឺយើងខ្ញុំធ្វើការជាមួយនឹងបងទីពីរ គឺ បងនួន នេះ រួចហើយខ្ញុំមកបញ្ជា ស-២១ ក្នុងឋានៈខ្ញុំជាប្រធាន ត្រូវតែអនុវត្តផែនការដែលឯកភាពជាមួយនឹងបក្ស។

**សៈ** នៅពេលដែលនិយាយ លោកប្រើពាក្យថា "ផែនការ" គឺលោកសំដៅទៅលើអ្វី?

**ឆៈ** ផែនការហ្នឹងគឺ ខ្ញុំនិយាយហ្នឹង គឺសំដៅទៅលើការងារជាភារកិច្ចដែលធ្លាប់មានមកនៅ ស-២១ ដូច្នេះ ខ្ញុំប្រើពាក្យនេះវាមិនចំមែន ផែនការនេះ គឺភារកិច្ច បន្តភារកិច្ច។

**សៈ** ហើយនៅពេលដែលលោកចាកចេញពី ស-២១ ជាចុងក្រោយនោះ តើលោកមានបានទទួលបញ្ជាណាមួយ ថាត្រូវធ្វើយ៉ាងម៉េចចំពោះអ្នកទោសដែលនៅសេសសល់នោះដែរឬទេ?

**ឆៈ** ខ្ញុំវង្វេងថ្ងៃបន្តិច។ ខ្ញុំសង្ស័យថ្ងៃ០៣ បងនួន គាត់ហៅខ្ញុំទៅធ្វើការ ឲ្យគេហៅខ្ញុំទៅធ្វើការ។ ខ្ញុំទៅ។ ០៣ មករា ១៩៧៧ គាត់ថា "មិត្តបញ្ចេញពួកនុ៎ងទៅឲ្យអស់ទៅ!" ខ្ញុំថា "អ្ហាក! ចុះពួកយួន?" ព្រោះខ្ញុំត្រូវមានភារកិច្ចហ្នឹងជាប់សួរចម្លើយយួន ដើម្បីចាក់តាមវិទ្យុ។ នេះ ស-២១ មានភារកិច្ចហ្នឹង។ គាត់ថា "អត់អីទេ បញ្ចេញទៅទាំងអស់ទៅ យើងគង់រកបានទៀតទេ"។ អ៊ីចឹងថា ខ្ញុំតបតទៅទៀត "អ៊ីចឹងខ្ញុំសូមទុកពួក យ-៨។ អង្គភាព យ-៨ ដែលបាញ់ភៀសរបរទេសនោះ បួននាក់"។ គាត់ថា "អើ! ឲ្យទុកចុះ ក៏ប៉ុន្តែម្ចាស់ការណ៎ា!" ខ្ញុំថា "បាទបង"។ នេះជាថ្ងៃចុងក្រោយដែលខ្ញុំជួប បងនួន។ ហើយមកដល់កន្លែងភ្លាម ខ្ញុំហៅ មិត្តហ៊ី មកប្រាប់ពីផែនការបញ្ចេញមនុស្សទៅឲ្យអស់នេះ។ ហើយ មិត្តហ៊ី ក៏អាចចាប់ផ្តើមអនុវត្ត។ ដល់គេអនុវត្តចប់សព្វគ្រប់ហើយ គេមកបង្ហាញខ្ញុំ។ ដូច្នេះ គេថ្ងៃដែល

បងនួន ហៅខ្ញុំទៅនោះ បើមិនថ្ងៃ០១ ថ្ងៃ០៣ ឬក៏ផែនការហ្នឹងខ្ញុំអនុវត្តហើយនៅថ្ងៃ០៣ ក៏មិនដឹង។ ហើយពេលហ្នឹងហើយដែលខ្ញុំចាប់ផ្តើមអស់សង្ឃឹមបំផុត។ ខ្ញុំថាជីវិតខ្ញុំជិតផុតហើយ។ ខ្ញុំដេកនៅតែផ្ទះហ្នឹង អត់ងើបទេ។ គ្មាននរណាឃើញខ្ញុំនៅកន្លែងគូររូប ឆ្លាក់រូបទៀតទេ។

[០៩:៣៥:១៦]

**ស៖** សូមអរគុណ។ លោកនិយាយថា ថ្ងៃ០៣ ខែមករា ៧៩ លោកចង់និយាយគ្រាន់តែរយៈពេលមុនដែលលោកចាកចេញពីភ្នំពេញនោះមែនទេ?

**ឆ៖** មុនហ្នឹងរយៈពេលដែលខ្ញុំចេញ-- អរគុណ។ គឺមុនរយៈពេលដែលខ្ញុំចេញពីភ្នំពេញបួនថ្ងៃ។ ដូច្នេះប្រហែលជាថ្ងៃបញ្ចប់ផែនការបញ្ចេញមនុស្ស បញ្ចេញអ្នកទោសឱ្យអស់យកទៅកម្ទេចនុងហើយ អាចផែនការហ្នឹងគាត់ដាក់ចេញពីថ្ងៃ០១ ក៏មិនដឹង។ ដូច្នេះ ថ្ងៃខ្ញុំច្រឡំ នៅ វង្វេងហើយ ពេលចូលថ្នាក់វង្វេងហើយ។ វង្វេងថ្ងៃខែហ្នឹង។

**ស៖** ហើយនៅក្នុងអំឡុងពេលនោះថាតើមានអ្នកទោសចំនួនប៉ុន្មាននាក់ដែរ ដែលត្រូវនៅបន្តឃុំឃាំង ឬរក្សាទុកនៅស-២១ នោះ?

**ឆ៖** អរគុណ។ ច្បាស់ណាស់គឺនៅតែបួននាក់ទេ គឺពួក យ-៨ គឺពួកកងការពារភ្ញៀវ ១មក ហើយដែលស្លាប់ហ្នឹង មានពួកលោកអឺ ហ្សាឌឹកម៉ាន់ (ប្រកបតាមសំឡេងដើម) ជាដើម។

[០៩:៣៦:៤៧]

**ស៖** ហើយតើមានអ្វីកើតឡើងទៅលើអ្នកទោសបួននាក់ដែលនៅសេសសល់ហ្នឹង?

**ឆ៖** អរគុណ។ អ្នកទោសបួននាក់ដែលនៅសេសសល់ហ្នឹងខ្ញុំបានផ្តាំផ្ញើអ៊ីចឹង។ ហើយទៅមិត្តហ៊ី គាត់ចាត់ចែងឱ្យគេបន្តសួរអ្នកបួននាក់នេះ តាមភារកិច្ចរបស់គេ ក៏ប៉ុន្តែគ្រាន់តែប្រាប់ថា មានរឿងអីម្ចាស់ការ។ ម៉ោងដប់មួយ ថ្ងៃត្រង់ ថ្ងៃទី០៧ មករា ១៩៧៧នេះ អ៎! ៧៩នេះ រថក្រោះវៀតណាមគេបើកតាមផ្លូវមុន្នីវង្សកាត់មុខផ្ទះខ្ញុំ ផ្អើលឆុរ។ ពេលនោះ មិត្តណាន-- ប្រាក់ ណាន អ្នកសួរចម្លើយម្នាក់គាត់យកចំពុះទុងទៅចាក់ជនរងគ្រោះ នៃពួក យ-៨ បួននាក់ហ្នឹង ស្លាប់នៅលើកៅអីបាត់ទៅនៅលើគ្រែហ្នឹងបាត់ទៅហើយ។

**ស៖** សូមអរគុណលោក។ ឥឡូវនេះ ខ្ញុំចង់ចូលទៅឯកសារមួយផ្សេងទៀត ប្រហែលជាលោកបានឃើញហើយគឺឯកសារ D108/50.1.7 ខ្ញុំមានឯកសារក្រដាសជូនលោកផងដែរ។ ហើយសុំការអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីបង្ហាញឯកសារនៅលើអេក្រង់។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត។ សូមអញ្ជើញ!

[០៩:៣៨:៤២]

**សួរដោយលោក វីណ្ស៊ៀម ស្មីត៖**

**ស៖** លោក កាំង ហ្កេកអ៊ាវ យើងទើបតែបាននិយាយគ្នាអំពីឯកសារនិយាយអំពីសេចក្ដីណែនាំរបស់បក្សកុម្មុយនីស្តកម្ពុជា ចំពោះខ្មាំង គឺនៅពាក់កណ្ដាលឆ្នាំ១៩៧៨ ឯកសារចេញនៅពេលនោះគឺឯកសារនេះគឺហាក់ចេញមកពីមជ្ឈិមបក្ស ដែលមានចំណងជើងថា "សេចក្ដីណែនាំអំពីការប្រើពាក្យអង្គការ និងពាក្យបក្ស" នេះឯកសារនេះចុះថ្ងៃទី១១ ខែកក្កដា ៧៧។ តើលោកធ្លាប់បានឃើញឯកសារនេះពីមុនដែរទេ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ឯកសារនេះខ្ញុំវាក់ ដូចជាមិនធ្លាប់ឃើញ ក៏ប៉ុន្តែអក្សរខាងលើនេះ គឺអក្សរមេខ្ញុំហើយ គឺអក្សរ សុន សេន។ ខ្ញុំវាក់ហើយ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការដកឯកសារអម្បាញ់មិញនេះពីសាក្សី ហើយនិងដកឯកសារនេះចេញពីអេក្រង់ទូរទស្សន៍!

[០៩:៤០:២០]

**សួរដោយលោក វីណ្ស៊ៀម ស្មីត៖**

**ស៖** ពេលដែលលោកឃើញថា ចំណារនេះ ជាចំណារមេរបស់លោកហើយ។ មេហ្នឹង គឺលោកសំដៅទៅអ្នកណា?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ តែកាលណាខ្ញុំនិយាយមេហើយ អត់មានឈ្មោះ ជាទូទៅគឺសំដៅតែម្នាក់គត់ គឺ សុន សេន។ ហើយបើ បងនួន ខ្ញុំសំដៅ-- ខ្ញុំនិយាយឈ្មោះគាត់បងទីពីរ ឬអនុលេខាបក្ស ឬក៏ បងនួន។ កាលណាខ្ញុំនិយាយមេមួយម៉ាត់ដាច់ប៉ិត គឺ សុន សេន។

**ស៖** ឯកសារនេះ ហាក់ដូចជាគោលនយោបាយក្នុងការបញ្ជាឲ្យប្រើប្រាស់ពាក្យ "អង្គការ" ឬក៏ "បក្ស" នេះ។ ហើយឯកសារនេះ ថាពាក្យ "អង្គការ" ឬក៏ "បក្ស" ប្រើសម្រាប់តែអង្គការទេ មិនប្រើ

ចំពោះបុគ្គលណាម្នាក់នោះទេ។ ឯកសារនេះ ចេញនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ៧៧ តើលោកអាចនៅចាំបានទេ ថាតើវាជាគោលនយោបាយនេះ ធ្លាប់បានបញ្ជូនទៅលោកតាមមធ្យោបាយណាមួយ ឬក៏ក្នុងវគ្គបណ្តុះបណ្តាលណាមួយ ក្នុងការប្រើពាក្យ "អង្គការ" នេះ គឺពាក់ព័ន្ធតែទៅនឹងអង្គការទាំងមូលតែម្តង មិនពាក់ព័ន្ធតែចំពោះបុគ្គលណាម្នាក់នោះទេ?

[០៩:៤២:១១]

**ឆ៖** អរគុណ។ ពាក្យ "អង្គការ" នេះ មានការណែនាំ ហើយបើនិយាយពីការខុសឆ្គងក៏មានដែរ ខ្ញុំឃើញច្បាស់នឹងភ្នែក។ ណាត បណ្តោយឱ្យកូនចៅហៅគាត់ "អង្គការ" ជាពិសេស យូ ប៉េងគ្រី ហៅ ម៉ុន ហ្នឹង ហៅណាត អង្គការពេញមាត់ នឹងមុខគាត់ នឹងមុខខ្ញុំ។ ខ្ញុំទទួលមិនបាន។ ហើយដល់ក្រោយមក ដូចជាវាមានឮការណែនាំរបស់ខាងលើ។ ប៉ុន្តែជាទូទៅ ក្នុងការប្រើពាក្យ "អង្គការ" នេះ សំដៅថា ប៉ុល ពត។ ហើយនិយាយមួយម៉ាត់ ចំពោះខ្ញុំ ខ្ញុំប្រើអង្គការនេះ សំដៅអចិន្ត្រៃយ៍មជ្ឈិមបក្ស។ បុគ្គលណាមួយដែលចុះមកដឹកនាំខ្ញុំក្នុងតំណាង ប៉ុល ពត តែជាអចិន្ត្រៃយ៍មជ្ឈិមបក្ស។ នេះខ្ញុំការអនុវត្តប៉ុណ្ណឹង។ ក៏ប៉ុន្តែពាក្យណែនាំហ្នឹង ពិតជាមានការណែនាំតាមវគ្គ ឬក៏តាមស្អីណាមួយខាន មិនខានទេ។ មាន ព្រោះវាមានបាតុភាពខុសឆ្គងអ៊ីចឹង ដូចនៅស-២១ គឺបាតុភាពខុសឆ្គង ណាត ហ្នឹងតែម្តង។

[០៩:៤៣:៣៣]

**ស៖** តើលោកមានបានដឹងអំពីគោលនយោបាយ ឬក៏សេចក្តីសម្រេចចេញដទៃទៀត ចេញមកពីគណៈមជ្ឈិមហ្នឹង ទាក់-- នៅក្នុងអំឡុងពេលហ្នឹង ទាក់ទងទៅនឹងសេចក្តីណែនាំរបស់គណៈមជ្ឈិម? ពាក់ព័ន្ធទៅនឹងខ្មែររបស់ខ្មាំង ក្នុងអំឡុងពេលដែលលោកនៅស-២១ហ្នឹង តើលោកមានទទួលជាសារាចរ ជាគោលនយោបាយ ជាសេចក្តីសម្រេចមកពីគណៈមជ្ឈិមនេះដែរឬទេ?

**ឆ៖** គោលនយោបាយៗ របស់បក្សចំពោះខ្មាំង។ វាមានសភាពមួយគឺដែលនឹងនរ។ ឲ្យតែខ្មាំង អង្គការប្រកាសថាខ្មាំងហើយ ត្រូវតែកម្ទេច។ ក៏ប៉ុន្តែដែលវិវឌ្ឍទៅតាមសភាពការណ៍ក្នុងរយៈកាលជាយុទ្ធវិធីនីមួយៗ។ ដូច្នេះ គ្មានការណែនាំជាក់ស្តែងទេ។ ដំបូងនៅស-២១ គេចាប់ពួកកម្មករដែលធ្វើបំផ្លាញរោងចក្រ បំផ្លាញអីហ្នឹង យកទៅវ៉ៃ សួរចម្លើយ អាហ្នឹងគេទុកជាខ្មាំងហើយ។ គេថាពួកនេះបំផ្លាញនេះ ពួកនោះបំផ្លាញនោះ។ ដល់ក្រោយមក សុន សេន ណែនាំឲ្យស-២១ កំណត់ សេ.អ៊ី.អា ដោយសារយកសេចក្តីសារភាពរបស់មនុស្សម្នាក់ដែល ចាប ណម លេខាមន្ទីរតំបន់៣២ ទទួលយកបានថា សេ.អ៊ី.អា បង្កឲ្យស-២១ រក សេ.អ៊ី.អា ឲ្យឃើញ។ ដូច្នេះនៅស-២១ កំណត់ សេ.អ៊ី.អា ទៅ។

ដល់ក្រោយមក កុយ ធួន ក៏ សេ.អ៊ី.អា ហើយដល់ក្រោយមកទៀតលេចចេញ កា.ហ្សេ.បេ ដល់ក្រោយមកទៀតលេចចេញភ្នាក់ងារយួនលេបទឹកដី។ ដូច្នេះអាហ្នឹងវាលេចចេញទៅតាមចលនាអ៊ីចឹង គ្មានសារាចរអីទេ ក៏ប៉ុន្តែអនុវត្តជាទូទៅ។ ប្រឆាំងអាខ្មាំងយួនឈ្លាន-- អ៊ំអ៊ែ! ប្រឆាំង សេ.អ៊ី.អា, កា.ហ្សេ.បេ, ភ្នាក់ងារយួនលេបទឹកដីប្រល័យពូជសាសន៍ វាមានជាហូរហែតាមវិទ្យុ។ ហើយបងាពេលបុណ្យម្តងៗ ក៏សរសេរអាហ្នឹង។ ដូច្នេះគោលនយោបាយចំពោះខ្មាំងនឹងនរ គឺខ្មាំងត្រូវតែសម្លាប់។ ហើយអ្នកណាជាខ្មាំង? វិវឌ្ឍ។

[០៩:៤៦:១០]

**ស៖** សូមអរគុណ។ ខ្ញុំសំដៅទៅលើគោលនយោបាយជាក់លាក់ ទាក់ទងទៅនឹងសេចក្តីណែនាំក្នុងការប្រើពាក្យ “អង្គការ” និង “បក្ស”។ ពាក្យថាជាក់លាក់នេះ គឺសេចក្តីណែនាំនិយាយគោលនយោបាយបក្សចំពោះខ្មាំង។ តើលោកមានបានដឹងអំពីគោលនយោបាយ ឬសេចក្តីណែនែជាក់លាក់ណាមួយដែលចេញដោយគណៈមជ្ឈិម ក្រៅពីឯកសារដែលយើងទើបពិភាក្សាគ្នានេះ? គឺនៅក្នុងអំឡុងពេលនោះតែម្តង តើលោក ក្រែងលោលោកធ្លាប់បានទទួលនៅពេលដែលលោកនៅស-២១ នោះ?

**ឆ៖** ខ្ញុំបានបញ្ជាក់ជូនតុលាការជាហូរហែ គ្រប់ពេលវេលាទាំងអស់។ គោលនយោបាយរបស់បក្សចំពោះខ្មាំង គឺត្រូវតែកម្ទេច ហើយខ្ញុំបានបញ្ជាក់ប៉ុន្មានថ្ងៃមុនថា បញ្ហានេះវា*ក្លាស៊ីក* គឺវាអត់ប្រែប្រួលទេ។

**ស៖** សូមអរគុណ។ នៅលើឯកសារនេះ គឺមានចំណារដែលលោកថាជារបស់ សុន សេន ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ៧៧ ដែលនៅពេលនោះស-២១ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់អគ្គសេនាធិការដដែលនោះ?

[០៩:៤៧:៥៣]

**ឆ៖** ដូចអត់ទាន់ឮសំណួរ ឮតែសេចក្តីអធិប្បាយរបស់ព្រះរាជអាជ្ញា។

**ស៖** នៅខែកក្កដា ឆ្នាំ១៩៧៧ តើស-២១ នៅតែស្ថិតនៅក្រោមការគ្រប់គ្រងរបស់សេនាធិការដ្ឋានដែរឬទេ?

**ឆ៖** ខ្ញុំមិនឆ្លើយអ៊ីចឹងទេ។ ឆ្លើយហ្នឹងទូលាយ ហើយវាពាំត្រណោតបន្តិច។ ខ្ញុំសូមឆ្លើយថា ខ្ញុំឡើងចុះទៅរាយការណ៍ និងទៅធ្វើការឲ្យ សុន សេន រហូតដល់ថ្ងៃ១៥ សីហា ១៩៧៧។ ដូច្នេះរយៈកាលដែលសារាចរនេះចេញ គឺខ្ញុំនៅក្រោមការគ្រប់គ្រងរបស់ សុន សេន ខាងការងារសន្តិបាល។

**ស៖** នៅដំណាក់កាលនេះ ថាតើ សុន សេន នៅតែជាប្រធានសេនាធិការដែរឬទេ?

**ឆ៖** អរគុណ។ សុន សេន នេះជាប្រធានសេនាធិការតាំងពីមុន៧៥។ ឯកសារថ្ងៃ០៩ តុលា ១៩៧៥ បន្ថែមភារកិច្ចមួយទៀតឱ្យ សុន សេន គឺសន្តិបាល សន្តិសុខ។ ដូច្នេះភារកិច្ចសន្តិសុខនេះ ជាភារកិច្ចដែល ប៉ុល ពត បន្ថែមឱ្យ សុន សេន នៅថ្ងៃ០៩ តុលា ១៩៧៥ គាត់នៅតែជាប្រធានសេនាធិការរហូតៗ គាត់អស់ជីវិត។

[០៩:៥០:១២]

**លោក វីណ្ស៊្លៀម ស្មីត៖**

សូមអរគុណ។ ឥឡូវ ខ្ញុំបញ្ចប់ការសួរទៅលើឯកសារនេះហើយ ខ្ញុំសូមអនុញ្ញាតប្រើប្រាស់ឯកសារមួយទៀត គឺ D366/7.1.475 ហើយខ្ញុំមានឯកសារជាក្រដាសសម្រាប់សាក្សីផងដែរ។ ហើយខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះ ដើម្បីបង្ហាញឯកសារនៅលើអេក្រង់។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**លោក វីណ្ស៊្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វីណ្ស៊្លៀម ស្មីត៖**

ចំណងជើងនៃឯកសារនេះដាក់ថា "មតិណែនាំរបស់៨៧០" កម្មវត្ថុ អំពីការទម្លាក់គ្រាប់បែករបស់ចក្រពត្តិអាមេរិកលើក្រុងសៀមរាបនៅថ្ងៃ២៥ កុម្ភៈ ឆ្នាំ៧៦។ ហើយគឺគណៈកម្មាធិការ៨៧០--បើឯកសារនេះនៅផ្នែកខាងក្រោមនិយាយថា "គណៈអចិន្ត្រៃយ៍" ដែលលើកថា ពួកគេគឺជាប់ពាក់ព័ន្ធទៅនឹងពួកចក្រពត្តិអាមេរិក និយាយពីការទម្លាក់គ្រាប់បែកនៅថ្ងៃទី២៥ កុម្ភៈ ៧៦។

**ស៖** សំណួររបស់ខ្ញុំ បើលោកមើលទៅឯកសារនេះ តើលោកធ្លាប់ឃើញឯកសារនេះពីមុនដែរទេ?

[០៩:៥២:០៤]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ខ្ញុំសូម ទាំងអស់គ្នាចាប់អារម្មណ៍ទៅលើថ្ងៃ កាលបរិច្ឆេទ គឺថ្ងៃ២៧ ខែកុម្ភៈ ឆ្នាំ១៩៧៦។ ពេលហ្នឹងគឺខ្ញុំអត់ទាន់ប្រកាន់តួនាទីជាប្រធានស-២១ ទេ តួនាទីនៅលើ ណាតៗ ដូច្នេះ

ឯកសារនេះអាចមកដល់ស-២១ តែ ណាត មិនបង្ហាញជាទូលាយ ក៏សឹងតែថាបាន។ ក៏ប៉ុន្តែបំផុសសកម្មភាពធ្វើមីទ្ទិងតាមសេចក្តីណែនាំនេះ។ ខ្ញុំសូមបញ្ជាក់តែប៉ុណ្ណឹងទេ។

**ស៖** ដូច្នេះដើម្បីបញ្ជាក់ឲ្យច្បាស់គឺថា លោកមានបាន-- លោកមិនបានឃើញឯកសារនេះពីមុនមកទេ អ៊ីចឹងមែនទេ?

**ឆ៖** ត្រូវ! ត្រឹមត្រូវ។

[០៩:៥២:៥៩]

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការដកឯកសារនេះចេញពីសាក្សី ហើយនិងដកចេញពីអេក្រង់ទូរទស្សន៍។

**សួរដោយ លោក វីណ្ឌៀម ស្មីត៖**

**ស៖** តើលោកមានបានដឹងអំពីព្រឹត្តិការណ៍នៃការទម្លាក់គ្រាប់បែកនៅក្រុងសៀមរាបថ្ងៃទី២៥ កុម្ភៈ ៧៦ នេះដែរទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ព្រឹត្តិការណ៍នេះ បើតាមការរំឭកឡើងវិញ ដូចមានផ្សាយតាមវិទ្យុ។ ហើយដល់ក្រោយមក ណាត គាត់បំផុតឲ្យធ្វើមីទ្ទិងមួយនៅ-- មីទ្ទិងហ្នឹងធ្វើនៅ មិនមែននៅស-២១ ទេ នៅក្នុងសាលាគរុកោសល្យខាងត្បូង អំ ខាងជើង។ សាលាគរុកោលស្យខាងជើង។

**ស៖** តើកិច្ចប្រជុំហ្នឹងមានគោលបំណងអ្វីដែរ?

**ឆ៖** កិច្ចប្រជុំហ្នឹងគឺមានគោលបំណងតែមួយទេ គឺបំផុសកំហឹងរបស់យុទ្ធជនឲ្យប្តេជ្ញាចិត្តប្រឆាំងចក្រពត្តិនិយម ហើយនិងបរិវារវា តែប៉ុនទ្នុងឯងទេ។

**ស៖** តើការប្រជុំនោះ តាមដែលលោកដឹង វាពាក់ព័ន្ធទៅនឹងការទម្លាក់គ្រាប់បែកនេះដែរឬទេ?

[០៩:៥៥:១៣]

**ឆ៖** អរគុណ។ ការប្រជុំនេះវាពាក់ព័ន្ធទៅនឹងការទម្លាក់គ្រាប់បែក ព្រោះ ណាត គាត់ចេញទៅគាត់ខទ្មេសនាមពីរបីម៉ាត់ដែរ អំពីព្រឹត្តិការណ៍ទម្លាក់គ្រាប់បែក។ ហើយនិងនិយាយបំផុសកំហឹង បានឲ្យយុទ្ធជនផ្សេងទៀត គេឡើងប្តេជ្ញាចិត្តប្រឆាំងចក្រពត្តិ។

**ស៖** តើលោកមានដឹងថា មានការស៊ើបអង្កេតណាមួយដើម្បីរកឲ្យឃើញថាអ្នកណាជាអ្នកទទួលខុសត្រូវចំពោះការទម្លាក់គ្រាប់បែកនេះដែរទេ?

**ផ៖** អរគុណ។ ខ្ញុំមិនដឹងទេ។

**ស៖** លោកដឹង មានបានដឹងថាតើគេរកឃើញអ្នកណាម្នាក់ទទួល-- រកឃើញថាជាអ្នកទទួលខុសត្រូវចំពោះការទម្លាក់គ្រាប់បែកនេះដែរទេ?

[០៩:៥៦:៣៣]

**ផ៖** ខ្ញុំមិនដឹងទេ។

**ស៖** អរគុណលោក។ ឥឡូវនេះ ខ្ញុំសុំបញ្ចប់ការសាកសួរពីឯកសារនេះហើយ។ ខ្ញុំសួរទៅលើប្រធានបទផ្សេងវិញម្តង ជាពិសេសទាក់ទងទៅនឹងការបង្កើតក្រសួងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ តើលោកអាចនិយាយបានថា តើមានក្រសួងប៉ុន្មានដែរ ដែលត្រូវគេ-- ត្រូវបានគេបង្កើតនៅក្នុងអំឡុងពេលនោះ ដើម្បីៗជាសេនាធិការ ឬក៏ជាការជំនួយការទៅដល់របបកម្ពុជាប្រជាធិបតេយ្យនោះ?

**ផ៖** អរគុណ។ ក្រសួងដែលកកើតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺមានក្រសួងពាណិជ្ជកម្មរដ្ឋ ដែលពីដើមឡើង-- ដែលដំបូងគ្រប់គ្រងដោយ កុយ ធួន។ ក្រសួងថាមពល ដែលដំបូងគ្រប់គ្រងដោយ កៅ រិទ្ធ ណុប មឿន ឈ្មោះដើម ណុប មឿន ក៏ប៉ុន្តែបានមួយសន្ទុះក៏ប្រគល់មកឲ្យ ឆាយ គឹមហ៊ៅ ហុក។ ក្រសួងសង្គមកិច្ច ក្រសួងនេះមានលក្ខណៈតៀតនៅឡើយទេ គ្រប់គ្រងត្រឹមតែរោងចក្រផលិតថ្នាំពេទ្យប៉ុន្មានគ្រាប់ប៉ុននុ៎ង។ ក្រសួងវប្បធម៌គ្មានទេ។ ក្រសួងឃោសនាការ គ្រប់គ្រងដោយ ហ៊ូ នឹម។ ក្រសួងអប់រំគ្រប់គ្រងដោយ យុន យ៉ាត ដល់ក្រោយពីពេលចាប់ ហ៊ូ នឹម មក យុន យ៉ាតគ្រប់គ្រងទាំងឃោសនាការ-- អ៎!គ្រប់គ្រងទាំងអប់រំផង ទាំងឃោសនាការផង។

[០៩:៥៨:៥១]

ដូច្នេះក្រសួងវាអស់ប៉ុណ្ណឹងឯង។ បើនិយាយពីគណៈកម្មាធិការ វាមានគណៈកម្មាធិការផ្សេងទៀតច្រើនដែរ អ៎! ក្រសួងឧស្សាហកម្មមួយទៀត គ្រប់គ្រងដោយ ចេង អន។ បើនិយាយគណៈកម្មាធិការការងារវាមានផ្សេងដូចជាៗ៖ ឃ្លាំងរដ្ឋ កាត់ដេររដ្ឋៗ ដូចចំណុះឲ្យនេះទេ-- ដឹកជញ្ជូនជើងទឹក ដឹកជញ្ជូនជើងគោក។ នេះខ្ញុំសូមរំឭកឃើញប៉ុណ្ណឹងសិន។

**ស៖** សូមអរគុណ។ តើលោកបានដឹងទេ ថានៅពេល-- នៅក្នុងរបបនៃកម្ពុជាប្រជាធិបតេយ្យ លោកមានដឹងអំពី-- នៅពេលនោះគឺថាលោកដឹងពីអត្ថិភាពនៃក្រសួងនេះទេ នៅអំឡុងពេលនោះតែម្តង?

**ផ៖** អរគុណ។ ខ្ញុំដឹង អត្ថិភាពរបស់ក្រសួងប៉ុន្មានដែលខ្ញុំរៀបរាប់អំមិញ ហើយប្រហែលជាខ្ញុំរៀបរាប់អំមិញនៅខ្វះផង។

**ស៖** នៅពេលហ្នឹង មានក្រសួងការបរទេសដែរទេ?

**ឆ៖** អរគុណ។ ក្រសួងនេះធំណាស់ មាន។ ក្រសួងនេះធំណាស់ ហើយមាន។

**លោក វីណ្តៀម ស្មីត៖**

សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមបង្ហាញនូវឯកសារមួយ D31/8.3 គឺឯកសារដែលចេញនៅថ្ងៃទី៩ ខែតុលា ៧៥។ ខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះ ដើម្បីបង្ហាញនៅលើអេក្រង់ ហើយខ្ញុំមានឯកសារជាក្រដាសបង្ហាញជូនសាក្សីផងដែរ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

[១០:០១:៣៩]

**សួរដោយលោក វីណ្តៀម ស្មីត៖**

**ស៖** តាមមើលឯកសារនេះ តើលោកបានឃើញឯកសារនេះទេកាលពីមុន?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ក្នុងជំនាន់កម្ពុជាប្រជាធិបតេយ្យ ខ្ញុំអត់ដែលបានឃើញឯកសារនេះទេ ហើយឃើញក្នុងសវនាការ។

**ស៖** តើលោកបានឃើញឯកសារនេះនៅក្នុងដំណាក់កាលស៊ើបអង្កេត ហើយលោកបានផ្តល់យោបល់លើឯកសារនេះដែរឬទេ?

**ឆ៖** បើតាមខ្ញុំចាំ ខ្ញុំឃើញឯកសារនេះនៅក្នុងសវនាការតែម្តង សវនាការលេខសំណុំរឿងលេខ ០០១ តែម្តង។ ហើយខ្ញុំមានផ្តល់យោបល់។

**ស៖** ខ្ញុំមានសំណួរពីរបីចំពោះលោក ដើម្បីឲ្យបញ្ជាក់ថា តើបុគ្គលមួយចំនួននេះជាអ្នកណាដែលគេប្រគល់ការងារឲ្យធ្វើនៅក្នុងឯកសារមួយនេះ។ លោកបាននិយាយថា ឈ្មោះបដិវត្តន៍ ហើយមានឈ្មោះបដិវត្តន៍ចំពោះមនុស្សមួយចំនួន ហើយអ្នកខ្លះហ្នឹង គឺយើងឃើញមានឈ្មោះម្តងទៀតនៅលើឯកសារនេះ។ ខ្ញុំនឹងសួរលោកឲ្យបានពេញលេញថា តើយើងមើលបញ្ជីឈ្មោះ១៣នាក់នៅក្នុងទំព័រទី១១ និយាយអំពីការងារផ្ទេរភារកិច្ច ហើយថាតើលោកដឹងពីឈ្មោះអ្នកទាំងអស់នេះ ដើម្បីយើងកត់ត្រានៅក្នុងកំណត់ត្រាតុលាការ ដើម្បីឲ្យយើងយល់ឯកសារនេះឲ្យបានច្បាស់។ ហើយអ្នកទីមួយ ហៅថាសមមិត្តលេខា ទទួលរួមយោធា និងសេដ្ឋកិច្ច តើលោកបានឃើញទេ បាទនៅលេខមួយ?

ឆ៖ អរគុណ។ ខ្ញុំបានឃើញ។

[១០:០៤:១០]

ស៖ ដើម្បីឲ្យយល់ច្បាស់នៅក្នុងបញ្ជីនេះ តើអ្នកណាជាសមមិត្តលេខា?

ឆ៖ អរគុណ។ សមមិត្តលេខា គឺប៉ុល ពត។

ស៖ ទីពីរហៅថា សមមិត្តអនុលេខាការងារបក្សសង្គមកិច្ច វប្បធម៌ ឃោសនាការ និងសិក្សាធិការ តើអ្នកណាជាសមមិត្តអនុលេខា?

ឆ៖ អរគុណ។ សមមិត្តអនុលេខា គឺនួន ជា។

ស៖ នៅលំដាប់ទីបី គឺសមមិត្ត វ៉ាន់ ការងារបរទេសទាំងបក្ស និងរដ្ឋ តើសមមិត្ត វ៉ាន់ ជាអ្នកណា?

ឆ៖ អរគុណ។ សមមិត្ត វ៉ាន់ គឺបង អៀង សារី។

ស៖ ហើយទីបួន សមមិត្ត ហែម ទទួលរណសិរ្ស និងរាជរដ្ឋាភិបាលពាណិជ្ជកម្មខាងបញ្ជី និងតម្លៃ តើសមមិត្តហែម ជាអ្នកណា?

ឆ៖ អរគុណ។ សមមិត្ត ហែម គឺបង ខៀវ សំផន។

ស៖ ទីប្រាំ គឺសមមិត្តឌុច ពាណិជ្ជកម្មក្នុងប្រទេស និងក្រៅប្រទេស តើឌុច សមមិត្ត ឌុច ជាអ្នកណា?

[១០:០៦:០៥]

ឆ៖ អរគុណ។ ឌុច គឺ កុយ ធួន។

ស៖ ប្រាំមួយ គឺសមមិត្ត ខៀវ ទទួលសេនាធិការ និងសន្តិសុខ តើអ្នកណាជាសមមិត្ត ខៀវ?

ឆ៖ អរគុណ។ សមមិត្ត ខៀវ គឺបង សុន សេន។ គឺ សុន សេន។

ស៖ ទីប្រាំពីរ សមមិត្ត វន គឺទទួលបន្ទុកខាងឧស្សាហកម្ម អយស្ម័យយាន តើសមមិត្ត វន ជាអ្នកណា?

ឆ៖ សមមិត្តវន គឺ វន វ៉េត។

ស៖ ហើយលេខប្រាំបី សមមិត្ត ឌឿន ប្រធានមន្ទីរនយោបាយរបស់៨៧០ តើសមមិត្ត ឌឿន ហ្នឹងគាត់ជាអ្នកណា?

ឆ៖ អរគុណ។ សមមិត្ត ឌឿន នេះ គឺឈ្មោះដើម សៀ វ៉ាស៊ី។

[១០:០៧:៣៩]

**ស៖** ពីម្សិលមិញលោកបានប្រាប់តុលាការថា នៅចំណុចមួយគាត់បានចេញពីតំណែងនេះ ហើយទៅកាន់តំណែងមួយទៀត តើត្រូវឬទេ?

**ឆ៖** អរគុណ។ មិត្តខឿន ចេញពីនេះ ទៅកាន់ពាណិជ្ជកម្មរដ្ឋ ត្រឹមត្រូវ។

**ស៖** សូមអរគុណ។ លើ-- បាទ លេខប្រាំបួន សមមិត្តភា ទទួលវប្បធម៌ សង្គមកិច្ច និងការងារបរទេស។

**ឆ៖** អរគុណ។ សមមិត្តភា គឺអ្នកបង អៀង ធីរិទ្ធ។

**ស៖** ហើយ អៀង ធីរិទ្ធ ជាភរិយារបស់លោក អៀង សារី តើត្រូវដែរឬទេ?

**ឆ៖** អរគុណ។ អ្នកបង អៀង ធីរិទ្ធ គឺភរិយាបង អៀង សារី។

**ស៖** ហើយលេខដប់ គឺសមមិត្ត អាត ឃោសនាអប់រំទាំងផ្ទៃក្នុង ទាំងខាងក្រៅ តើសមមិត្ត អាត ជាអ្នកណា?

[១០:០៩:០៧]

**ឆ៖** អរគុណ។ សមមិត្ត អាត គឺអ្នកបង យុន យ៉ាត ប្រពន្ធបង ខៀវ សំផន-- អ៎! ប្រពន្ធបង សុន សេន។

**ស៖** លេខ១១ សមមិត្ត ជ័យ កសិកម្ម តើសមមិត្ត ជ័យ ហ្នឹងគាត់ជាអ្នកណា?

**ឆ៖** អរគុណ។ សមមិត្ត ជ័យ ហ្នឹងឈ្មោះជាទូទៅដែលគាត់ធ្លាប់ប្រើគឺ នង សួន-- នួន សួន។

**ស៖** ហើយ១២ គឺសមមិត្ត យ៉េម ការិយាល័យ៨៧០ តើសមមិត្ត យ៉េម ហ្នឹងគាត់ជាអ្នកណា?

**ឆ៖** អរគុណ។ សមមិត្ត យ៉េម ហ្នឹងគឺ ស៊ុម សុន។

**ស៖** លេខ១៣ សមមិត្ត ប៉ង់ គឺតើប៉ង់ហើយជាអ្នកណា? គាត់ទទួលខាងមន្ទីររដ្ឋាភិបាល?

**ឆ៖** អរគុណ។ ប៉ង់ នេះគឺ ឈឹម សំអោក។

**លោក វីណ្ឌៀម ស្មីត៖**

សូមអរគុណ។ ឥឡូវនេះខ្ញុំបញ្ចប់ឯកសារនេះ ហើយខ្ញុំនឹងសូមដាក់បង្ហាញឯកសារ IS13.16 គឺកំណត់ហេតុរបស់កិច្ចប្រជុំអចិន្ត្រៃយ៍នៅថ្ងៃទី០៧ ឧសភា ឆ្នាំ៧៦ អំពីបញ្ហាពាណិជ្ជកម្ម។ ខ្ញុំមានឯកសារលើក្រដាស សូមអនុញ្ញាតលោកប្រធានដើម្បីបង្ហាញសាក្សី ហើយនិងដាក់លើអេក្រង់ផងដែរ បាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

[១០:១១:៤១]

**សួរដោយលោក វីណ្ឌៀម ស្មីត៖**

**ស៖** សូមលោកពិនិត្យមើលឯកសារនេះ ហើយប្រាប់តុលាការ និងខ្ញុំថា តើលោកបានឃើញឯកសារនេះឬទេ កាលពីមុន?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំមិនដែលឃើញឯកសារនេះទេពីមុនមក។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការដកហូតយកឯកសារនេះពីសាក្សីវិញ ហើយនិងឲ្យដកចេញពីអេក្រង់ទូរទស្សន៍!

**លោក វីណ្ឌៀម ស្មីត៖**

**ស៖** នៅក្នុងឯកសារនេះ គឺមានឈ្មោះមួយចំនួនម្ដងទៀត ដែលខ្ញុំចង់ឲ្យលោកជួយបញ្ជាក់បន្ថែម។ សមមិត្ត គ្រិន តើសមមិត្តគ្រិនហ្នឹងជាអ្នកណា?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ សមមិត្ត គ្រិន នេះ ឈ្មោះដើមគឺ ធុច រិន។

[១០:១៣:២៥]

**ស៖** ចុះ*កាំម្រាដ* -- អ៎ សមមិត្ត សោម ជាអ្នកណា?

**ឆ៖** សូមបញ្ជាក់មួយម៉ាត់។ ព្រះរាជអាជ្ញា សោម នេះឈ្មោះច្រើនណាស់។ ទីវ អុល ក៏ឈ្មោះ សោម។ ឈឹម សុខងួន ខាងកំពង់ផែក៏ឈ្មោះ សោម។ ពេជ ឆន សេនាធិការក៏ឈ្មោះ សោម។ ដូច្នេះ ព្រះរាជអាជ្ញាសួរខ្ញុំសោម ណាមួយ? សោម កំពង់ផែ ឬសោម ឃោសនាការ? ឬសោម សេនាធិការ?

**ស៖** អ៊ីចឹងគឺថា ដាក់នៅក្នុងជាគណៈកម្មាធិការកំពង់ផែ។

**ឆ៖** អរគុណ។ សោម នេះគឺ ឈឹម សុខងួន។

**ស៖** បន្ទាប់មកទៀត គឺសមមិត្តមួយ?

**ឆ៖** បុគ្គលនេះខ្ញុំមិនស្គាល់ទេ។

**ស៖** បន្ទាប់មកទៀតមានសមមិត្ត សារិន?

**ឆ៖** បុគ្គលនេះក៏ខ្ញុំមិនស្គាល់ដែរ។

**ស៖** ហើយសមមិត្ត វុធ លោកស្គាល់ទេ?

**ឆ៖** បុគ្គលនេះ ក៏ខ្ញុំមិនស្គាល់។

[១០:១៥:២៤]

**ស៖** បុគ្គលទាំងអស់នេះ គឺថាយើងដាក់-- ខ្ញុំអានជូនអំមិញនេះ គឺនៅក្នុងរបាយការណ៍របស់គណ:កម្មាធិការ ហើយខ្ញុំចង់សួរឈ្មោះមនុស្សពីរនាក់ទៀត ដែលនៅក្នុងគណ:ពាណិជ្ជកម្ម ហើយសមមិត្ត ជ័យ។

**ឆ៖** មិនដឹងជា ជ័យ ណាទេ។ ខ្ញុំស្គាល់តែ ជ័យ ម្នាក់ នៅកសិកម្ម។ ដូច្នេះ ព្រះរាជអាជ្ញាសូមបញ្ជាក់មើល៍ កសិកម្ម ឬក៏ពាណិជ្ជកម្ម។

**ស៖** នៅក្នុងបរិបទនេះ គឺសមមិត្ត ជ័យ គឺជាទទួលខាងកសិកម្ម ហើយក៏ ហើយទៅជំនួសដោយខាងគណ:ពាណិជ្ជកម្ម។ បាទ និយាយពី ជ័យ មកពីខាងកសិកម្មនុ៎ង ថាតើជ័យ ជាអ្នកណា ដែលក្រោយមក ទៅកាន់ខាងពាណិជ្ជកម្ម?

**ឆ៖** បងជ័យ មិនដែលទៅខាងពាណិជ្ជកម្មទេ។ បងជ័យ មុនដំបូង គេចាត់តាំងឲ្យខាងឃ្លាំងប្រាក់។ ប៉ុន្តែដល់ឃ្លាំងនុ៎ងមិនប្រើ ផ្ទេរ បងជ័យ ទៅឲ្យ-- ច្រឡំៗហើយ ដូច្នេះ បងជ័យ មិនដែលទៅពាណិជ្ជកម្មទេ។ បង ជ័យ នៅតែខាងឃ្លាំងប្រាក់ ហើយនិងន៎ែ កសិកម្ម។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំនឹងចូលទៅដល់ប្រធានបទមួយផ្សេងទៀត យើងបានពិភាក្សាអំពីក្រសួងនានា ហើយអំពីការងារត្រូវបានបែងចែកនៅក្នុងក្រសួងមន្ទីរនោះ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងករណី ស-២១ ដែលនិយាយពីទំនាក់ទំនងជាមួយក្រសួងផ្សេងៗ តើលោកអាចពន្យល់បានទេ ថាតើមានទំនាក់ទំនងហ្នឹង អ្វីខ្លះ? ថាតើ ស-២១ ផ្សារភ្ជាប់ទំនាកទំនងទៅនឹងក្រសួងផ្សេងៗទៀត ដោយវិធីណា?

**ឆ៖** អរគុណ។ ស-២១ គ្មានទំនាក់ទំនងទៅនឹងក្រសួងផ្សេងទាំងអស់ ក្រៅតែអំពីទៅខាងលើជាមួយ សុន សេន ជាមួយ បងនួន-- នួន ជា នេះ ហើយនិងជាមួយ មិត្តប៉ង់ ដែលជាអ្នកនាំពាក្យរបស់បងប៉ុល។

**ស៖** នៅក្នុងពេលដែលលោកធ្វើការនៅ ស-២១ ថាតើមានមនុស្សមកពីក្រសួងផ្សេងៗ ដែល

ត្រូវបានគេចាប់ខ្លួន ហើយបញ្ជូនមកសម្លាប់ ឲ្យគេសម្លាប់នៅស-២១ ដែរឬទេ?

**ឆ៖** អរគុណ។ មនុស្សមកក្រសួងផ្សេងៗ បញ្ជូនមកឲ្យស-២១ សួរចម្លើយហើយ កម្ទេចមានៗច្រើន។

[១០:១៩:១០]

**ស៖** ចាតើលោកអាចបញ្ជាក់ឈ្មោះក្រសួងទាំងអស់នោះ ឬក៏ជាទីកន្លែងដែលគេចាប់មនុស្ស ហើយបញ្ជូនមកស-២១ នោះ មានក្រសួងប៉ុន្មាន? កន្លែងណាខ្លះ?

**ឆ៖** ខ្ញុំមិនអាចចូលជាក់ស្តែងទេ។ គ្រាន់តែដឹងរឿងពីរ គាត់-- រឿងទីមួយគឺចាប់ វន វ៉េត ហ្នឹងច្បាស់។ ចាប់នៅមន្ទីរមជ្ឈិមតែម្តង អ្នកចាប់គឺពួក មិត្តលីន ហើយអ្នកបញ្ជាការចាប់ចងនុំង ពេលនុំងបញ្ជាផ្ទាល់ដោយការចាប់ គឺ តាម៉ុក។ នេះ ព្រឹត្តិការណ៍ទីមួយ គេចាប់ហើយ គេបញ្ជូនមកឲ្យខ្ញុំ ល្ងាចរៀបជិត ជិតព្រលប់ហើយ។ ឯចំណែកមួយទៀត គឺខ្ញុំចេញទៅចាប់ តាមបញ្ជា បងនួន នេះ ខ្ញុំទៅទទួលយកប្រពន្ធ ចេង អន ហើយនិងន៉ែប្រពន្ធ វន វ៉េត។ កន្លែងទៅទទួលហ្នឹង គឺពុទ្ធិកវិទ្យាល័យព្រះសុរាម្រិតនេះពីរដែលស-២១ ចេញទៅចាប់។

**ស៖** ខ្ញុំនឹងត្រឡប់មកប្រភេទអ្នកទោសដែលគេបញ្ជូនទៅស-២១។ ប៉ុន្តែលោកបានបញ្ជាក់ថាការចាប់ខ្លួន វន វ៉េត នេះដើម្បីឲ្យច្បាស់ គឺគាត់ធ្លាប់ធ្វើជាមេរបស់លោកនៅម-១៣ តើត្រូវដែរឬទេ?

[១០:២១:១៦]

**ឆ៖** អរគុណ។ វន វ៉េត ជាមេរបស់ខ្ញុំនៅម-១៣។ តាមពិត វាតាំងពីសម័យខ្ញុំនៅក្រុងភ្នំពេញគាត់ជាលេខាក្រុង។

**ស៖** ហើយ វន វ៉េត ក៏នៅក្នុងគណៈអចិន្ត្រៃយ៍ដែរ តើត្រូវឬទេ?

**ឆ៖** អរគុណ។ វន វ៉េត គាត់នៅក្នុងគណៈអចិន្ត្រៃយ៍។

**ស៖** ចាតើលោកចាំទេ គេចាប់ខ្លួន វន វ៉េត នៅឆ្នាំណា?

**ឆ៖** បើតាមខ្ញុំចាំ ដូចជាថ្ងៃ០២ វិច្ឆិកា ១៩៧៨។

**ស៖** តើលោកដឹងដែរឬទេ ថាតើកាលៈទេសៈដែលថា វន វ៉េត ត្រូវបានគេចាប់ខ្លួន ហើយថាតើមានហេតុការណ៍អីពាក់ព័ន្ធនឹងការចាប់ខ្លួននោះ?

**ឆ៖** ខ្ញុំមិនច្បាស់ មិនដឹងរឿងអីទេ គ្រាន់តែ មិត្តលីន គាត់ហៅឲ្យខ្ញុំចាំទទួលមនុស្សដែលគាត់ចាប់បាន។ ដល់ហើយឃើញ វន វ៉េត ហើយនិង ចេង អន មកដល់ ដឹកមួយកូនឡានតូច អាដឹកបាន

ទម្ងន់៥០០គីឡូ។

[១០:២៣:២០]

**ស៖** នៅពេលមួយ តើលោកបានសន្ទនាជាមួយ កែ ពក ទេ? នៅពេលដែលលោកបានជួបគាត់ នៅប្រទេសថៃឆ្នាំ១៩៨៨ ឬ៨៩ អំពីកាលៈទេសៈដែលថានាំឲ្យគេចាប់ខ្លួន វន វ៉េត ហើយនិងហេតុការណ៍ សភាពការណ៍នៃការចាប់ខ្លួន វន វ៉េត នោះ?

**ឆ៖** អរគុណ។ ខ្ញុំជួប កែ ពក មែន ប៉ុន្តែ កែ ពក គាត់អៀនគាត់ មិនប៊ាននិយាយពីរឿងខ្លួនគាត់រត់ចូលក្រោមគ្រែទេ។ គាត់និយាយតែអំពីរឿង តាម៉ុក ចេញទៅបញ្ជាឲ្យពួក មិត្តលីន ឲ្យចាប់។ គាត់ថា បងប៉ុល ប្រាប់គាត់ថា មិត្តកុំអាលទាន់ទៅផ្ទះ នៅចាំមើលកុនសិន។ រួចដល់គេចាប់ វន វ៉េន ហើយនិង ចេង អន រួចទៅ បាន១ បងប៉ុល ហៅគាត់ថាម៉េច មិត្តមើលឃើញកុនទេ? សប្បាយទេ? ល្អទេ? បងប៉ុល សួរអ៊ីចឹង។ នេះ វន-- អ៉ន៉ែ កែ ពក ប្រាប់ប្រាជ្ញ ប្រាប់ខ្ញុំអ៊ីចឹង។

**ស៖** ដើម្បីឲ្យច្បាស់ ថាតើ កែ ពក ហ្នឹងគាត់ជាអ្នកណា? គាត់មានតំណែងឬក៏អ្វីបាទ?

**ឆ៖** កែ ពក នេះគាត់ជាលេខាភូមិភាគឧត្តរ។ ដល់ក្រោយមកភូមិភាគនេះគេប្រែឈ្មោះទៅជាភូមិភាគកណ្តាល គាត់នៅជាលេខាភូមិភាគកណ្តាលហ្នឹង។ អង្កាល់នៅឈ្មោះជាភូមិភាគឧត្តរ គាត់ជាអនុលេខារបស់ កុយ ធួន ទេ។

**ស៖** តើលោកបានពន្យល់អំពីកាលៈទេសៈដែលថា គេធ្វើសេចក្តីសម្រេចដូចម្តេច ដើម្បីចាប់ខ្លួន វន វ៉េត នោះបាទ?

[១០:២៥:៣៤]

**ឆ៖** ខ្ញុំមិននាំអាទិ បងពក និយាយពីរឿងនុ៎ងទេ។ បងពក គាត់នាំអាទិខ្ញុំនិយាយពីរឿងថ្ងៃខែឆ្នាំដែលប៉ូលិសទៅចាប់ខ្ញុំនៅចម្ការលើ ថ្ងៃ៥ មករា ១៩៦៧ អ៉! សូមទោស អើ! ត្រូវហើយ។ ថ្ងៃ៥ មករា ឆ្នាំ១៩៦៨ គាត់នាំទៅនិយាយឯនុ៎ងវិញ។

**ស៖** ដែលលោកបានប្រាប់សហចៅក្រមស៊ើបអង្កេតអំពីប្រធានបទនេះ ខ្មែរ 00398226 អង់គ្លេស ERN 0003 បាទ 398239 ហើយភាសាបារាំង 00398242។ ទាក់ទងទៅនឹងការពិភាក្សានេះ អ្វីដែលលោកបានប្រាប់សហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី២២ តុលា ឆ្នាំ២០០៩ ថា ខ្ញុំសូមឲ្យលោកធ្វើមតិយោបល់លើចំណុចនេះ។ គេសួរថា "តើលោក ខៀវ សំផន បានឃើញការចាប់ខ្លួន វន វ៉េត ដែរឬទេ? ហើយខ្ញុំនិយាយថាអ្វីដែល កែ ពក បាននិយាយទាក់ទងទៅនឹងការចាប់ខ្លួនរបស់ តិច យូ, កង

សុផល អនុលេខាភូមិភាគឦសាន នោះ វន វ៉េត ក៏ត្រូវដែរ”។ កែ ពក បានប្រាប់ខ្ញុំថា “នៅពេលដែលយើងបានជួបនៅឆ្នាំ១៩៨៨ ឬ៨៩ នៅប្រទេសថៃ បន្ទាប់ពីមានកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ហើយ ប៉ុល ពត បានសុំឲ្យអ្នកចូលរួមនៅចាំ ហើយចាំមើលការដូចកុន។ ហើយ តាម៉ុក បានបញ្ជានៃការ ឲ្យមានការចាប់ខ្លួន វន វ៉េត ហើយនិង ចេង អន ហើយៗសួរ កែ ពក ដោយញញឹមថា តើអ្នកឯងឃើញកុនទេ?” ហើយលោកបាននិយាយថា “នៅក្នុងចំណោមគណៈអចិន្ត្រៃយ៍ដែលចូលរួមនោះ គឺហើយមាន នួន ជា, អៀង សារី, ខៀវ សំផន ក៏បាននៅទីនោះដែរ។ សំណួរចំពោះលោកគឺថា តើត្រូវដែរឬទេនូវអ្វីដែល កែ ពក ប្រាប់លោកគឺអ៊ីចឹងឬទេ?

[១០:២៨:១៣]

**ឆ៖** អរគុណ។ បើនិយាយពី បងពក គាត់ប្រាប់ខ្ញុំពីរឿងប្រជុំ ប្រហែលជាមែន អ៎! ប្រហែលជាមែនអី គឺមែនហើយ។ ក៏ប៉ុន្តែបើនិយាយអំពីខ្ញុំដែលដឹងដំណឹងមកនោះ គឺដឹងថាគាត់ចូលក្រោមគ្រែ រត់ចូលក្រោមគ្រែ គាត់ភ័យរត់ចូលក្រោមគ្រែ។ ប៉ុន្តែពេលនុ៎ងបង ពក គាត់អត់ប៉ានិយាយទេ គាត់ប៉ាននិយាយត្រឹមតែថា បងប៉ុល ឲ្យនៅរង់ចាំមើលកុន។ ហើយដល់រួចចាប់ វន វ៉េត បានៗបង ប៉ុល គាត់ទៅញញឹមនិយាយជាមួយបង ពក មែន។ ថាម៉េច មិត្តមានឃើញកុនហើយ? ដូច្នេះប៉ុណ្ណឹង។

[១០:២៩:០៣]

**ស៖** នៅពេលដែលលោកសន្ទនាជាមួយគាត់នៅប្រទេសថៃ តើលោកសួរអ្វីបន្ថែមទេ ឬក៏គាត់ជាអ្នកចាប់ផ្តើមនិយាយអំពីកាលៈទេសៈនោះនៅ-- ដែលថាហេតុការណ៍ដែលកើតឡើងជុំវិញ វន វ៉េត ការចាប់ខ្លួន វន វ៉េត នោះ?

**ឆ៖** អរគុណ។ និយាយគ្នាពេលនោះយូរដែរ ដូចជាមួយម៉ោងជាង។ ដូច្នេះអ្នកណាចាប់ផ្តើមរឿងអីមុន ខ្ញុំមិនដឹងទេ ក៏ប៉ុន្តែសំខាន់ពេលនុ៎ងបង ពក គាត់រំឭកអារឿងពេលដែលខ្មាំងដេញចាប់ខ្ញុំ។ ពេលនោះគាត់ក៏នៅធ្វើមេខ្ញុំ។ ពេលនោះគាត់រត់រួចខ្លួន ខ្ញុំនៅត្រូវខ្មាំងចាប់។ ដូច្នេះគាត់ថាថ្ងៃនុ៎ងហើយជាថ្ងៃដែលខ្មាំងផ្ទុះអាវុធដំបូងគេបំផុតទូទាំងប្រទេស។ ហ្នឹងគាត់រំឭករឿងហ្នឹងឡើង ហើយរំឭកនៅពេលហ្នឹង កុយ ធួន ក្បត់យ៉ាងម៉េច ស្អីយ៉ាងម៉េច? ប្រាប់ខ្ញុំ។ ដូច្នេះរឿងរ៉ាវយើងខ្ញុំជជែកគ្នាច្រើន មិនដឹងជារឿងអី ជារឿងអីខ្លះទេ ហើយមិនដឹងរឿងអី ដែលខ្ញុំផ្តើមគំនិតមុន រឿងអីដែលគាត់ផ្តើមគំនិតមុនទេ។

**លោក វីល្លៀម ស្មីត៖**

សូមអរគុណ--

[១០:៣០:២២]

**ប្រធានអង្គជំនុំ៖**

ដល់ពេលសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយ អនុរក្សមន្ទីរឃុំឃាំងឲ្យអញ្ជើញលោកសាក្សីទៅកាន់បន្ទប់រង់ចាំ សម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញ គាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ ឲ្យបានមុនអង្គជំនុំជម្រះចូលមកកាន់អាសនៈ។

សូមអញ្ជើញលោកមេធាវីជាតិការពារក្តី លោក អៀង សារី!

[១០:៣០:៥៥]

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន សូមអរគុណលោក លោកស្រីចៅក្រម។ ដោយសារបញ្ហាសុខភាព ជាពិសេសបញ្ហាឈឺចង្កេះឆ្អឹងខ្នង និងជើងដែលមិនអាចឲ្យលោក អៀង សារី ទ្រាំអង្គុយនៅទីនេះបាន ថ្ងៃនេះ លោកស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមផ្ទាល់នៅក្នុងសវនាការនេះ ប៉ុន្តែសុំចូលរួមសវនាការនេះ នៅបន្ទប់រង់ចាំខាងក្រោមសម្រាប់រយៈពេលមួយថ្ងៃនេះពេញតែម្តង។

អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាពិចារណា សម្រេចតាមសំណើ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ បានស្តាប់សំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលធ្វើឡើងតាមរយៈមេធាវីការពារ ក្តីរបស់គាត់ សុំលះបង់សិទ្ធិមិនចូលរួមផ្ទាល់ក្នុងកិច្ចដំណើរការសវនាការនៅក្នុងបន្ទប់សវនាការនេះ ដោយទៅបន្តការតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍ ពីបន្ទប់មួយនៅ ខាងក្រោមបន្ទប់សវនាការនេះសម្រាប់រយៈពេលពេញមួយថ្ងៃនេះ ដោយមូលហេតុសុខភាពមិនអាច អង្គុយបន្តតាមដានដោយផ្ទាល់នូវកិច្ចដំណើរការសវនាការបាន។ អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំ របស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំតាមរយៈមេធាវីរបស់គាត់ ក្នុងការលះបង់សិទ្ធិមិន ចូលរួមក្នុងតាមដានកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយទៅបន្តតាមដាន កិច្ចដំណើរកិច្ចសវនាការពីចម្ងាយពីបន្ទប់មួយស្ថិតនៅក្រោមបន្ទប់សវនាការនេះ តាមរយៈឧបករណ៍ សោតទស្សន៍ពេញមួយថ្ងៃនេះ។ តែអង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តី អៀង សារី ប្រគល់មក អង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ដែលមានមានចុះហត្ថលេខា ឬក៏

ផ្តិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ អៀង សារី ហើយនិងបង្គាប់ឲ្យផ្នែកខាងសោតទស្សន៍ត ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់ពេញមួយថ្ងៃនេះ នៅក្នុងអំឡុងពេលសវនាការ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក អៀង សារី ទៅកាន់បន្ទប់ខាងក្រោមដែល រៀបចំជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់ចុះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣២ នាទី ដល់ម៉ោង ១០:៥១ នាទី)*

[១០:៥១:២២]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីបន្តការងាររបស់ខ្លួន។

បាទ សូមអញ្ជើញ!

**លោក វីល្លៀម ស្មីត៖**

សហព្រះរាជអាជ្ញាសូមអរគុណលោកប្រធាន។

**សួរដោយលោក វីល្លៀម ស្មីត៖**

សាក្សីមុននឹងយើងសម្រាកនេះ យើងបាននិយាយអំពីក្រសួងដែលបាន-- ត្រូវបានបង្កើតឡើង នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ហើយយើងក៏បានពិភាក្សាដែរ អំពីទំនាក់ទំនងរវាងស-២១ ជាមួយក្រសួងនានា ហើយអំពីវិធីនៃការប្រាស្រ័យទាក់ទង ហើយនិងការភ្ជាប់ទំនាក់ទំនងដោយវិធី ណា។ នៅពេលដែលយើងពិនិត្យមើលបញ្ជីអ្នកទោសដែលរួមបញ្ចូល លោកបានយល់ស្របថាជា

កំណត់ត្រាត្រឹមត្រូវនៃអ្នកទោសដែលត្រូវបានឃុំខ្លួន ហើយនិងសម្លាប់នៅស-២១។ ហើយលោកបានឃើញថា មានតួលេខប្រហែលជា ៥៦០៩នាក់ ជាសមាជិកមកពីកងទ័ព។ ហើយតួលេខនេះប្រហែលជា១១៣ មកពីក្រសួងការបរទេស ហើយប្រហែលជា៤៨២មកពីក្រសួងពាណិជ្ជកម្ម។ ប្រហែល១១៦មកពីក្រសួងសង្គមកិច្ច។ ប្រហែលជា៨៤នាក់ មកពីក្រសួងឃោសនាការ ហើយនិងអប់រំ។ ប្រហែល៣២៨នាក់ មកពីអតីតយោធា ទាហានរបស់សាធារណរដ្ឋ ហើយនិងរណសិរ្សរួបរួមជាតិកម្ពុជា ហើយបន្ទាប់មកទៀតមាន៣២៨, ២០៩, ហើយគឺថានៅក្នុងនោះ គឺមានដាក់មុខងារដែលអ្នកទាំងនោះកាន់កាប់មុននឹងគេចាប់បញ្ជូនមកស-២១ ផងដែរ។

**ស៖** សំណួររបស់ខ្ញុំ ដែលចង់សួរទៅលោកនោះ គឺថាតើនៅពេលដែលគេផ្តល់ជាសេចក្តីសារភាពនៅស-២១ ហើយឆ្លើយដាក់មនុស្សផ្សេងៗទៀតនៅក្នុងចម្លើយសារភាពនោះ ថាតើពីការរៀបចំ ឬក៏ឆ្លើយដាក់មនុស្សនៅក្នុងមន្ទីរដែលគេធ្វើការនោះ? តើព័ត៌មាននោះ យើងយកមកវិភាគ ហើយយើងបញ្ជូនយ៉ាងដូចម្តេច? ហើយតើអ្នកណាខ្លះជាអ្នកវិភាគមានតែលោក ឬក៏បុគ្គលិកនៅស-២១ ហ្នឹងធ្វើដូចម្តេចដែរ? ថាតើព័ត៌មាននៅក្នុងចម្លើយសារភាពហ្នឹងគេប្រើដើម្បីអ្វី?

[១០:៥៥:០៨]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ តួនាទីរបស់ស-២១ គឺធ្វើម៉េចយកឲ្យបានចម្លើយសារភាព ហើយនៅខាងចុងចម្លើយសារភាពហ្នឹងតែងមានបញ្ជីឈ្មោះ ដែលជនរងគ្រោះត្រូវជាប់ឃុំនុំងឆ្លើយដាក់។ ឯចំណែកវិធីធ្វើម៉េចសួរឲ្យចេញ ហើយធ្វើម៉េចចម្លើយហ្នឹងកុំឲ្យរាលដាល អានេះជារឿង ជាបញ្ហាមួយដោយឡែក។ ដល់យើងខ្ញុំបានចម្លើយហើយ យើងខ្ញុំរាយការណ៍ឯកសារទាំងមូលហ្នឹងទៅមេ។ ចប់ភារកិច្ចរបស់យើងហើយ ឯចំណែកចាត់ចែងយ៉ាងម៉េច អាហ្នឹងស្រេចនឹងខាងលើទេជាអ្នកចាត់ចែង សម្រេចយកប៉ុន្មានអីប៉ុន្មាន អាហ្នឹងក៏ខាងលើចាត់ចែង។ ឯកសារអំមិញ ថ្ងៃ១៦ ខែ០៩ ១៩៧៦ ជាឧទាហរណ៍មួយ ស-២១ បញ្ជូនបញ្ជីទៅមួយចំនួន ដល់ទៅមេគេប្រជុំក្នុងគណៈសេនាធិការបើកទូលាយ គេយកតែ ២៩នាក់ អាហ្នឹងជាបញ្ហាមួយជាក់ស្តែង ឧទាហរណ៍មួយជាក់ស្តែង។ ខាងលើចាត់ចែង។

**ស៖** ដូច្នេះ បើយើងយល់ពីដំណើរការនោះឲ្យបានច្បាស់នោះ គឺឧទាហរណ៍ ប្រសិនបើអ្នកជាប់ឃុំម្នាក់បានផ្តល់ចម្លើយសារភាព ហើយនៅក្នុងចម្លើយសារភាពនោះ គាត់បានធ្វើបញ្ជីមនុស្សមួយចំនួនដែលគាត់ឆ្លើយដាក់ថាជាខ្មាំង ឬក៏មនុស្សប្រភេទណា ហើយលោកបានទទួលចម្លើយសារភាព

នេះ។ តើលោកបង្កើតបញ្ជីឈ្មោះមនុស្សស្រង់ចេញពីចម្លើយសារភាពហ្នឹងបញ្ជូនទៅលើ ឬក៏គ្រាន់តែលោកធ្វើចំណារផ្ទាល់ដៃលើចម្លើយសារភាព ហើយបញ្ជូនទៅលើ?

[១០:៥៧:២០]

**ឆ៖** ទីមួយ ចម្លើយសារភាព។ ទីពីរ ឈ្មោះមនុស្សដែលគេឆ្លើយដាក់។ ឈ្មោះមនុស្សដែលគេឆ្លើយដាក់ ផ្ទាល់ខ្លួនខ្ញុំ ខ្ញុំអត់ដែលប៉ះពាល់ទេ។ ក៏ប៉ុន្តែខ្លឹមសារនៃចម្លើយសារភាព នៅក្នុងសម័យកាលសុន សុន គាត់ណែនាំឲ្យខ្ញុំសរសេរសង្ខេបខ្លី ជាពាក្យពីរបីមាត់ជាដំបូង ដើម្បីឲ្យគាត់យល់ដល់ជម្រៅឯកសារនុំង ស្រួលគាត់ធ្វើការ។ នេះបញ្ហាហ្នឹងវាមានប៉ុណ្ណឹង។ ទីមួយខ្លឹមសារនៃសេចក្ដីសារភាព។ ទីពីរ បញ្ជីនៃមនុស្សដែលគេឆ្លើយដាក់។ ខ្ញុំសូមសរុបប៉ុណ្ណេះ។

**ស៖** សូមអរគុណ។ ដើម្បីឲ្យច្បាស់ តើលោកនិយាយថាលោកមិនបានធ្វើបញ្ជីអ្នកដែលគេឆ្លើយដាក់ទេ? តើអ្នកផ្សេងជាអ្នកស្រង់យកឈ្មោះចេញពីបញ្ជីដែលគេឆ្លើយដាក់ហ្នឹងឬទេ?

**ឆ៖** បញ្ជីនេះ គឺអ្នកឆ្លើយជាអ្នកធ្វើ ហើយគេផ្ទួផ្ទាត់គ្នាកុំឲ្យខ្វះជាមួយអ្នកសួរ។ គឺខាងក្រោមទេជាអ្នកដោះស្រាយ។

**ស៖** ចម្លើយសារភាព ហើយនិងបញ្ជី ទាំងពីរហ្នឹងបញ្ជូនទៅថ្នាក់លើរបស់លោកដែរឬទេ?

**ឆ៖** អរគុណ។ នេះជាទិសដៅតែមួយគត់ ដែលស-២១ ធ្វើការបានចម្លើយសារភាពបញ្ជូនទៅខាងលើ។ ហើយដាច់ខាតគឺបញ្ជូនទៅខាងលើ។

[១០:៥៩:៣៧]

**លោក វីណ្ឌៀម ស្មីត៖**

សូមអរគុណ។ ប្រហែលជាខ្ញុំអាចបង្ហាញឯកសារទៅលោក D43/IV ឧបសម្ព័ន្ធលេខ២៦ ជាក្របនៃចម្លើយសារភាព។ ខ្ញុំមានឯកសារលើក្រដាសដើម្បីជូនសាក្សី ហើយខ្ញុំសូមអនុញ្ញាតតុលាការដាក់បង្ហាញនៅលើអេក្រង់ផងដែរបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការយកឯកសារពីតំណាងសហព្រះរាជអាជ្ញាជូនសាក្សី!

**សួរដោយលោក វីណ្ឌៀម ស្មីត៖**

**ស៖** អ៊ីចឹង ឯកសារដាក់បង្ហាញនៅលើអេក្រង់។ លោកសាក្សីសូមពិនិត្យមើលឯកសារនេះ តើ

ឯកសារនេះលោកធ្លាប់បានឃើញកាលពីមុន បានន័យថា ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** មួយ ចេញពីស-២១ វាអត់មានអក្សរជាពណ៌ក្រហម និងអក្សរជាខាងក្រោមនោះទេ។ វាមានតែ-- ចេញពីស-២១ វាមានតែកំណត់ហេតុសង្ខេបរបស់ ម៉ុក សំអុល ហៅ ហុង ប្រធានមន្ទីរពេទ្យកម្ចាត់ជំងឺគ្រុនចាញ់។ វាមានតែប៉ុណ្ណឹង។ អក្សរពីរបីតួនេះ មិនមែនជារបស់ស-២១ ទេ។ សរុបមកវិញ ឯកសារនេះចេញមកពីស-២១ តែមានចំណារថែម។

[១១:០១:៤៥]

**ស៖** តើលោកបានឃើញឯកសារនេះដែរទេកាលពីមុន?

**ឆ៖** អរគុណ។ ឯកសារនេះ ខ្ញុំបានឃើញ ហើយបានពន្យល់អំពីចំណារថ្មីថែម។

**ស៖** សូមលោកអានចំណារផ្ទាល់ដៃ ដែលសរសេរនៅក្នុងប្រអប់ពណ៌ក្រហមបាទ។

**ឆ៖** ខ្ញុំសូមអានដូចតទៅ៖ "ខាងសង្គមកិច្ច ដោះស្រាយអស់ហើយ"។

**ស៖** សូមអរគុណ។ ឯកសារមួយនេះ និយាយថា នៅក្នុងគោលបំណងនោះគឺថា ចម្លើយសារភាពរបស់ ម៉ុក សំអុល ហៅ ហុង ជាប្រធានមន្ទីរពេទ្យកម្ចាត់ជំងឺគ្រុនចាញ់បាទ។ តើត្រូវដែរឬទេ?

**ឆ៖** អរគុណ។ ត្រឹមត្រូវហើយ។

**ស៖** រីឯចំណារផ្ទាល់ដៃនៅខាងក្រោមទំព័រ សូមលោកអានចំណារនេះផងបាទ។

**ឆ៖** អរគុណ។ "ជូនសមមិត្ត ចាន់ ហើយ ថ្ងៃ២៨ ខែ០២ ១៩៧៨"។

**ស៖** តើលោកស្គាល់ទេអក្សរផ្ទាល់ដៃនេះ ជាអក្សររបស់អ្នកណា? នៅក្នុងខាងឆ្វេងដៃនេះ ដែលទាក់ទងថាជូនសមមិត្ត ចាន់ ហើយ ហ្នឹង អ្នកណាជាអ្នកសរសេរអក្សរហ្នឹងបាទ?

[១១:០៤:២៨]

**ឆ៖** អរគុណ។ ចំណារនៅខាងក្រោម ហើយខាងឆ្វេងដៃ គឺជាចំណាររបស់ បងនួន គឺ នួន ជា។

**ស៖** ហេតុអ្វីក៏លោកស្គាល់អ៊ីចឹង?

**ឆ៖** ខ្ញុំធ្លាប់ឃើញអក្សរគាត់។ គាត់សរសេរសំបុត្រតិចណាស់ទៅខ្ញុំ តែបីបួនច្បាប់ប៉ុន្នុំងទេ ក៏ប៉ុន្តែអក្សរគាត់គឺអ៊ីចឹង។

**ស៖** តើលោកស្គាល់ទេ អ្នកណាជាសមមិត្ត ចាន់?

**ឆ៖** អរគុណ។ ចាន់ នេះ ឈ្មោះដើម សេង ហុង។ លេខាតំបន់ប៉ុន្មានទេ? ខាងភូមិភាគបូព៌ា។

**ស៖** សូមអរគុណ។ រីឯចំណារផ្ទាល់ដៃនៅក្នុងប្រអប់ពណ៌ក្រហមខាងលើឆ្វេងដៃ តើលោកស្គាល់ទេ ជាចំណាររបស់អ្នកណា?

**ឆ៖** អរគុណ។ ចំណារនៅលើប្រអប់ខាងលើ នៅក្នុងប្រអប់ ហើយនៅផ្នែកខាងលើខាងឆ្វេងនេះក៏ជាចំណាររបស់ បងនួន។

**ស៖** គឺថាមានការបកប្រែល្អៀងតិចនៅក្នុងចំណារនេះ។ នៅក្នុងអង់គ្លេសនិយាយថា គឺថាសង្គមកិច្ចដើម្បីដោះស្រាយ ប៉ុន្តែការពន្យល់របស់លោកនោះ គឺថាខាងសង្គមកិច្ចដោះស្រាយហើយ។ បានន័យថា-- ដូច្នេះខ្ញុំមិនទាន់ច្បាស់ថា តើចំណារផ្ទាល់ដៃហ្នឹងមានអត្ថន័យយ៉ាងដូចម្តេចឲ្យច្បាស់បាទ?

[១១:០៧:០៥]

**ឆ៖** អរគុណ។ ការបកប្រែពីលើកមុនជាអង់គ្លេស ដែលលោកធ្លាប់ឮមល្អៀងពីន័យដើម។ ន័យដើមគឺ "គេដោះស្រាយរួចហើយ" ដែលអង់គ្លេសហៅថា *"អលរីឌី"*។

**ស៖** បាទ ពេលដែលលោកនិយាយថា បញ្ហាហ្នឹងដោះស្រាយរួចហើយហ្នឹង គឺជាមួយផ្នែកខាងសង្គមកិច្ចឬ? បាទ តើដោះស្រាយជាមួយអ្នកណា? ដោះស្រាយរឿងអ្វី?

**ឆ៖** ដោះស្រាយនេះ គឺដោះស្រាយចាប់ខ្លាំង ដែលមាននៅក្នុងឯកសារនេះ។ តែផ្នែក ដែល ម៉ុក សំអុល ហៅ ហុង ឆ្លើយដាក់ខាងសង្គមកិច្ច។

**ស៖** សំណួរខ្ញុំបន្ទាប់ទៅទៀត ថាតើដឹងថាបញ្ហាទាំងអស់ងហ្នឹង ត្រូវដោះស្រាយ។ ជាពិសេសនៅក្នុងផ្នែកហ្នឹង ហើយបើសិនជាបញ្ជូនបញ្ជីហ្នឹងទៅមុខទៀត តើអ្នកដែលនៅក្នុងបញ្ជីហ្នឹង គេដោះស្រាយដូចម្តេច? ជាពិសេស នៅក្នុងខាងសង្គមកិច្ចនុំងថា តើលោកបានដឹងវិធីដែលគេដោះស្រាយហ្នឹងទេថា តើអ្នកនៅក្នុងៗបញ្ជីហ្នឹង ជួបវាសនាយ៉ាងដូចម្តេចក្រោយមក?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ ដោយមានការជំទាស់តវ៉ាពីមេធាវីអន្តរជាតិការពារក្តីលោក នួន ជា។

[១១:០៩:១៥]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ តាមដែលខ្ញុំចាំនោះ គឺថាសាក្សីនោះ គាត់បានបញ្ជាក់ថា នៅពេល

នោះ គាត់មិនដែលបានឃើញចំណារនេះទេ។ ហើយសំណួរនេះ គឺហាក់ដូចជានាំឲ្យសាក្សីគាត់និយាយស្អានបែបនោះឯង។ បើមិនដូច្នេះទេ គឺថាគាត់នឹងមិនបានឃើញឯកសារនេះទេ គាត់មិនអាចឆ្លើយបានទេ។ អ៊ីចឹងនេះជា-- ខ្ញុំសូមជំទាស់បែបនេះ។

**លោក វីណ្ឌៀម ស្មីត៖**

សាក្សីកាត់ថា គាត់បានឃើញឯកសារ ហើយបានឃើញចំណារផ្ទាល់ដៃ ហើយចំណារខ្លះធ្វើខាងក្រៅ ប៉ុន្តែមិនច្បាស់បន្តិច ក៏ប៉ុន្តែខ្ញុំនឹងសួរជាមួយនឹងគាត់។ ប៉ុន្តែគាត់ឆ្លើយថា គាត់បានឃើញចំណារទាំងអស់ហ្នឹង ថាតើ ខ្ញុំបានសួរថា ចំណារហ្នឹងមានអត្ថន័យដូចម្តេច? គាត់អានហើយ គាត់បានដឹងពីរឿងទាំងអស់ហ្នឹង គាត់ពន្យល់រួចមកហើយ។

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំសុំឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញា តាមអ្វីខ្ញុំចាំគឺថា-- យើងនឹងអាចបង្ហាញគាត់នៅពេលក្រោយ គាត់ថាគាត់បានគាត់បានឃើញនៅពេលដំណាក់កាលស៊ើបអង្កេតទេ នៅក្នុងរឿងក្តី០០២ទេ ឯកសារនេះមិនមែនពីមុនទេ។

**លោក វីណ្ឌៀម ស្មីត៖**

ខ្ញុំមិនចាំថាសាក្សីនិយាយអ៊ីចឹងទេ អ៊ីចឹងសូមលោកប្រធាន និងលោកចៅក្រមពិនិត្យ បើសិនជាគាត់និយាយបែបនោះមែន ដូចមេធាវីថានោះបាទ។

[១១:១១:០៩]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់របស់មេធាវីអន្តរជាតិការពារក្តីឲ្យ នួន ជា គ្មានប្រសិទ្ធភាព។ តំណាងសហព្រះរាជអាជ្ញាអាចបន្ត បញ្ជាក់សំណួរនេះសាជាថ្មី ដើម្បីឲ្យសាក្សីឆ្លើយនូវសំណួរនេះ ប្រសិនបើសាក្សីអាចភ្លេចនូវសំណួរដែលតំណាងសហព្រះរាជអាជ្ញាបានសួរ។

**លោក វីណ្ឌៀម ស្មីត៖**

សូមអរគុណលោកប្រធាន។

**សួរដោយ លោក វីណ្ឌៀម ស្មីត៖**

**ស៖** ពិនិត្យមើលចំណារផ្ទាល់ដៃនេះ គឺថា បញ្ហាត្រូវបានដោះស្រាយហើយនៅក្រសួងខាងសង្គមកិច្ចនេះ។ តើលោកយល់ដូចម្តេចកាលណាគេសរសេរពាក្យថា "បញ្ហាដោះស្រាយ" ហើយ កាល

ណាមានបញ្ជីមនុស្សដែលគេឆ្លើយដាក់ចេញមកពីស-២១ ហើយគេមានចំណារបែបនេះ។ ហើយមានអត្ថន័យដូចម្តេច?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ចំណារនេះគឺចំណារអ្នកសម្រេច។ អ្នកសម្រេចនេះ សម្រេចឲ្យគេដោះស្រាយខាងសង្គមកិច្ចរួចហើយ។ បានន័យថា បានសម្រេចឲ្យគេចាប់ប៉ុន្មាននាក់? ស្អីប៉ុន្មាននាក់? គឺអ្នកសម្រេចជាអ្នកចារ។ ហើយអ្នកសម្រេចហ្នឹង គឺខ្ញុំសូមបញ្ជាក់ម្តងទៀត គឺ បងនួន ខ្ញុំហ្នឹងតែម្តង។

**ស៖** នៅពេលដែលនិយាយថាបញ្ហានឹងត្រូវដោះស្រាយនៅខាងសង្គមកិច្ច ចំពោះការយល់ដឹងរបស់លោក ពាក្យថា "ដោះស្រាយ" នោះមានអត្ថន័យដូចម្តេចកាលណោះ?

**ឆ៖** អរគុណហើយដែលបានបញ្ជាក់បញ្ហានេះម្តងទៀត។ ពាក្យ "ដោះស្រាយ" នេះ បើមុនឆ្នាំ ១៩៧៥ គឺមន្ទីរ១៣ ត្រូវយកមនុស្សទៅកម្ទេច។ ឯចំណែក "ដោះស្រាយ" លើកនេះនៅក្នុងឯកសារនេះគឺអចិន្ត្រៃយ៍សម្រេចឲ្យចាប់ប៉ុន្មាននាក់ គឺបានសម្រេច ហើយបញ្ជាឲ្យគេទៅចាប់រួចអស់ហើយ។ នេះជាក់ស្តែងក្នុងករណីនេះ វាមានន័យអ៊ីចឹង។

[១១:១៣:៥៧]

**ស៖** សូមអរគុណ។ តាមអ្វីដែលលោកដឹងគឺ គណៈអចិន្ត្រៃយ៍គឺដោះស្រាយបញ្ហាហើយជាមួយប្រធាន ឬក៏ប្រធាននៃក្រសួងនីមួយៗហ្នឹង តើអ៊ីចឹងដែរឬទេ?

**ឆ៖** អរគុណ។ ដោះស្រាយតាមនុ៎ងអ៊ីចឹងមែន។

**ស៖** តើលោកអាចពន្យល់តុលាការឲ្យបានពិស្តារជាងនេះបន្តិចបានទេ?

**ឆ៖** អរគុណ។ កាលណាអានចម្លើយនេះហើយ បងនួន គាត់មានមតិហើយ គាត់គិត គាត់សម្រេចហើយ តើចម្លើយឆ្លើយដាក់នេះប៉ុន្មាននាក់? ត្រូវចាប់អ្នកណាខ្លះ? ដូច្នេះ គាត់បញ្ជាទៅឲ្យគេចាប់។ ដូច្នេះគាត់បញ្ជារួចអស់ហើយ សព្វគ្រប់អស់ហើយ។ ហើយប្រហែលជាអាចគេបញ្ជារួច-- គេដោះស្រាយ គេចាប់ចងរួចអស់ហើយ បានៗគេរាយការណ៍ជូនគាត់ គាត់ដាក់ចារនៅហ្នឹង ឬក៏គាត់ក៏គ្រាត់តែបញ្ជារួចហើយ ធម្មតាទេតែគាត់បញ្ជាហើយ គេត្រូវតែធ្វើ។ ដូច្នេះ "ដោះស្រាយហើយ"ហ្នឹងគឺបានន័យអ៊ីចឹង។ បានន័យថា សម្រេចហើយ បញ្ជាទៅឲ្យគេហើយ ឬក៏បទបញ្ជាអនុវត្តហើយក៏សឹងតែថាបានទៀត។

[១១:១៥:៤៥]

**លោក វីណ្សៀម ស្មីត៖**

សូមអរគុណ។ ខ្ញុំជូនឯកសារមួយទៀត D43/IV ឧបសម្ព័ន្ធ៤១។ ខ្ញុំមានឯកសារលើក្រដាសជូនលោកមើល។ ហើយសូមអនុញ្ញាតឱ្យមន្ត្រីតុលាការជូនឯកសារទៅសាក្សី។

**សួរដោយលោក វីណ្សៀម ស្មីត៖**

**ស៖** លោកសាក្សីសូមលោកមើលឯកសារនេះ ហើយបញ្ជាក់ថា តើលោកបានឃើញឯកសារហ្នឹងពីមុន ឬបានឯកសារហ្នឹងពីមុនដែរឬទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ខ្ញុំសូមបញ្ជាក់ថា ឯកសារនេះពិតជាឯកសាររបស់ស-២១ ដែលបញ្ជូនទៅខាងលើ។ បញ្ជូននៅថ្ងៃទី២១ ខែកុម្ភៈ ១៩៧៨។ ហើយឯកសារនេះមានអក្សរខ្ញុំជាចំណារជូនទៅខាងលើផង ដែលខ្ញុំសរសេរថា "បងជាទីគោរព! ហើយដល់ចុងបញ្ចប់ខ្ញុំសរសេរដោយគោរព ហើយហត្ថលេខាឌុច"។ របស់ដែលចេញទៅពីស-២១ ជូនអង្គការ ជូនខាងលើ គឺប៉ុណ្ណឹង។ ហើយដល់ទៅខាងលើជាអ្នកចារ ជាអ្នកសម្រេច ជាអ្នកពិចារណា។ ដូច្នេះ ខ្ញុំសូមអធិប្បាយថា ច្បាស់ជាឯកសាររបស់ស-២១ ដែលមានចំណាររបស់ខ្ញុំ។

[១១:១៨:០២]

**ស៖** សូមលោកអានដោយសង្ខេប អានន្ទូវចំណារផ្ទាល់ដៃរបស់លោក ថាតើលោកអាចបញ្ជាក់តុលាការផង ថាតើនេះជាចម្លើយសារភាពរបស់បុគ្គលណា? ហើយគាត់មានតំណែងជាអ្វី អ្នកដែលសារភាពនោះ?

**ឆ៖** អរគុណ។ ចម្លើយសារភាពនេះជាចម្លើយរបស់ មាឃ ទូច ហៅ កែម។ កាលមុនគាត់ធ្វើជាទូតរបស់កម្ពុជាប្រជាធិបតេយ្យប្រចាំនៅឡាវ។ ហើយខ្ញុំសូមអានចំណារខ្ញុំដែលសរសេរជូនទៅខាងលើ៖

"បងជាទីគោរព! សកម្មភាពវានៅលាវមានពីរ។ ១) ជាមួយចក្រពត្តិ វាទាក់ទងអង្គការហាស់.សេ.អ៊ា បានជួប អ៊ិន តាំ ដោះស្រាយដកអាណិកជនខ្មែរនៅឡាវទៅអប់រំឱ្យដាច់ខាត ប្រឆាំងបដិវត្តន៍នៅថៃ។ ហាស់.សេ.អ៊ា ជាផ្នែកមួយនៃអង្គការសហប្រជាជាតិ។ ហាស់.សេ.អ៊ែ នេះហៅពេញសូមទោស! ហាស់.សេ.អ៊ា ហៅពេញឈ្មោះ គឺស្នងការដ្ឋានជាន់ខ្ពស់ផ្នែកភៀសខ្លួន។ ២) ជាមួយយួនវាធ្វើការងារជាប់ជាមួយទូតយួន ឈ្មោះ ឌិញ យូលៀម និងរដ្ឋមន្ត្រីការបរទេសឡាវឈ្មោះ ភូន

ស៊ីផាសឹត ក្នុងយុទ្ធសាស្ត្រសហព័ន្ធឥណ្ឌូចិន។ យួនក៏ត្រូវការអាណិកជនខ្មែរ នៅឡាវប្រើការ។ ដោយគោរព ឌុច ២១ កុម្ភៈ ១៩៧៨។ សកម្មភាពវានៅឡាវ វាសរសេរពីទំព័រ៣៧ តទៅ"។ នេះជាសំណេររបស់ខ្ញុំជូនទៅខាងលើ។

**ស៖** សូមអរគុណ។ ហើយលោកមើលឯកសារនៅក្នុងខាងលើ ខាងឆ្វេងដៃ នៅក្នុងប្រអប់តូចពណ៌ក្រហម។ បាទតើចំណារនោះមានខ្លឹមសារដូចម្ដេច? សូមលោកអានបានទេ?

**ឆ៖** អរគុណ។ ចំណារនេះអានដូចតទៅ៖ "សមមិត្ត វ៉ាន់"។

[១១:២១:០៩]

**ស៖** តើលោកដឹងទេថា អ្នកណាជាអ្នកធ្វើចំណារផ្ទាល់ដៃដែលលោកអានអម្បាញ់មិញនេះនៅខាងលើ ហើយឆ្វេងដៃនោះ?

**ឆ៖** អរគុណ។ ចំណារនេះ ក៏នៅតែជាចំណារ បងនួន របស់ខ្ញុំដដែល។

**ស៖** ហេតុអ្វីបានជាលោកជឿជាក់អំពីរឿងនេះបែបនេះនោះ?

**ឆ៖** បញ្ហានេះ គឺមានដូចតទៅ៖ អក្សរ បងនួន ខ្ញុំធ្លាប់ឃើញ អក្សរនេះ គឺអក្សរទ្រនុំង។ ក៏ប៉ុន្តែទីពីរ ថ្ងៃខែដែលខ្ញុំសរសេរទៅជូនគាត់ ថ្ងៃ២១ ខែ២ ៧៨។ ដូច្នេះ វាក្រោយៗថ្ងៃ១៥ សីហា ១៩៧៥ ដែលសុន សេន ទៅនៅអ្នកលឿង។ ហើយទីបី មានតែ បងនួន ទេ បានហ៊ានហៅ បងវ៉ាន់ ថាសមមិត្ត វ៉ាន់។ ឯចំណែក បងខៀវ បើគាត់សរសេរទៅវិញ គឺគាត់សរសេរ បងវ៉ាន់។ សូមបញ្ចប់ប៉ុណ្ណេះ។

**ស៖** សូមអរគុណ។ តើលោកដឹងទេ ថាគោលបំណងនៃចំណារនៃខ្លី មានគោលបំណងដូចម្ដេចដែរទៅលើឯកសារនេះបាទ?

**លោក ម៉ៃខល កាណាវាស៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយនឹងសំណួរ។

បាទ សូមអញ្ជើញលោកមេធាវី!

[១១:២៣:១៩]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម សូមជម្រាបសួរភាគីទាំងអស់។ ខ្ញុំចង់

រំពឹកថា ការសួរសំណួរនេះដូចជាការឲ្យសាក្សីសន្និដ្ឋានថា តើអាហ្នឹងចំណាររបស់អ្នកណា? ដើម្បីអ្វី? ដូច្នេះ គាត់ៗមិនស្ថិតនៅក្នុងស្ថានភាពត្រូវឆ្លើយទេ លើកលែងតែគាត់មានការសន្ទនាជាមួយអ្នកដែលធ្វើចំណារហ្នឹង។ បើមិនដូច្នោះទេ គាត់មិនអាចពន្យល់បានទេ បើសិនឲ្យគាត់ពន្យល់ថាអ្វី? អ្នកណាជាអ្នកចារនោះ ហើយដូច្នេះគោលបំណងនៅពីខាងក្រោយនោះ គឺថាមិនសមស្របទេ បើឲ្យសាក្សីហៅ ដោយស្មានបែបនេះនោះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីអន្តរជាតិការពារក្តី នួន ជា!

[១១:២៤:១២]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ដូច្នេះខ្ញុំស្របទៅតាមមេធាវីការពារក្តីលោក អៀង សារី។ លោកសហព្រះរាជអាជ្ញាអាន-- សួរថាតើត្រូវដែរឬទេ? សាក្សីបានឃើញឯកសារនេះពីមុននោះ ប៉ុន្តែសំណួរនោះត្រូវតែឲ្យជាក់លាក់ជាងនេះ។

ខ្ញុំគិតថានៅពេលដែលបង្ហាញឯកសារហើយ ដូច្នេះគាត់ត្រូវសួរ ថាតើគាត់បានឃើញដោយមានចំណារហ្នឹងរួចទៅហើយ។ ដូច្នេះគាត់បានឃើញ ដូច្នេះធ្វើឲ្យយើងមិនច្បាស់លាស់នៅក្នុងករណីនេះថា យើងនៅមិនច្បាស់ថា តើសាក្សីបានឃើញចំណារហ្នឹង ទាំងអស់ហ្នឹងនៅពេលនោះ ឬក៏ឃើញពេលក្រោយមកទេ? ឬក៏គាត់បានឃើញនៅក្នុងរឿងក្តី០០១ ទេ។ នេះហើយជាចម្ងល់។ មិនដឹងថាគាត់បានឃើញនៅក្នុងដំណាក់កាលចៅក្រមស៊ើបអង្កេតដែរឬទេ?

ដូច្នេះយើងគប្បីតែដឹងរឿងនេះ មុនពេលដែលសហព្រះរាជអាជ្ញាបង្ហាញឯកសារឲ្យសាក្សីគាត់ស្មាននោះ។ បាទ ដូច្នេះហើយយើងជំទាស់ជាដាច់ខាតមិនឲ្យសាក្សីរូបនេះ ធ្វើការស្មានទៅលើអ្វីដែលសហព្រះរាជអាជ្ញាបានសួរនោះទេ។

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។

ខ្ញុំមិនអាចឈប់សំណួរនេះទេ លើកលែងតែសាក្សីគាត់មានជំហរមួយអាចនឹងឆ្លើយបាន។ លោកចៅក្រមដឹងហើយ សាក្សីគាត់ពាក់ព័ន្ធក្នុងការធ្វើចំណារអស់រយៈពេលជាច្រើនឆ្នាំ ហើយគាត់មានទំនាក់ទំនងយ៉ាងយូរអង្វែងជាមួយ នួន ជា គឺជាអ្នកដែលគាត់បានឆ្លើយថា ជាអ្នកធ្វើចំណារខាងលើ

នេះ។ ដូច្នេះសំណួរនេះ គឺថាបញ្ហានេះគឺត្រូវតែលើកឡើង។ ដូច្នេះខ្ញុំគ្រាន់តែសួរគាត់ដើម្បីឲ្យឆ្លើយភ្លាមៗតែម្តងថា ហេតុអ្វីបានជាមានឈ្មោះអ្នកដទៃនៅលើនេះ ហើយជាចំណាររបស់ណា? ហើយគាត់មានតួនាទីមួយ ជំហរមួយអាចនឹងដឹង យល់ដឹងបាន។ ហើយថាតើចំណារនេះ ដើម្បីជូនដំណឹងទៅដល់អ្នកដទៃឬក៏យ៉ាងណា? ប៉ុន្តែដោយសារតែខ្ញុំចង់ឲ្យគាត់ឆ្លើយភ្លាមៗ ហើយនេះមិនមែនជាលើកទីមួយទេដែលសាក្សីរូបនេះគាត់អាចដឹង ឬក៏អាចនឹងឆ្លើយទៅនឹងចំណារលើឯកសារបែបនេះ។

[១១:២៦:៤៣]

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន។ គេ គឺសាក្សីរូបនេះ គាត់និយាយអំពីចំណាររបស់គាត់ ដែលគាត់សរសេរចំណារជាក់លាក់ណាមួយ ហើយដើម្បីគោលបំណងអ្វី? ហើយថាតើចំណារផ្ញើទៅអ្នកណា? ជាដើម។ល។ ប៉ុន្តែនៅពេលនេះ ការផ្តល់ឱកាសឲ្យសាក្សីឃើញចំណារបែបនេះ គឺគាត់មិនមានតួនាទី ឬជំហរមួយអាចស្មានៗបែបនោះ នោះទេ។ ហើយសហព្រះរាជអាជ្ញាបានឆ្លើយថា គាត់សួរសំណួរនេះដោយស្មោះត្រង់ទេ ដោយមានមូលដ្ឋានត្រឹមត្រូវ បើមិនអ៊ីចឹងគាត់មិនសួរទេ។ នេះមិនមែនជាចម្លើយដែលគាត់ត្រូវឆ្លើយតបទៅនឹងការជំទាស់របស់ខ្ញុំទេ ដោយសារតែគាត់សួរឲ្យសាក្សីរូបនេះ ឆ្លើយស្មានៗតែប៉ុណ្ណោះ។

[១១:២៧:៣៤]

**ប្រធានអង្គជំនុំ៖**

បាទ ជំទាស់មានប្រសិទ្ធភាព។

តំណាងសហព្រះរាជអាជ្ញា-- អំ! សាក្សីមិនចាំបាច់ឆ្លើយនឹងសំណួរចុងក្រោយអម្បាញ់មិញនេះទេ។ តំណាងសហព្រះរាជអាជ្ញាអាចតាំងសំណួរថ្មីផ្សេងទៀត។

**លោក វីញ្ចៀម ស្មីត៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វីញ្ចៀម ស្មីត៖**

**ស៖** លោកសាក្សីនៅពេលលោកបានឃើញឯកសារនេះ ច្បាស់ណាស់លោកបានធ្វើចំណារនៅលើឯកសារនេះ។ នៅពេលលោកឃើញឯកសារនេះជាចុងក្រោយ តើលោកឃើញចំណារនៅលើឯកសារជាក់លាក់នេះដែលដាក់ថា សមមិត្តវ៉ាន់ នោះដែរឬទេ? នៅពេលដែលខ្ញុំនិយាយថា គឺខ្ញុំសំដៅទៅលើអំឡុងដែលលោកធ្វើការនៅស-២១ នោះ តើលោកដែលឃើញចំណារសរសេរនៅលើឯកសារនេះ

ដាក់ថា សមមិត្ត វ៉ាន់ នេះដែរឬទេ?

[១១:២៨:៤៣]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ឯកសារនេះមិនមែនជាឯកសារប្រមូលចេញពីស-២១ ទេ។ ស-២១ គ្មានចំណាររបស់ថ្នាក់លើនៅលើឯកសារចម្លើយសារភាពទេ។ ស-២១ មានរក្សាទុកមែន តែចំណាររបស់ខ្ញុំ។ ឯកសារណាដែលមានចំណាររបស់ខ្ញុំប៉ុណ្ណោះ។ ឯចំណែកឯកសារដែលប្រមូលចេញពីមន្ទីរមជ្ឈិមផ្ទាល់ ទើបបានមានចំណាររបស់ថ្នាក់។

**ស៖** សូមអរគុណលោក។ នៅពេលគេឆ្លើយដាក់អ្នកណាម្នាក់មកពីមន្ទីរណាមួយ ឬក៏ផ្នែកណាមួយ តើមន្ទីរឬផ្នែកនោះ ត្រូវជូនដំណឹងថា មនុស្សដែលគេឆ្លើយដាក់នៅក្នុងមន្ទីររបស់គាត់ហ្នឹង គឺគាត់បានដឹងអីចឹងទេ? លោកបានដឹងអីចឹងទេ?

[១១:២៩:៥៥]

**ឆ៖** ឯកសារ ស-២១ អត់សំដៅទៅក្រសួងណាទេ ជូនទៅខាងលើតែម្តង ជូនទៅអចិន្ត្រៃយ៍តែម្តង គឺអចិន្ត្រៃយ៍ជាអ្នកសម្រេច ចាប់ប៉ុន្មាន មិនចាប់ប៉ុន្មាន សុំយោបល់ខាងក្រោម ឬមិនសុំ សុំយោបល់ម្ចាស់ក្រសួងគេ ឬមិនសុំ អាហ្នឹងជាសិទ្ធិរបស់អចិន្ត្រៃយ៍។ ដូច្នេះ អត់មានរឿងអី ស-២១ ទាក់ទងទៅនឹងសាមីក្រសួងរបស់គេទេ។ ហ្នឹងខ្ញុំសូមបញ្ជាក់ប៉ុណ្ណោះ។

**ស៖** ហើយថាតើហេតុអ្វីបានជាគណៈអចិន្ត្រៃយ៍ត្រូវទាក់ទងទៅមន្ទីរ ឬផ្នែកណាមួយមកចាប់ខ្លួននោះ?

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ថាតើគាត់ដឹងដោយរបៀបណាថាគណៈអចិន្ត្រៃយ៍ត្រូវធ្វើយ៉ាងម៉េច លើកលែងតែគាត់ចូលរួម។ ដូច្នេះ សំណួរគឺសួរថា លោកដឹងដោយរបៀបណា? លោកដឹងបញ្ហានេះដោយរបៀបណា? ពីព្រោះប៉ុន្មានថ្ងៃកន្លងមកនេះ គឺថាគាត់មិនដែលចូលរួមកិច្ចប្រជុំគណៈអចិន្ត្រៃយ៍តែម្តងក៏មិនដែលផង។ សូម្បីកិច្ចប្រជុំរបស់គណៈមជ្ឈិមក៏មិនដែល។ គាត់ត្រូវឆ្លើយអ្នកណាត្រូវគេសម្លាប់ អ្នកណាគេចាប់។

នេះជាសំណួរដែលអាចត្រូវសួរ ប៉ុន្តែឧទាហរណ៍ទៅនឹងរយៈពេលកន្លងមកនេះគឺថា សហព្រះរាជអាជ្ញាមិនបានបង្ហាញនូវភស្តុតាងណាមួយ ដែលថាសាក្សីរូបនេះ ធ្លាប់បានចូលក្នុងកិច្ចប្រជុំ

គណៈអចិន្ត្រៃយ៍តែម្ដងក៏មិនដែលដែរ។ គាត់អះអាងថា អ្នកណាធ្វើអ្វី ហើយគាត់និយាយអំពីកិច្ចប្រជុំគណៈអចិន្ត្រៃយ៍។ ការស្ដាប់ចម្លើយសាក្សីពាក់ព័ន្ធទៅនឹងគោលនយោបាយ ដូចជារូបគាត់ផ្ទាល់ ដែលគាត់រស់រានមានជីវិតពីរបបនោះ ប៉ុន្តែគាត់មិនដែលបានចូលប្រជុំបែបនេះទេ។ ប៉ុន្តែ គាត់បានទទួលព័ត៌មានពីអ្នកដទៃទៀត ទាក់ទងទៅនឹងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ទៅវិញ។

[១១:៣១:៥៧]

មុននឹងឆ្លើយទៅនឹងសំណួរបែបនេះ គឺថា គួរតែសួរសំណួរដូចជាខ្ញុំអ៊ីចឹង ថាតើលោកដឹងថាមានអ្វីកើតឡើងនៅក្នុងគណៈអចិន្ត្រៃយ៍ដោយរបៀបណា? ហើយគេនិយាយគ្នាយ៉ាងម៉េចនៅក្នុងគណៈអចិន្ត្រៃយ៍? បើសិនណាជាគាត់ឆ្លើយថា គាត់ដឹងជាលើកដំបូងបែបនេះ គឺថាខ្ញុំមិននឹងជំទាស់ហើយ។ លើកលែងតែគាត់មានការចង្អុលបង្ហាញ និងបញ្ជាក់ឲ្យបានច្បាស់លាស់។ សូមអរគុណលោកប្រធាន។

**លោក វិល្លៀម ស្មីត៖**

លោកប្រធាន នេះគឺជាសំណួរដែលសហព្រះរាជអាជ្ញាសូម-- មេធាវីការពារក្ដីគាត់អាចសួរសំណួរទៅសាក្សីបែបនេះបាន។ ខ្ញុំមិនត្រូវ ថាតើត្រូវរៀបចំសំណួរ សួរសំណួរជាក់លាក់យ៉ាងម៉េចនោះទេ។ សាក្សីគ្រាន់តែនិយាយថា គណៈអចិន្ត្រៃយ៍បានទាក់ទងផ្នែក ឬក៏មន្ទីរផ្សេងៗ ពាក់ព័ន្ធទៅនឹងមនុស្សដែលគេឆ្លើយដាក់។ ឯឥឡូវនេះ ខ្ញុំគ្រាន់តែឆ្លើយ-- សួរសំណួរបែបនេះទៅកាន់សាក្សីតែប៉ុណ្ណោះ ទាក់ទងទៅនឹងបញ្ហាដែលគាត់មិនបានដឹងនោះ គាត់មានថៅហ្វាយផ្ទាល់របស់គេ មេផ្ទាល់របស់គាត់គឺជាសមាជិកគណៈអចិន្ត្រៃយ៍ សុន សេន និងនួន ជា គឺជាសមាជិកគណៈអចិន្ត្រៃយ៍។ គាត់បានពិភាក្សាយ៉ាងទៀងទាត់ជាមួយនឹងមេៗរបស់គាត់។ ហេតុដូច្នេះហើយបានសួរថាតើគាត់ដឹងដោយរបៀបណា? គាត់មានសមត្ថភាព និងលទ្ធភាពអាចដឹងបាន។ ហេតុដូច្នេះឯងទើបខ្ញុំសួរសំណួរបែបនេះ ដើម្បីជួយទៅដល់អង្គជំនុំជម្រះឲ្យមានការយល់ជ្រាបឲ្យបានច្បាស់លាស់។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៣៧:៥៤]

**ប្រធានអង្គជំនុំ៖**

លោក កាំង ហ្គេកអ៊ាវ លោកដឹងទេថាចំណារលើគ្របឯកសារដែលមានពាក្យថា "សមមិត្តវ៉ាន់" ហ្នឹង តើក្រោយពេលមានចំណារហ្នឹង គេបញ្ជូនទៅខាងណា? គេបញ្ជូនមកឲ្យលោកនៅមន្ទីរស-២១ ឬក៏បញ្ជូនទៅកន្លែងផ្សេងទៀត ដែលលោកមិនដឹងទេពីបញ្ហានេះ។

**លោក កាំង ហ្គេកអ៊ាវ៖**

អរគុណ។ ស-១២ ផលិតឯកសារដើម្បីឲ្យអចិន្ត្រៃយ៍ប្រើ។ អចិន្ត្រៃយ៍ប្រើបញ្ជូនទៅណាអាហ្នឹងស-២១ ហួសសមត្ថកិច្ចហើយ។ អត់ដឹងទេ គេអត់បញ្ជូនឯកសារនេះមកស-១២ ទេ គេបញ្ជូនទៅខាងណាស្រេចតែនឹងគេ។

[១១:៣៨:៥១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សេចក្តីជំទាស់របស់មេធាវីការពារក្តីមានប្រសិទ្ធភាព។ សាក្សីមិនចាំបាច់ឆ្លើយនូវសំណួរចុងក្រោយដែលសួរដោយតំណាងសហព្រះរាជអាជ្ញាទេ។ សហព្រះរាជអាជ្ញា បើមានបំណងសួរសាក្សីបន្តទៀតអាចតាំងសំណួរផ្សេងបាន។

**លោក វីណ្ឌៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ បើសិនណាជាយើងដកឯកសារនេះ ហើយអាចបង្ហាញឯកសារ D43/IV ឧបសម្ព័ន្ធ៤៧។ ខ្ញុំមានឯកសារជាក្រដាសជូនទៅសាក្សីផងដែរ សូមអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីបង្ហាញលើអេក្រង់។

[១១:៤០:០០]

**ប្រធានអង្គជំនុំ៖**

ជំនុំជម្រះអនុញ្ញាត មន្ត្រីរដ្ឋបាលតុលាការទទួលពីតំណាងសហព្រះរាជអាជ្ញាជូនទៅសាក្សី។

**សួរដោយលោក វីណ្ឌៀម ស្មីត៖**

**ស៖** សាក្សីលោកធ្លាប់ឃើញឯកសារនេះដែរទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ឯកសារនេះក៏ជាឯកសាររបស់ស-២១ ហើយឯកសារដែលមានចំណាររបែបនេះយកមកបង្ហាញខ្ញុំឲ្យពន្យល់នៅក្នុងសំណុំរឿង អំ! នៅក្នុងសម័យស៊ើបអង្កេត។

**ស៖** ហើយប្រសិនណាយើងមើលទៅក្នុងប្រអប់នៅលើនៃឯកសារនេះ លោកអាចអានអក្សរនេះបានទេ?

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធានមុននឹងឲ្យសាក្សីអាន ខ្ញុំព្ញសួរសាក្សីគឺថា គាត់បានឃើញក្រោយមកទេ ក្រោយពី

គាត់ឆ្លើយនៅក្នុងសំណុំរឿង០០១។ ដូច្នេះខ្ញុំសូមជំទាស់ បើសិនណាជាយើង-- បើសិនណាគាត់ចេញតាមទ្វារមុខគាត់មិនអាច-- បើគាត់ចេញទ្វារមុខហើយ គាត់មិនអាចចេញតាមទ្វារក្រោយផងបានទេ។ ដូច្នេះបើគាត់និយាយអំពីចំណារ ដែលគាត់ធ្វើទៅលើឯកសារនេះក្រោយៗមកទៀតនៅស-២១ គឺថាត្រូវឲ្យវាមានលក្ខណៈដូចគ្នា។ ដូច្នេះការជំទាស់នេះ ខ្ញុំគិតឃើញថាមានប្រសិទ្ធភាព។ ហើយដូច្នេះបច្ចេកទេសនៃការសួរបែបនេះមិនអាចប្រើប្រាស់បានទេ។

**លោក វីណ្សៀម ស្មីត៖**

នេះគឺជាបញ្ហាខុសគ្នា លោក លោកស្រីចៅក្រម គឺខ្ញុំសួរ ខ្ញុំនឹងសួរថា តើចំណារជាចំណារអ្នកណានៅពេលក្រោយ?

[១១:៤២:១២]

**លោក ម៉ែខល ការណាវាស៖**

ប៉ុន្តែមានការបញ្ជាក់រួចហើយថា គាត់បានឃើញចំណារតែពេលក្រោយទេ។ សហព្រះរាជអាជ្ញាអាចនឹងសួរសំណួរដូចថា តើចំណារណាមួយលើនេះជាចំណារមកពីស-២១ ចំណារលោក ឬចំណាររបស់បុគ្គលិកលោក ឬក៏អត់? ឧទាហរណ៍ថា សន្មតថាគាត់ធ្វើចំណារនេះគឺគាត់ជាអ្នកដែលឃើញឯកសារនៃចម្លើយសារភាពនេះចុងក្រោយហើយ។ គាត់អាចនឹងធ្វើចំណារដោយរបៀបណាមួយក៏បានដែរ។ ប៉ុន្តែគាត់បានបញ្ជាក់ហើយថា ក្រោយពីបានឃើញឯកសារនេះ គឺគាត់បានឃើញចំណារនេះជាលើកទីមួយ នៅពេលដែលគាត់ត្រូវបានឃុំខ្លួននៅ អ.វ.ត.ក តែប៉ុណ្ណោះ។ ដូច្នេះ មិនត្រូវសួរសំណួរបែបនេះតទៅទៀតទេ។

**លោក វីណ្សៀម ស្មីត៖**

លោក លោកស្រីចៅក្រម បញ្ហាមិនដូច្នេះទេ។ បញ្ហាគឺខ្ញុំសួរថា តើគាត់បានឃើញឯកសារទេ? តើអាចចំណាំទៅលើចំណារបានទេ? វាមិនបញ្ហាថា គាត់ធ្លាប់បានឃើញចំណារ វាចេញពីស-២១ ឬក៏អត់នោះទេ។ សំណួរថា តើគាត់ចាំនូវចំណារដោយផ្ទាល់ដៃ ឬក៏អត់? សាក្សីរូបនេះគាត់អាចចាំនូវសរសេរអក្សរផ្ទាល់ដៃរបស់ នួន ជា បាន។ ដូច្នេះបានជាខ្ញុំសួរ ក្រែងថាតើចំណារដោយដៃនេះជាចំណាររបស់ នួន ជា?

**លោក ម៉ែខល ការណាវាស៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

លោកមេធាវីគួរតែគោរពតាមវិធាន ដែលអង្គជំនុំជម្រះបានកំណត់រួចហើយ បើលោកចង់និយាយគឺលោកត្រូវសុំការអនុញ្ញាតជាមុនពីប្រធានអង្គជំនុំជម្រះ មិនគប្បីងើបឡើងនិយាយឯកចិត្តដូច្នេះនោះឡើយ។

អញ្ជើញលោក ផេសមិន!

[១១:៤៤:០៤]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ទៅនឹងសំណួរដែលសហព្រះរាជអាជ្ញាបានសួរ ជាសំណួរ-- ពិតណាស់ជាសំណួរនាំមុខឲ្យសាក្សីឆ្លើយ ដើម្បីចង់បានចម្លើយ។ ដើម្បីឆ្លើយមកដាក់ឈ្មោះកូនក្តីរបស់យើងខ្ញុំ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី កាណាវាស មាន--

[១១:៤៤:២៩]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមអភ័យទោស ខ្ញុំនឹងព្យាយាមឈប់លោតឡើងឆ្លើយបែបនេះតទៅទៀតហើយ។ ខ្ញុំនឹងមិនជំទាស់ទេ ប្រសិនបើសហព្រះរាជអាជ្ញា គាត់បង្ហាញឯកសារដោយមានចំណារ ហើយសួរថា តើលោកចំណាំចំណារសរសេរដោយដៃនេះបានទេ? ឧទាហរណ៍ថា គាត់អាចឆ្លើយបាន គាត់ចំណាំបាន និងអាចសួរសំណួរបន្តបន្ទាប់ទៅទៀតបានថា តើជាចំណារអ្នកណា? ប៉ុន្តែការសួរថាតើមានអ្វីកើតឡើងបែបនេះ ពីព្រោះសាក្សីចម្លើយថា វាហួសពីសមត្ថកិច្ចរបស់គាត់ហើយ។ ហេតុដូច្នេះបានជាខ្ញុំជំទាស់។ ប្រសិនណាជាសំណួរនោះ សួរដោយត្រឹមត្រូវនោះ យើងបានដឹងថាតើសហព្រះរាជអាជ្ញាគាត់ចង់ទៅណា? មានមូលដ្ឋានអ្វីច្បាស់លាស់? នោះខ្ញុំមិនជំទាស់ទេ។ សួរថា តើចាំចំណារសរសេរដោយដៃនេះ ដូច្នេះជាដើមបាទ។

[១១:៤៥:៤៣]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៤៨:២៤]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ ដើម្បីដោះស្រាយបញ្ហានេះឲ្យបានជ្រះស្រឡះ អង្គជំនុំជម្រះផ្តល់វេទិកាទៅលោកចៅក្រម ហ្សង់ម៉ាក ដើម្បីក្នុងនាមតំណាង-- អ៎! ក្នុងនាមអង្គជំនុំជម្រះដើម្បីដោះស្រាយ សួរបញ្ជាក់ និងដោះស្រាយបញ្ហានេះ។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

ជាសារៈសំខាន់ណាស់ ដើម្បីឲ្យយើងដឹងថាតើសំណួរទាំងអស់នេះ មានភាពពាក់ព័ន្ធ ឬក៏អត់? ហើយដើម្បីវាយតម្លៃភាពពាក់ព័ន្ធនេះ យើងត្រូវដឹងឲ្យបានច្បាស់ ថាតើអ្នកណាដែលត្រូវអានចំណារនេះ? ហើយតើចំណារនេះចេញពីណា? លោក ឌុច លោកគឺជាអ្នកទទួលចំណារនេះ ឬក៏មិនមែន? ហើយ គឺចំណារដែលដាក់នៅលើឯកសារនេះ ហើយលោកបានបញ្ជាក់ថាឯកសារនេះ គឺចេញមកពីមន្ទីរស-២១ តើលោកជាអ្នកចារ ឬក៏មិនមែន?

[១១:៤៩:៤៨]

មានន័យថាឯកសារដើមចេញមកពីស-២១។ តើលោកអាចជម្រាបជូនបានទេ ថាចំណារនេះជាចំណារដែលលោកត្រូវអនុវត្តតាមដែរឬទេ? ឧទាហរណ៍ ចំណារនេះគេផ្ញើមកដើម្បីឲ្យអនុវត្តតាម ឬប្រាប់ព័ត៌មានអីមួយ ថាតើចំណារនេះមានគោលដៅអ្វីដែរ? ហើយសម្រាប់អ្នកណា? សូមឲ្យលោកឆ្លើយនឹងសំណួរនេះសិន។

**លោក កាំង ហ្កេកអ៊ាវ៖**

សូមអរគុណលោកចៅក្រម។ ចំណារដែលខ្ញុំសរសេរ ដែលចំណារដែលមាននៅក្នុងឯកសារបង្ហាញនេះ ខ្ញុំមិនឃើញទេ មុននឹងឯកសារនេះត្រូវបង្ហាញខ្ញុំឲ្យពន្យល់នៅក្នុងសម័យកាលស៊ើបអង្កេត។ ខ្ញុំសូមបញ្ជាក់ថា ស-២១ មានសិទ្ធិត្រឹមតែបញ្ជូនឯកសារទៅឲ្យអចិន្ត្រៃយ៍។ ឯចំណែកចាត់ចែងចារយ៉ាងម៉េច? ចាត់ចែងដោះស្រាយយ៉ាងម៉េច? ជាសមត្ថកិច្ចរបស់អចិន្ត្រៃយ៍។ អចិន្ត្រៃយ៍ចាត់ចែង ហើយក៏អត់ផ្តល់ព័ត៌មាននៃការចាត់ចែងនេះមកឲ្យស-២១ វិញដែរ។ ដោយឡែកមានតែមានឈ្មោះមនុស្សណា ដែលអចិន្ត្រៃយ៍សម្រេចឲ្យគេចាប់ ទើបអចិន្ត្រៃយ៍ឲ្យគេមកប្រាប់ថា ចាំទទួលឈ្មោះនេះៗ។ អរគុណ។ សូមបញ្ចប់។

[១១:៥២:១៩]

**ប្រធានអង្គជំនុំ៖**

សូមៗអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីណ្ឌៀម ស្មីត៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។ ប្រហែលជាត្រូវបញ្ជាក់បញ្ហានេះឲ្យច្បាស់។

**សួរដោយលោក វីណ្ឌៀម ស្មីត៖**

**ស៖** សាក្សីលោកបានិយាយអំពីគោលបំណងនៃចម្លើយសារភាព ចំណារជូនទៅសហចៅក្រមស៊ើបអង្កេតក្នុងអំឡុងពេលនៃការស៊ើបអង្កេត ក្នុងអំឡុងពេលនៃការស៊ើបអង្កេតនោះ។ តើនេះត្រឹមត្រូវដែរទេ?

[១១:៥២:៥៨]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ឯកសារដែលមានចំណារអក្សរក្រហមនៅខាងលើនេះ សហចៅក្រមស៊ើបអង្កេតយកមកបង្ហាញខ្ញុំឲ្យពន្យល់ នៅក្នុងសម័យកាលស៊ើបអង្កេត។ នេះជាការពិត។

**ស៖** ហើយបើសិនណា ខ្ញុំអាចបញ្ជាក់លោកបាននៅពេលដែលគេបង្ហាញឯកសារទៅលោក គឺឯកសារ D21 អង់គ្លេស 00242931។ លោកចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង បានសួរទៅលោកថា “ចំណារនៅផ្នែកខាងលើខាងឆ្វេងនេះ គឺដាក់ថា សមមិត្តវ៉ាន់ តើលោកអាចពន្យល់បានទេ?” លោកបានពន្យល់ថា “ខ្ញុំបានឃើញចំណារបែបនេះប៉ុន្មានដងដែរ ចំណារនេះជាចំណាររបស់ នួន ជា។ ហើយ សុន សេន បានបញ្ជាក់ទៅថា បងវ៉ាន់ មិនមែន សមមិត្តវ៉ាន់ ដូចដែលលោក នួន ជា សរសេរនោះទេ។ ចម្លើយសារភាពផ្ញើទៅជូនប្រធានអង្គភាព ក្នុងចំណុចពីរ។ ទីមួយ ដើម្បីបញ្ជាក់អំពីប្រធានមន្ទីរអង្គភាពនោះ និងម្យ៉ាងទៀតដើម្បីៗឲ្យគាត់សម្របសម្រួលដល់ការចាប់ខ្លួនទៅដល់មនុស្សដែលពាក់ព័ន្ធ ប្រសិនណាជាត្រូវការ”។

[១១:៥៤:៣៤]

ហើយពាក់ព័ន្ធទៅនឹងលោក មាឃ ទូច ដែលជាឯកអគ្គរដ្ឋទូតនៅប្រចាំប្រទេសឡាវនោះ គឺថាបានបញ្ជូនទៅប្រធានមន្ទីរអង្គភាព។ ដូច្នេះសំណួររបស់ខ្ញុំ គឺថាតើលោកបញ្ជូនឯកសារនេះជូនទៅគណៈអចិន្ត្រៃយ៍ ហើយលោកមិនដឹងថា មានអ្វីកើតឡើងទៅនឹងមនុស្សបែបនេះទេ? ឬក៏មានករណីដែល

លោកខ្លះ លោកបានដឹងដូចជាលោកឆ្លើយបញ្ជាក់ទៅចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង នោះ។ តើលោកបញ្ជាក់ចំណុចនេះឡើងវិញបានទេ?

**ឆ៖** លោកប្រធានជាទីគោរព សំណួរនេះទូលាយ ខ្ញុំក៏ក្តាបជ្រុងជ្រោយខ្ចឹមសារឲ្យចំត្រង់ណាមួយ ដើម្បីឆ្លើយមិនទាន់បានទេ។ សូមអនុញ្ញាតឲ្យឯកសហព្រះរាជអាជ្ញាបញ្ជាក់ឲ្យចំកន្លែងណាដែលលោកចង់ដឹង។

**ស៖** សាក្សី លោកបានឆ្លើយទៅចៅក្រម យូ ប៊ុនឡេង ថាចម្លើយសារភាពផ្ញើជូនប្រធានមន្ទីរដើម្បីមូលហេតុពីរ។ ទីមួយ គឺដើម្បីជូនប្រធានមន្ទីរអំពីសកម្មភាពរបស់ខ្មាំង និងទីពីរ ដើម្បីឲ្យគាត់កំណត់នូវការចាប់-- សម្រួលដល់ការចាប់ខ្លួនអ្នកដែលឆ្លើយពាក់ព័ន្ធ។ ប្រសិនរឿងហ្នឹង វាដូច្នេះមែនថាចម្លើយសារភាពជូនទៅប្រធានមន្ទីរអង្គភាព ដើម្បីថាត្រូវចាប់ខ្លួនបន្តទៅទៀត ឬក៏យ៉ាងណា និងដើម្បីជូនដំណឹងទៅប្រធានមន្ទីរអង្គប្រភាពអំពីសកម្មភាពរបស់ខ្មាំង។ តើនេះវាជាករណីអ៊ីចឹងមែនឬក៏អត់?

[១១:៥៦:៣៣]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតបនឹងសំណួរ ពីព្រោះមានជំទាស់ពីមេធាវីការពារក្តី។

បាទ សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំច្របូកច្របល់មែនទែន ខ្ញុំឮថា សាក្សីថាគាត់មិនអាចអានចំណារនេះបានទេ។ ហើយសហព្រះរាជអាជ្ញា គាត់ដកស្រង់សម្តីយកចំណារនៅជ្រុងខាងលើ ខាងឆ្វេងនៃឯកសារហ្នឹង។ ហើយខ្ញុំមិនដឹងថា យើងកំពុងនិយាយទៅឯកសារដដែល ឬក៏យ៉ាងម៉េច? ហើយក៏គឺចំណារនៅជ្រុងខាងស្តាំ ផ្នែកខាងលើ គឺសាមញ្ញបំផុត តើយើងកំពុងនិយាយឯកសារដដែល ឬក៏យ៉ាងណា ឬក៏សាក្សី គាត់មិនអាចអានចំណារនេះបានទេ មុននឹងគាត់ឆ្លើយទៅសហចៅក្រមស៊ើបអង្កេតនោះ?

**លោក វីណ្សៀម ស្មីត៖**

ខ្ញុំមិននិយាយអំពីឯកសារនៅចំពោះមុខសាក្សីទេ។ ខ្ញុំនិយាយអំពីមូលហេតុដែលគាត់ឆ្លើយជូនសហចៅក្រមស៊ើបអង្កេត គឺចម្លើយសារភាពផ្តល់ទៅប្រធានមន្ទីរអង្គភាព ដើម្បីឲ្យដឹងអំពីសកម្មភាព

ខ្លាំង និងដើម្បីអនុញ្ញាតឲ្យមានការចាប់ខ្លួនពីអង្គភាពនោះ។

[១១:៥៨:០៤]

គាត់បានផ្តល់ចម្លើយដែលស៊ីសង្វាក់គ្នាទៅនឹងចម្លើយថ្ងៃនេះ ហើយក៏បានផ្តល់ចម្លើយខ្លះ ក៏វាមិនស៊ីសង្វាក់គ្នាដែរ។ អ្វីដែលខ្ញុំចង់បាននេះ គឺខ្ញុំសួរសំណួរជាក់លាក់ទៅគាត់នូវអ្វីដែលគាត់បានឆ្លើយទៅសហចៅក្រមស៊ើបអង្កេត ដើម្បីឲ្យឃើញនូវទិដ្ឋភាពពិតតែម្តង។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ក្នុងរបៀបដែលសហព្រះរាជអាជ្ញាចាប់ផ្តើមសំណួររបស់គាត់ផ្តល់ចំណាប់អារម្មណ៍របស់គាត់ ដែលថាសាក្សីបានពិភាក្សាឯកសារនេះនៅពេលនោះ។ ឥឡូវនោះ វាហាក់បីដូចជាថា គឺហាក់បីគាត់យោងទៅលើឯកសារផ្សេងទៅវិញ។ បើដូច្នេះមែននោះ សហព្រះរាជអាជ្ញាអាចនឹង គឺថាជជីកសាកសួរសាក្សីរបស់គាត់ផ្ទាល់នេះ ឬគាត់កំពុងព្យាយាម កំពុងតែដាស់ការចងចាំរំឭកការចងចាំជំនួសសាក្សីនេះ។ ខ្ញុំបានបញ្ជាក់ហើយ គឺថាសាក្សីបញ្ជាក់នៅថ្ងៃនេះ គឺសាក្សីត្រូវឆ្លើយនៅក្រោមសម្បថ នូវអ្វីដែលគាត់បានឆ្លើយជូនសហចៅក្រមស៊ើបអង្កេត។ ហើយមុន-- ក្នុងសវនាការនេះសោតទៀត គឺថាគាត់ត្រូវតែឆ្លើយដោយស្ថិតនៅក្រោមការធ្វើសម្បថ។ ឧទាហរណ៍ដែលនៅបន្សល់ទុកនៅស-២១ គាត់មិនបានដឹងថាតើឯកសារនេះត្រូវចាត់ចែងរបៀបណាទេ ហើយឯកសារនេះមិនបានបញ្ជូនត្រឡប់មកវិញផង។ ហើយឥឡូវនេះ សហព្រះរាជអាជ្ញាគាត់ចង់ឲ្យសាក្សីអះអាង ដើម្បីឆ្លើយទៅនឹងអ្វីដែលគាត់បានឆ្លើយជូនសហចៅក្រមស៊ើបអង្កេត។

បើធ្វើដូច្នេះ ខ្ញុំសូមថាធ្វើយ៉ាងម៉េចកុំសួរក្នុងលក្ខណៈជាសំណួរនាំមុខ គឺគ្រាន់សួរថា គាត់បាននិយាយអ្វីខ្លះទៅនឹងសហចៅក្រមស៊ើបអង្កេតអង្កាល់ពេលនោះ គឺថាយើងឃើញថា សាក្សីនេះ គេកំពុងត្រូវបានរំឭក គាត់កំពុងតែបំផ្លាញទៅលើឯកសារនេះហើយ។ ហើយបើថា ជជីកសាកសួរសាក្សីនេះយ៉ាងណាគឺគាត់ត្រូវនិយាយប្រាប់យើងថា នៅក្នុងឱកាសណាមួយផ្សេងនោះ លោកអាចនៅចាំបានទេ អ្វីដែលលោកបានឆ្លើយនៅពេលនោះ ឆ្លើយទៅនឹងសំណួរដូចនេះៗ។ ប៉ុន្តែអ្វីដែលសហព្រះរាជអាជ្ញាធ្វើនេះ គឺខ្ញុំសួរថា មិនគួរណាសួរបែបណាដើម្បីគោលបំណង ឬក៏ចេតនាទុច្ចរិតណានោះទេ?

[១២:០០:៥៦]

ខ្ញុំចង់ថា ឲ្យគាត់ធ្វើកិច្ចការនេះប្រកបដោយភាពទុច្ចរិត បើគាត់ជជែកសាកសួរបែបនេះ គាត់អាចធ្វើបាន បើគាត់រំឭក ឬក៏ជួយដាស់ការចងចាំរបស់សាក្សីនេះ គឺខ្ញុំគ្រាន់តែឲ្យបង្ហាញឯកសារទៅលើសាក្សី ហើយចោទសួរសាក្សីដោយមិនត្រូវការចោទសួរទាំងឡាយណាដែលជាការដាស់ការចងចាំទៅដល់សាក្សីរូបនេះនោះទេ។ សូមអរគុណច្រើន។

**លោក វីណ្ហៀម ស្មីត៖**

លោក លោកស្រីចៅក្រម។ ខ្ញុំសហព្រះរាជអាជ្ញា ខ្ញុំមិនព្យាយាម *អ៊ីមភីឆ* បានន័យថា សួរផ្ចុញផ្ចាលគាត់នោះទេ។ ខ្ញុំគ្រាន់តែសួរឲ្យគាត់បញ្ជាក់ពីអ្វីដែលគាត់បានដឹង។

*(ចៅក្រមពិភាក្សាគ្នា)*

[១២:០២:០៥]

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់មេធាវីទាំងពីរក្រុមចំពោះការតាំងសំណួរចុងក្រោយដោយតំណាងសហព្រះរាជអាជ្ញាអន្តរជាតិចំពោះសាក្សីរូបនេះគ្មានប្រសិទ្ធភាព។ ដូច្នេះសាក្សីត្រូវឆ្លើយតបទៅនឹងសំណួរដែលសួរចុងក្រោយដោយតំណាងសហព្រះរាជអាជ្ញាអន្តរជាតិអម្បាញ់មិញនេះ ប្រសិនបើលោកចងចាំ បើមិនចងចាំទេ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ អាចតាំងសំណួរនេះជាថ្មី។

សូមអញ្ជើញ!

**លោក វីណ្ហៀម ស្មីត៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វីណ្ហៀម ស្មីត៖**

**ស៖** លោកសាក្សី តើលោកនៅចាំសំណួរខ្ញុំទេ? បើសិនជាលោកមិនចាំខ្ញុំនឹងសួរឡើងវិញ។

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ដើម្បីច្បាស់លាស់ ខ្ញុំសូមអញ្ជើញព្រះរាជអាជ្ញាសួរខ្ញុំសាជាថ្មី។

[១២:០៣:១០]

**ស៖** នៅក្នុងការឆ្លើយរបស់លោកជូនសហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង នោះទាក់ទងទៅនឹងឯកសារ ចម្លើយសារភាព ហើយនិងចំណារទៅលើចម្លើយសារភាពរបស់ មាយ ទូច លោកថា លោកបានពន្យល់ថា លោកបានឃើញចម្លើយសារភាពមួយចំនួនត្រូវបានចារផ្ទាល់ដៃដោយរបៀបនេះ

ហើយលោកនិយាយថា ចំណារហ្នឹងធ្វើឡើងដោយ នួន ជា ហើយប្រសិនបើ សុន សេន ជាអ្នកសរសេរទៅ អៀង សារី គាត់ហៅថា បងរ៉ាន់ គាត់មិនហៅថា សមមិត្តរ៉ាន់ ទេ។ បន្ទាប់មកលោកនិយាយបន្តថា ចម្លើយសារភាពត្រូវបានបញ្ជូនទៅប្រធានអង្គភាពដើម្បីឲ្យគាត់ពិនិត្យមើលមួយ គឺដើម្បីជូនដំណឹងដល់អ្នកនោះ អំពីសកម្មភាពខ្មាំងនៅក្នុងអង្គភាពនោះ។ ហើយមួយទៀត គឺដើម្បីឲ្យប្រធានអង្គភាពនុំងពិនិត្យមើល ហើយនិងសហការជាមួយការចាប់ជនដែលគេឆ្លើយដាក់នោះ។

សំណួររបស់ខ្ញុំចំពោះលោកគឺថា តើនេះជាការពិតដែរឬទេ ថាលោកបានដឹងថាចម្លើយសារភាពទាំងនោះត្រូវតែបញ្ជូនទៅប្រធានអង្គភាព ជាទីកន្លែងដែលជនជាប់ចោទ អ៎! ជនជាប់ឃុំនោះ គេបានបញ្ជូនមកពី-- អ៎! សូមទោស។ ថាតើជាករណីដែលទេ ដែលថាចម្លើយសារភាពត្រូវបានបញ្ជូនទៅប្រធានអង្គភាពជាកន្លែងដែលមនុស្សត្រូវបានគេចោទ គេឆ្លើយដាក់ ដើម្បីឲ្យប្រធាននោះបានដឹង ហើយក៏ដើម្បីជួយសម្រួលឲ្យបានដឹងថា អ្នកដែលគេឆ្លើយដាក់នោះ ទំនងគេនឹងត្រូវចាប់ខ្លួនហើយ។ ពីព្រោះថា ថ្ងៃនេះលោកបាននិយាយថា ក៏ដូចគ្នាដែរ នៅពេលដែលចម្លើយសារភាពបញ្ជូនទៅ គណៈអចិន្ត្រៃយ៍ហើយ លោកមិនដឹងថា គេយកទៅធ្វើអ្វីទេ។ ដូច្នេះ សូមលោកបំភ្លឺត្រង់ចំណុចនេះ។

[១២:០៥:២២]

**លោក ម៉ៃខល កាណាវាស៖**

សូមអនុញ្ញាតលោកប្រធាន។ ខ្ញុំមិនចង់ជំទាស់ទេ បើសិនជាយើងពិនិត្យមើលចម្លើយទាំងស្រុង វាមានចំណុចខ្លះ ដែលថាន័យផ្សេង ប៉ុន្តែសហព្រះរាជអាជ្ញាដកស្រង់ចំណុចមួយ។ គាត់និយាយថា "ខ្ញុំមិនដឹងជាលម្អិតទេថា អ្នកទាំងអស់នោះធ្វើការទាក់ទងគ្នានោះ" ហើយគាត់និយាយថា "វាអាចថាដោយសារថាប្រហែលជាអាចនឹងបញ្ជូនទៅភាគីណា"។ ដូច្នេះ ខ្ញុំគិតថា ដើម្បីឲ្យពេញលេញគឺថា សហព្រះរាជអាជ្ញាអានទាំងស្រុងនៃផ្នែកនោះ ឬក៏បង្ហាញចម្លើយទាំងស្រុងដើម្បីយើងមើល ហើយយើងមិនជំទាស់ទាក់ទងទៅនឹងការតាំងសំណួរ ប៉ុន្តែការជ្រើសរើសយកតែផ្នែកមួយនៃចម្លើយរបស់គាត់នោះមិន-- បាទគឺថាយើងសំណួរហ្នឹង គឺថាគាត់ផ្តល់ជាចម្លើយទាំងស្រុង យកត្រង់ហ្នឹងទាំងមូល គឺអាចនឹងជួយដល់លោកសាក្សីបាន។

ឥឡូវនេះ គឺយើងនិយាយអំពីអ្វីដែលគាត់ដឹង ឬក៏អ្វីដែលគាត់សន្និដ្ឋាន ឬអ្វីដែលគាត់បានដឹងពេលក្រោយមក ឬក៏អ្វីដែលគាត់ទើបតែបានឃើញបានដឹងពេលនេះបាទ។

*(ចៅក្រមពិភាក្សាគ្នា)*

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់របស់មេធាវីការពារក្តីលោក អៀង សារី ចុងក្រោយអម្បាញ់មិញនេះគ្មានប្រសិទ្ធភាពទេ។ ដូច្នេះសាក្សីត្រូវឆ្លើយនឹងសំណួរដែលសួរអម្បាញ់មិញនេះ ហើយអង្គជំនុំជម្រះសូមជម្រាបជូនផងដែរថា ក្រុមមេធាវីការពារក្តីទាំងអស់ ទាំងមេធាវីការពារក្តី នួន ជា ផង ទាំងមេធាវីការពារក្តីលោក អៀង សារី ផង ហើយនិងក្រុមមេធាវីការពារក្តីដទៃទៀត។ បញ្ហាដែលនៅសេសសល់ដែលមានស្ថានភាពមានផលប្រយោជន៍ផ្ទុយគ្នានៅក្នុងការដេញដោល ចំពោះសាក្សីក៏ដោយ ចំពោះជនជាប់ចោទ ឬក៏អ្នកមុខគោលដៅ ដែលត្រូវផ្តល់សក្ខីកម្មនោះ គឺគប្បីទុកលទ្ធភាពនេះ ដេញដោលដោយខ្លួនឯង តាំងសំណួរដោយខ្លួនឯង នូវចំណុចទាំងឡាយណាដែលខ្លួនយល់ឃើញថា មិនត្រឹមត្រូវ ដើម្បីផ្ទៀងផ្ទាត់ឲ្យអង្គជំនុំជម្រះមានមូលដ្ឋានពិចារណាការវាងចម្លើយដែលផ្តល់សក្ខីកម្មដោយសាក្សីនៅក្នុងអំឡុងពេលភាគីម្ខាងទៀតសួរ។ ឧទាហរណ៍ដូចជា តំណាងសហព្រះរាជអាជ្ញាសួរ និងបញ្ហាស្រដៀងគ្នា ឬក៏ប្រហាក់គ្នា ឬក៏ជាមួយគ្នានេះដែលពាក់ព័ន្ធសួរដោលដោយក្រុមមេធាវីការពារក្តី ដោយឥស្សរចិត្ត។ អង្គជំនុំជម្រះនឹងពិចារណាមើល ថាតើចម្លើយមួយណាដែលអង្គជំនុំជម្រះអាចជឿបាន។ នេះជាបច្ចេកទេសខុសគ្នា រវាងនីតិ-- បច្ចេកទេសក្នុងការសួរដេញដោលរវាងភាគីចោទ ភាគីដាក់បន្ទុក ហើយនិងភាគីដោះបន្ទុក។ ភាគីពាក់ព័ន្ធនៅទីនេះ ការអនុវត្តបច្ចេកទេសមិនតម្រូវទៅតាមការយល់ដឹង ឬក៏ភាពជំនាញនៃភាគីណាមួយឡើយ។

សូមអញ្ជើញសាក្សី ឆ្លើយនឹងសំណួរអម្បាញ់មិញនេះ ប្រសិនអាចឆ្លើយបានដើម្បី-- មុនយើងសម្រាកពិសាអាហារថ្ងៃត្រង់។

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ដោយសារសំណួរនេះវាឃ្លាតពីការឆ្លើយខ្ញុំសូមសរុបឆ្លើយត្រួសៗ បើខ្វះខាតយ៉ាងម៉េច សូមព្រះរាជអាជ្ញាសួរថែមផ្សេងទៀតចុះ។ ស-២១ ផលិតឯកសារជូនអចិន្ត្រៃយ៍ នេះជាភារកិច្ចរបស់ស-២១។ យកឯកសារទៅពិនិត្យ ហើយសម្រេច នេះវាជាកាតព្វកិច្ចរបស់អចិន្ត្រៃយ៍។ ស-២១ អត់មានសិទ្ធិចូលទៅជ្រៀតជ្រែកទេ។ ហើយចាត់ចែងឯកសារនេះ ក៏វាជាភារកិច្ចរបស់អចិន្ត្រៃយ៍ដែរ។ ដោយឡែក ខ្ញុំឆ្លើយជាមួយនឹងសហចៅក្រម យូ ប៊ុនឡេង ខ្ញុំឆ្លើយលម្អិត។ អចិន្ត្រៃយ៍បញ្ជូនឯកសារដែលខ្លួនបានអានហើយទៅសាមីអង្គភាព ដើម្បីសាមីអង្គភាពយល់ ហើយនិងចាត់ចែង។ នេះជា១រឿងលម្អិត ជារឿងជាក់ស្តែងក្នុងការអនុវត្ត។ ឯចំណែកខ្ញុំរាយការណ៍ជូនសហចៅ-- លោកន៎

ចៅក្រម ឡាវ៉ែន៍ អំមិញនេះ ខ្ញុំនិយាយអំមិញតែមួយម៉ាត់ទេ ខ្ញុំថាហ្នឹងជាកាតព្វកិច្ចជារបស់អចិន្ត្រៃយ៍។ ដូច្នេះវាដូចគ្នាទេ មួយសរុប មួយនិយាយឲ្យជាក់ស្ដែង។ ដូច្នេះពិត រឿងទាំងឡាយណាដែលខ្ញុំបានរាយការណ៍ជូនសហចៅក្រមស៊ើបអង្កេត ជារឿងដែលចេញពីការឃើញ ការបានអនុវត្តរបស់ខ្ញុំនៅជំនាន់នុ៎ង។ ពេលនេះ និយាយត្រឹមប៉ុណ្ណេះ ពេលនោះនិយាយត្រឹមប៉ុណ្ណោះ វាអត់នេះទេ គ្រាន់តែមួយនិយាយវាល្អិតជាក់ស្ដែង មួយទៀតនិយាយជាគោលការណ៍។ ដូច្នេះ ខ្ញុំនៅតែរក្សាគ្រប់ម៉ាត់ គ្រប់ពាក្យដែលខ្ញុំរាយការណ៍ជូនសហចៅក្រមស៊ើបអង្កេត។ ហើយរក្សាគ្រប់ម៉ាត់ គ្រប់ពាក្យដែលខ្ញុំបានឆ្លើយចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនេះ។ ដូច្នេះ ខ្ញុំសូមឆ្លើយខ្លីប៉ុណ្ណឹង។

[១២:១១:៣៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណតំណាងសហព្រះរាជអាជ្ញា អរគុណសាក្សី។ ឥឡូវនេះដល់ពេលត្រូវសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ចាប់ពីពេលនេះទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលថ្ងៃនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ ហើយនិងបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង ឲ្យអញ្ជើញសាក្សីទៅកាន់បន្ទប់រង់ចាំសម្រាប់សាក្សី ហើយឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅរសៀលនេះ នៅម៉ោងមួយសាមសិបនាទី។

សូមអញ្ជើញលោកមេធាវី ផេសមិន!

[១២:១២:១៧]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ កូនក្ដីរបស់ខ្ញុំគាត់ចង់ជូននូវសំណើសុំតាមដានពីបន្ទប់នៅខាងក្រោមយើង-- ដូចជម្រាបថាកូនក្ដីរបស់ខ្ញុំមិនអាចចូលរួមនៅក្នុងសាលសវនាការខាងក្នុងនេះ។ ខ្ញុំនឹងជូនលិខិតបោះបង់សិទ្ធិរបស់គាត់នៅពេលបន្ទាប់នេះ បាទ។

[១២:១២:៤៣]

**ប្រធានអង្គជំនុំ៖**

បាទបានស្ដាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្ដីរបស់ខ្លួនគាត់ ស្នើសុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ខាងក្រោមបន្ទប់

សវនាការតាមប្រព័ន្ធសោតទស្សន៍ ដោយលះបង់សិទ្ធិមិនចូលរួមសវនាការដោយផ្ទាល់ នៅក្នុងបន្ទប់សវនាការនេះដោយមូលហេតុសុខភាព។ អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំតាមរយៈមេធាវីរបស់គាត់ ដោយលះបង់សិទ្ធិមិនចូលរួមតាមដានកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ទៅតាមដានកិច្ចដំណើរការពីចម្ងាយពីបន្ទប់មួយស្ថិតនៅក្រោមបន្ទប់សវនាការនេះ តាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់ពេញមួយរសៀលនេះ។ តែក្រុមមេធាវីការពារក្តីត្រូវប្រគល់មកឱ្យអង្គជំនុំជម្រះភ្លាមៗ នូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់របស់ជនជាប់ចោទ នួន ជា ដោយមានចុះហត្ថលេខា ឬក៏ផ្តិតម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទរូបនេះផង។

បង្គាប់ផ្នែកខាងសោតទស្សន៍ តភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា តាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់ដំណើរការសវនាការរសៀលនេះ។ ហើយបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប ទៅកាន់បន្ទប់រង់ចាំខាងក្រោម ហើយរសៀលនេះទុកលោក នួន ជា នៅខាងក្រោមនុ៎ងហើយ ហើយឱ្យនាំតែលោក ខៀវ សំផន មកកាន់សាលសវនាការវិញឱ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:១៤ នាទី ដល់ម៉ោង ១៣:៣៥ នាទី)*

[១៣:៣៤:២៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ នឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញ!

**លោក វីល្លៀម ស្មីត៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ហើយនិងសាធារណជនទាំងអស់ផងដែរ។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** លោក កាំង ហ្កេកអ៊ាវ មុនពេលដែលយើងឈប់សម្រាកព្រឹកមិញនេះ លោកបាននិយាយថា អ្វីដែលលោកបាននិយាយជម្រាបសហចៅក្រមស៊ើបអង្កេតនោះ ទាក់ទងទៅនឹងអង្គហេតុដែលថា ចម្លើយសារភាពត្រូវបានបញ្ជូនទៅប្រធានអង្គភាពហ្នឹងចំណុចមួយ។ ទីមួយ គឺដើម្បីជូនដំណឹងប្រធានរបស់អង្គភាពនោះអំពីសកម្មភាពខ្មាំងនៅក្នុងអង្គភាពនោះ។ ហើយមួយទៀត គឺដើម្បីឲ្យប្រធានអង្គភាពនោះគឺថា អង្កេត និងសហការក្នុងការចាប់ខ្លួនរបស់ខ្មាំងទាំងនោះ។ តើលោកអាចបញ្ជាក់បានទេថា សេចក្ដីលម្អិតនោះត្រឹមត្រូវទេ? លោកបញ្ជាក់ថា "ត្រឹមត្រូវ"។

សំណួររបស់ខ្ញុំបន្ទាប់ ថាតើជាការអនុវត្តទូទៅដែរឬទេ ទាក់ទងទៅនឹងចម្លើយសារភាពទាំងអស់ដែលឆ្លើយ ដែលគេឆ្លើយដាក់ទៅមនុស្សផ្សេងៗនៅក្នុងអង្គភាពផ្សេងៗនោះបាទ? ឬក៏មន្ទីរ ឬក៏ក្រសួងផ្សេងៗ ដែលដើម្បីឲ្យប្រធានក្រសួងមន្ទីរហ្នឹងគេពិនិត្យឯកសារនោះបាទ?

[១៣:៣៦:២៣]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ សូមបញ្ជាក់ជូនតុលាការទាំងមូលថា អ្នកដែលបញ្ជូនសំណុំរឿងទៅឲ្យសាមីអង្គភាព ដែលមានអ្នកឆ្លើយសារភាពនៅស-២១ ហ្នឹង គឺជាកាតព្វកិច្ចរបស់អចិន្ត្រៃយ៍ទេ មិនមែន ស-២១ ទេ។ សហព្រះរាជអាជ្ញានិយាយហ្នឹង អត់មានប្រធាន វាអត់ច្បាស់។ ដូច្នេះខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ ប្រធានរបស់វាគឺអចិន្ត្រៃយ៍មជ្ឈិមបញ្ជូនទៅ។ នេះជាក្រឹត្យក្រមរួមនៃកិច្ចដំណើរការ ដែលអចិន្ត្រៃយ៍ប្រើប្រាស់ឯកសារស-២១ និងឯកសារមន្ទីរនគរបាលទាំងអស់ផ្សេងទៀត។

[១៣:៣៧:២៧]

**ស៖** ថាតើលោកដឹងដោយវិធីណា ថាគណៈកម្មាធិការបញ្ជូនចម្លើយសារភាពនេះទៅមន្ទីរផ្សេងទៀតនោះ?

**ឆ៖** អរគុណ។ សូមគោរពលោកប្រធាន យើងខ្ញុំប្រតិបត្តិការបញ្ហានេះច្រើនឆ្នាំហើយ ជាពិសេសតាំងពីឆ្នាំ១៩៧១ មក។ ឯកសារដែលយើងខ្ញុំជូនទៅ តាម៉ុក ជូនទៅ សុន សេន គេផ្ញើរទៅ៣២ បងប៉ាល់ រឿងអីក៏ដោយឲ្យតែជាប់ទាក់ទងជាមួយ បងប៉ាល់ ខាងតំបន់៣២ នេះរឿងចាស់។ រឿងថ្មីក៏អ៊ីចឹង។ រឿងខ្ញុំបញ្ជូនឯកសារទៅ វាលេចចេញជាការប្រជុំនៅថ្ងៃ១៦ ខែកញ្ញា ១៩៨៦ (ស៊ីក) ដែលឲ្យ មិត្តសុខ មកចូលរួមដែរ ដើម្បី មិត្តសុខ មានមតិ តើអនុញ្ញាតឲ្យចាប់ខាងណាខ្លះ អីខាងណាខ្លះ។ នេះ

ក្នុងការអនុវត្តជាក់ស្តែងឲ្យយើងខ្ញុំឃើញ។ ភស្តុតាងមានជាក់ស្តែងហើយ។ ដូច្នេះ ជាគោលការណ៍ គឺអ៊ីចឹង។ រួចឯកសារមួយទៀត មានគេឆ្លើយដាក់មនុស្សនៅក្នុងមន្ទីរអង្គការ ពេទ្យអង្គការ ក៏ប៉ុន្តែខាងតាម៉ុក ហ្នឹងសួរចម្លើយ។ តាម៉ុក ផ្ញើមកឲ្យអចិន្ត្រៃយ៍ធ្វើ។ ហ្នឹងវាជារឿងធម្មតា។ ការផ្ញើឯកសារចុះឡើងក្នុងកិច្ចចាត់ចែងរបស់អចិន្ត្រៃយ៍ភាគជាមួយនឹងលេខាភាគ ជាមួយនឹងម្ចាស់អង្គភាពដើម ឬនឹងអង្គភាពដែលមានពាក់ព័ន្ធ។

[១៣:៣៩:៣០]

**ស៖** សូមអរគុណ។ លោកបាននិយាយថា មូលហេតុមួយដែលប្រធានអង្គភាពសាមីដែលត្រូវសួរយោបល់នោះ គឺអនុញ្ញាតឲ្យគាត់សម្របសម្រួល ឬក៏បានដឹងឮអំពីការចាប់ខ្លួនរបស់អ្នកដែលគេចោទនោះ។ ថាតើលោកដឹងទេថា ប្រធានអង្គភាពសាមីនោះមានជម្រើស ថាត្រូវចាប់ ឬមិនត្រូវចាប់អ្នកដែលគេឆ្លើយដាក់នោះ? តើពាក្យថា "ជួយសម្របសម្រួល" ឬក៏ឲ្យបានដឹងពីបញ្ហានេះតើមានន័យដូចម្តេច?

**ឆ៖** ឥឡូវយើងឃើញឯកសារដែលសល់ជាភស្តុតាង។ បងខៀវ សុន សេន នេះសរសេរទៅឲ្យ មិត្តតាល់ ពិនិត្យ។ បានន័យថា មនុស្សថាឆ្លើយដាក់ក្នុងនុ៎ង អង្គការសម្រេចជាគោលការណ៍ហើយថាត្រូវចាប់។ ប៉ុន្តែម្ចាស់អង្គភាពអាចរក្សាទុកអ្នកណាមួយបាន ដោយម្ចាស់អង្គភាពត្រូវធានាចំពោះមុខអង្គការមិនឲ្យអ្នកនោះដឹងរឿង ហើយក៏មិនឲ្យអ្នកនោះបំផ្លាញអង្គការតទៅទៀតបាន។ នេះមួយភស្តុតាង។ ភស្តុតាងមួយទៀត ខ្ញុំសូមលើកឧទាហរណ៍ថ្ងៃ១៦ កញ្ញា ១៩៧៦ ដដែលយកមកវែកញែក។ នៅពេលដែលអង្គការ នៅពេលដែលបង៨៩ គាត់សួរទៅ បងខៀវ គាត់សួរទៅ មិត្តសុខៗ ថានេះមិនមែនខ្សែ ចក្រី ទេ ខ្សែគេផ្សេង បងខៀវ ថា អើ! ទុកចុះ។ ដូច្នេះបញ្ជីមនុស្សប៉ុន្មានដែលឆ្លើយនោះសរុបទៅវាលើស គាត់ចម្រាញ់ទៅនៅសល់២៩នាក់។ នេះជាកិច្ចដំណើរការមួយដែលនាំឲ្យយើងខ្ញុំអះអាងថា គោលការណ៍ដែលថា ម្ចាស់អង្គភាពសុខចិត្ត ទើបចាប់បាន អាហ្នឹងវាមានចេញជាភស្តុតាងជាក់ស្តែងហើយ។ គោលការណ៍ គឺអ៊ីចឹង ម្ចាស់អង្គភាពសុខចិត្ត ទើបចាប់បាន។

[១៣:៤២:០៨]

**ស៖** តើលោកអាចពន្យល់គោលបំណងពីបញ្ហានេះ ថាតើត្រូវមានការព្រមព្រៀងពីប្រធានអង្គភាពសាមីមុនពេលនឹងចាប់ខ្លួននោះ? តើលោកអាចជម្រាបតុលាការបានទេ ហេតុអីបានជាមានករណីបែបនេះ?

**ឆ៖** អរគុណ។ សូមគោរពលោកប្រធាន ក្នុងលក្ខន្តិកៈបក្ស កម្មាភិបាលម្នាក់គេទទួលខុសត្រូវចំពោះមុខបក្សលើមហាជនរបស់គេ។ មហាជនគេខុស គេដឹង។ ដូច្នេះបើកាលណាគេប៉ានធានាអ្នកណាហើយ គឺជីវិតគេនៅក្នុងជាមួយអ្នកនោះឯងដែរ។ ហើយយើងចេះតែទៅដកផ្ដេសផ្ដាស យើងក៏ខុសលក្ខន្តិកៈបក្សដែរ។ យើងរំលោភលើភារកិច្ចរបស់គេដែលបក្សប្រគល់ឲ្យ គេទទួលខុសត្រូវចំពោះមុខបក្ស លើអង្គភាពរបស់គេ លើមហាជនរបស់គេ។

[១៣:៤៣:២៨]

**ស៖** ពេលដែលលោកនិយាយថា កម្មាភិបាលមានការទទួលខុសត្រូវចំពោះមហាជនរបស់ពួកគេនោះ តើមានអត្ថន័យដូចម្ដេច?

**ឆ៖** អរគុណ សូមគោរពលោកប្រធាន។ កម្មាភិបាលទទួលខុសត្រូវចំពោះមហាជនរបស់ខ្លួន។ ខ្ញុំសូមលើឧទាហរណ៍ជាក់ស្ដែងដើម្បីស្រួលយល់។ យុទ្ធជននៅក្នុងមន្ទីរ១៣ មុននឹងជ្រើសចូលមន្ទីរ១៣ ខ្ញុំជ្រើសយកមកពីមូលដ្ឋានភូមិឃុំមកដោយផ្ទាល់ដៃ ធានាបរិសុទ្ធភាពខាងនយោបាយ។ ដូច្នេះខ្ញុំយកមកខ្ញុំអប់រំ ខ្ញុំដឹងខុស ដឹងត្រូវរបស់ខ្ញុំ អ្នកណាប៉ានមកចាប់អង្គភាពតែផ្ដេសតែផ្ដាសអត់បានទេ។ ដូច្នេះខ្ញុំអប់រំ ខ្ញុំអី គ្រប់គ្រងរបស់ខ្ញុំ ដើម្បីទាំងអស់គ្នាទៅបម្រើបក្ស។ នេះជាភារកិច្ចរបស់កម្មាភិបាលមួយៗទៅលើអង្គភាពរបស់គេ។ នេះវាមានន័យអ៊ីចឹង។

**ស៖** លោកក៏បាននិយាយដែរថា នៅក្នុងដំណើរការនេះ បើសិនជាគេចង់ធ្វើម៉េចកុំឲ្យមានកំហុសនោះ កុំឲ្យមានភ័ន្តច្រឡំនោះ តើលោកយល់ថាមានន័យដូចម្ដេចដែលថាធ្វើម៉េចកុំមានកំហុសឬមានការភ័ន្តច្រឡំនោះនៅពេលដែលមានគេឆ្លើយដាក់អ្នកណាម្នាក់នោះ?

**ឆ៖** ត្រូវហើយ នេះហើយដែលគេហៅថា អនុវត្តប្រជាធិបតេយ្យប្រមូលផ្ដុំនោះមួយបែប។ ខាងលើយល់ស្របជាគោលការណ៍ តែជាក់ស្ដែងខាងក្រោមក៏រួមចំណែកហ្នឹងដែរ។ ទាំងអស់គ្នាទទួលខុសត្រូវចំពោះមុខបក្ស។

[១៣:៤៥:៥៣]

**ស៖** ដូច្នេះ យើងអាចយល់ពាក្យនេះនៅក្នុងពាក្យជាក់ស្ដែង ដែលលោកនិយាយថាចម្លើយសារភាពនោះត្រូវបានបញ្ជូនទៅប្រធានអង្គភាពសាមីនោះ មានមូលហេតុពីរ។ មួយ គឺដើម្បីជូនដំណឹងទៅដល់ប្រធាននោះអំពីសកម្មភាពខ្មាំង ហើយពីរដើម្បីអនុញ្ញាតឲ្យគាត់បានសម្របសម្រួល ឬក៏បានដឹងថានឹងមានការចាប់ខ្លួនអ្នកដែលគេឆ្លើយដាក់ ហើយចម្លើយសារភាពនោះ គឺត្រូវបានគេបញ្ជូនទៅដើម្បី

ឲ្យគេប្រាកដថាប្រធានអង្គភាពសាមីនោះគឺថា មាន-- ឧទាហរណ៍បើមានកំហុស គឺថាគេឆ្លើយដាក់ដោយកំហុសនោះ ដោយភ័ន្តច្រឡំ គឺថាគាត់អាចពិនិត្យឡើងវិញថា តើមានកំហុស ឬក៏មិនមានកំហុសនៅក្នុងការឆ្លើយដាក់ហ្នឹង តើលោកអាចពន្យល់បន្ថែមបានទេ?

**ឆ៖** អរគុណ។ សូមគោរពលោកប្រធាន។ បញ្ហានេះ គេអត់ជជែកគ្នាទេ កាលណាសំណុំរឿងទៅពីខាងលើ ខាងលើប្រគល់ទៅឲ្យ ដូចរឿងបង សុន សេន គាត់សរសេរអ៊ីចឹង "ជូន មិត្តតាល់ ពិនិត្យ" មិត្តតាល់ យកទៅដល់ ពិនិត្យ។ ដូច្នេះ គេសម្រេច។ រួចសម្រេច គឺខ្ញុំសូមប្រគល់ជូនអង្គការប៉ុណ្ណេះ ឯចំណែកប៉ុណ្ណេះទៀត ខ្ញុំទុកសិន តាមដានតទៅទៀត អប់រំតទៅទៀត។ គេនិយាយប្រើពាក្យអ៊ីចឹង គេមិនប្រកែកយកចាញ់ យកឈ្នះ យកភស្តុតាងអីៗទេ។ គេនិយាយអ៊ីចឹង។

ដូច្នេះ ទាំងអស់គ្នារួមចំណែកទទួលខុសត្រូវក្នុងការចាប់ខ្លួនយុទ្ធជន និងកម្មាភិបាលមួយចំនួនណាដែលនៅក្រោមការគ្រប់គ្រងរបស់ខ្លួន។ នេះគឺអ៊ីចឹង។

[១៣:៤៨:០១]

**ស៖** ជាពិសេស ហេតុអ្វីបានជាគេបញ្ជូនចម្លើយសារភាព? ហេតុអ្វីបានជាអនុវត្តទម្លាប់ការបញ្ជូនទៅឲ្យប្រធានអង្គហេតុ មិនទុកឲ្យប្រធានអង្គភាពសាមីនោះពិនិត្យ ហើយនិងសម្រេចក្នុងការចាប់ខ្លួនអ្នកដែលគេឆ្លើយដាក់?

**លោក កាំង ហ្គេកអ៊ាវ៖**

សូមទោសលោកប្រធាន! ខ្ញុំអត់ទាន់យល់សំណួរនេះទេ សូមឲ្យព្រះរាជអាជ្ញាបញ្ជាក់ឲ្យស្រួល។

**លោក វីល្លៀម ស្មីត៖**

ខ្ញុំនឹងសម្រួលឃ្លានេះជូនលោក លោកប្រធានបាទ។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** លោកសាក្សី លោកបាននិយាយថា មានការអនុវត្តកាលណាចម្លើយសារភាពត្រូវបានគេបញ្ជូនទៅគណៈអចិន្ត្រៃយ៍ហើយ គណៈអចិន្ត្រៃយ៍បញ្ជូនទៅប្រធានអង្គភាពសាមី។ ហេតុមួយនោះ គឺថាដើម្បីពិនិត្យ និងឲ្យអ្នកហ្នឹងសម្រេចលើករណីដែលគេឆ្លើយដាក់ហ្នឹង?

សំណួរខ្ញុំហ្នឹង គឺថាហេតុអ្វីបានជាគេសួរយោបល់ឲ្យប្រធានអង្គភាពហ្នឹងត្រូវពិនិត្យសម្រេចនិងក្នុងករណីហ្នឹង?

[១៣:៤៩:២៥]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ សូមគោរពលោកប្រធាន។ បញ្ហាមានពីរ ទីមួយសភាពការណ៍ខ្មាំងនៅក្នុងអង្គភាព។ ទីពីរ មនុស្សដែលគេឆ្លើយពាក់ព័ន្ធនៅក្នុងអង្គភាព។ ជួនអីមនុស្សនោះ វាទង្គិចដល់ម្ចាស់អង្គភាពខ្លាំងពេក គេឲ្យស-២១ ដកឈ្មោះចេញសិន។ រួចដល់ក្រោយមក បានៗគេមើលទៅ ដល់ត្រឹមត្រូវបានគេធ្វើបញ្ជូនទៅ។ ឧទាហរណ៍ដូចករណី ឈូក។ ចម្លើយពាក់ព័ន្ធនឹង ឈូក យូរហើយ បើតាមខ្ញុំចាំគេមិនទាន់ឲ្យ សោ ភឹម ដឹងទេ។ គេឲ្យស-២១ ដកទុកសិន។ កាត់អាកន្លែងណាដែលត្រូវកាត់។ រួចហើយដល់ពេលណាមួយដែលជាកំណត់បានៗគេនេះទៅ គេអញ្ជើញ បងភឹម មកប្រជុំ។ នេះសភាពការណ៍មានពីរ បញ្ហាមានពីរ។ ទីមួយ ជាសភាពការណ៍រួមជាឧបាយកលខ្មាំងនៅក្នុងអង្គភាព។ ទីពីរ គឺសាមីខ្លួនដែលមានគេឆ្លើយដាក់។ បើសាមីខ្លួនដែលមានគេឆ្លើយដាក់នោះ វាទង្គិចដល់ម្ចាស់អង្គភាពពេក អាហ្នឹងគេលៃមើល គេដកទុកសិន។ នេះសូមបញ្ជាក់អ៊ីចឹង។

**ស៖** នៅពេលដែលលោកនិយាយថា អាចជាមានឧបាយកលនៅក្នុងអង្គភាពហ្នឹង ឧបាយកលក្នុងហ្នឹងតើឧបាយកលម៉េច? តើលោកអាចបន្ថែមបានទេ?

[១៣:៥១:០៦]

**ឆ៖** អរគុណ។ សូមគោរពលោកប្រធាន។ ឧបាយកលក្នុងអង្គភាពហ្នឹង គឺឧបាយកលដែលចម្លើយសារភាពវាលាតត្រដាង។ ចម្លើយសារភាពនីមួយៗវាលាតត្រដាងឧបាយកលខ្មាំងនៅក្នុងអង្គភាពនីមួយៗនោះឯង។

**ស៖** សូមអរគុណ។ អ៊ីចឹងសូមលោកមើលឯកសារ 43/IV ឧបសម្ព័ន្ធ៤៧ ជាឯកសារចុងក្រោយដែលយើងត្រូវពិនិត្យមើល។ សូមអនុញ្ញាតបង្ហាញនៅក្នុងអេក្រង់ តើលោកមានឯកសារនៅចំពោះមុខទេ គឺចម្លើយសារភាពរបស់ សាន់ ប៉ូ?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត មាននៅ?

**អ្នកបកប្រែ៖**

បាទសូមគេតម្រូវពីអ្នកបកប្រែ គឺចម្លើយសារភាពរបស់ សាន់ ប៉ូ។

**សួរដោយលោក វីណ្សៀម ស្មីត៖**

**ស៖** លោកសាក្សីតើលោកមានចម្លើយសារភាពរបស់ សាន់ ប៉ូ នៅចំពោះហើយឬនៅ? បាទ

ជាក្របរបស់ចម្លើយសារភាព។

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ខ្ញុំមានហើយ។

**ស៖** បាទអរគុណ គឺចុះនូវកាលបរិច្ឆេទ គឺឆ្នាំ១៩៧៨ ខែ៨។ នៅក្នុងក្របនេះ តើលោកស្គាល់ទេថាសំណេរផ្ទាល់ដៃនេះ? តើសរសេរថាម៉េច ហើយលោកស្គាល់ទេជាចំណាររបស់បុគ្គលណាដែរ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! មានការជំទាស់ពីមេធាវីការពារក្តី នួន ជា។

សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ មុនពេលសម្រាកសហព្រះរាជអាជ្ញាបានសួរសំណួរនេះទៅសាក្សីរួចហើយ បាទ គឺថាតាមសម្តីរបស់សាក្សីគឺជាសំណេររបស់ នួន ជា ហើយព្រះរាជអាជ្ញាបានប្រើសំណួរនាំមុខ។ ដូច្នេះខ្ញុំបាន-- ខ្ញុំសូមជំទាស់សំណួរនេះ។

**លោក វីណ្ឌៀម ស្មីត៖**

នេះគឺជាបញ្ហានៅក្នុងការយល់នេះ ដូចជួនកាលយើងមានការជំទាស់ទៅលើការពិភាក្សាទៅដល់ខ្លឹមសារ ប៉ុន្តែពេលខ្លះយើងចូលទៅ ជួនកាលភាគីបានធ្វើសេចក្តីពន្យល់ ហើយបានជំទាស់។ ដូច្នេះហើយការ សេចក្តីថ្លែងការណ៍ហ្នឹងគឺធ្វើឲ្យមានប៉ះពាល់ដល់ស្មារតីរបស់សាក្សី ដូច្នេះបើសិនជាគាត់ជំទាស់សូមឲ្យជំទាស់តាមគោលការណ៍ច្បាប់អនុញ្ញាត។ ដូច្នេះហើយ យើងបង្កើតការអនុវត្តនៅទីនេះ គឺថាបើជំទាស់ លោកជំទាស់កុំធ្វើសេចក្តីថ្លែងការណ៍។ បើដូច្នោះទេ សាក្សីនឹងយល់ថា គឺជាការតទាល់គ្នា គាត់ពិបាកយល់។ ដូច្នេះហើយយើងមិនបានធ្វើឡើងដោយចេតនា ដើម្បីបំពាននីតិវិធីទេ ដូចជានៅក្នុងឯកសារនេះ គឺថាគាត់បានបញ្ជាក់នៅក្នុងឯកសារនេះមួយចំនួន ដែលខ្ញុំនឹងសួរ ប៉ុន្តែមេធាវីនឹងសួរនៅពេលក្រោយ។ ប៉ុន្តែនៅពេលនេះ ខ្ញុំសួរឲ្យសាក្សីបញ្ជាក់ បាទ ហើយបើសិនជា លោកសាក្សីគាត់ឆ្លើយលើកក្រោយមេធាវីការពារក្តី លោកមានឱកាសនឹងសួរដដែលទេ។

**ប្រធានអង្គជំនុំ៖**

ជំទាស់របស់មេធាវីអន្តរជាតិការពារក្តី នួន ជា គ្មានប្រសិទ្ធភាព។ សាក្សីឆ្លើយតបនឹងសំណួរដែលបានសួរចុងក្រោយ ដោយតំណាងព្រះរាជអាជ្ញាអន្តរជាតិអម្បាញ់មិញនេះ ប្រសិនបើលោកនៅចាំ

សំណួរ។

[១៣:៥៥:៣៤]

**ឆ៖** អរគុណ។ ចំណារនៅលើក្រប នៃចម្លើយសារភាពរបស់ សាន់ ប៉ូ គឺជាចំណាររបស់បង នួន គឺ នួន ជា។

**ស៖** សូមអរគុណ។ នៅក្នុងចំណុចនេះ តាមបទពិសោធន៍ ឬក៏ការងាររបស់លោកនៅស-២១ តាមដែលលោកពិនិត្យចម្លើយសារភាព ថាតើមានពេលប៉ុន្មានដងដែលលោកបានឃើញ ឃើញនូវចំណាររបស់ នួន ជា នៅលើឯកសារទាំងនោះបាទ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន។ ខ្ញុំសូមបញ្ជាក់ថា នួន ជា មានសរសេរសំបុត្រមកខ្ញុំ។ គាត់មិនសរសេរច្រើនដូច សុន សេន ទេ។ ខ្ញុំស្គាល់អក្សរគាត់ ល្មមឲ្យខ្ញុំហ៊ាននិយាយថា ចំណារនេះជាចំណាររបស់គាត់។ ដូច្នេះ ប៉ុន្មានដងមុនឯកសារនេះ ឬក៏ខាងលើបង្ហាញឯកសារមកខ្ញុំប៉ុន្មានដង ខ្ញុំមិនចាំទេ ក៏ប៉ុន្តែឯកសារនេះពិតជាបានបង្ហាញ មកឲ្យខ្ញុំអធិប្បាយ មកឲ្យខ្ញុំពន្យល់នៅក្នុងរយៈកាលស៊ើបអង្កេត ហើយខ្ញុំបានឆ្លើយអ៊ីចឹងដដែលហ្នឹង។ ចំណារនេះគឺជាចំណាររបស់ បងនួន។

[១៥:៥៧:៣២]

**ស៖** ដើម្បីបញ្ចប់សំណួរចុងក្រោយនៃឯកសារនេះ តើចំណារហ្នឹង គឺមានខ្លឹមសារម៉េច? បើអានហ្នឹង អានដូចម្ដេចកើតបាទនៅក្នុងប្រអប់នេះបាទ?

**ឆ៖** អរគុណលោកប្រធាន។ ខ្ញុំសូមបញ្ជាក់ សូមអនុញ្ញាតលោកប្រធានបញ្ជាក់ជូនលោកព្រះរាជអាជ្ញាបន្តិច ប្រអប់ដែលគូរនៅលើឯកសារដែលយើងកាន់នេះ ហើយប្រអប់ដែលគូរនៅលើឯកសារដែលបញ្ចាំងនេះ មិនត្រូវគ្នាទេៗ។ សូមឲ្យគេកែឲ្យដូចគ្នាទៅ។ ប្រអប់ដែលយើងគូរនៅលើឯកសារនេះ ប្រអប់ដែលយើងគូរនៅលើឯកសារដែលខ្ញុំកាន់នៅហ្នឹងដែរនេះ ហើយប្រអប់ដែលគូរនៅក្នុងឯកសារដែលៗនេះ ដូចហើយ។ អរគុណ។ ខ្ញុំសូមអនុញ្ញាត--

**ស៖** សូមអរគុណ។

**លោក ម៉ៃខល ផេសមិន៖**

តើឯកសារណា តើប្រអប់ណាដែលលោកនិយាយនោះ?

**សួរដោយលោក វីណ្ឌៀម ស្មីត៖**

**ស៖** គឺឯកសារដដែលនេះឯង ដែលបង្ហាញ ហើយខ្ញុំគ្រាន់តែជូនឯកសារលើក្រដាសទៅគាត់

ឲ្យគាត់មើលក្នុងប្រអប់ក្រហម មានចំណារផ្ទាល់ដៃពីរនៅខាងលើនៃក្រដាសនេះ ហើយនៅក្នុងអេក្រង់ពីមុននោះគឺថា ដែលយើងគូសបញ្ជាក់ដោយសហព្រះរាជអាជ្ញា។ ឥឡូវនេះគឺដូចគ្នាបេះបិទគឺ 0017432 បាទ។ បាទ គឺជាចម្លើយសារភាពរបស់ សាន់ ប៉ូ ហើយឲ្យលោកសាក្សីគាត់អានខ្លឹមសារដែលនៅក្នុងប្រអប់ក្រហមនេះ ថាតើអានដាច់ទៅអានដូចម្ដេច? ដូច្នេះចម្លើយ អ៎!ចំណារនៅខាងឆ្វេងដៃខាងលើ តើនិយាយថាម៉េច?

**ឆ៖** សូមគោរពលោកប្រធាន។ ចំណារនៅខាងឆ្វេងដៃអានថា "សមមិត្ត វ៉ាន់"។

**ស៖** បាទអ្នកណាជាសមមិត្ត វ៉ាន់?

**ឆ៖** សមមិត្ត-- អរគុណ។ សមមិត្ត វ៉ាន់ គឺ អៀង សារី។

**ស៖** សូមអរគុណ។ ខ្ញុំបញ្ចប់ជាមួយឯកសារនេះហើយ ឥឡូវនេះខ្ញុំចង់ចូលឲ្យលោកចាប់អារម្មណ៍លើឯកសារ D108/26.282។ បាទសូមអនុញ្ញាតតុលាការដាក់តាំងឯកសារនេះនៅលើអេក្រង់ផងដែរ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ហើយមន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញាជូនទៅសាក្សីដើម្បីពិនិត្យ!

[១៤:០១:០៨]

**សួរដោយលោក វីណ្សៀម ស្មីត៖**

**ស៖** លោកសាក្សី ឯកសារនេះ គឺជាតារាងដែលនិយាយអំពីក្រសួងការបរទេស។ សូមលោកពិនិត្យមើលទៅលើឯកសារនេះ ហើយបញ្ជាក់ថាតើលោកធ្លាប់ឃើញឯកសារនេះពីមុនដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ឯកសារនេះគឺជាឯកសារស-២១។

**ស៖** តើលោកធ្លាប់ឃើញឯកសារនេះពីមុនដែរទេ? បានន័យថាមុនថ្ងៃនេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ឯកសារនេះគឺសរសេរចេញពីស-២១។ ដូច្នេះចៀសមិនរួចពីខ្ញុំបានឃើញនោះទេ។ តែខ្ញុំគ្រាន់តែមិនចាំ។

**ស៖** តើលោកអាចជម្រាបបានដែរឬទេ ថាតើលោកចាំឬក៏លោកស្គាល់ឯកសារនេះដោយរបៀបណា?

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន គឺថានៅពេលនេះយើងដឹងអំពីច្បាប់ទម្លាប់ហើយ ដែលថាឯកសារនេះត្រូវដកចេញ ហើយអ្វីដែលសំខាន់គឺថា គាត់បាននិយាយថា គាត់ស្គាល់ឯកសារនេះ ដូច្នេះយើងមិនមែន ដូច្នេះ គឺថាលោក លោកស្រីចៅក្រមអាចមានសិទ្ធិសម្រេច ថាតើទុកឯកសារនេះ ឬមួយក៏យ៉ាងម៉េច ដើម្បីបញ្ជាក់អំពីយថាភាពនៃឯកសារនេះ។

[១៤:០៣:១៨]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីជាតិការពារក្តីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទសូមអរគុណលោកប្រធាន។ តាមស្តាប់សម្តីរបស់សាក្សីដែលឆ្លើយអម្បាញ់មិញនេះ តបទៅនឹងសំណួររបស់សហព្រះរាជអាជ្ញាហ្នឹងគឺថា ឯកសារនេះគាត់មិនបានដឹងថាបានទទួលពីមុនមកទេ ប៉ុន្តែការសន្និដ្ឋានមួយរបស់គាត់ ដោយសារគាត់គិតថាឯកសារនេះយកចេញពីទួលស្លែង។ អ៊ីចឹងគាត់សន្និដ្ឋានថាគាត់បានទទួល។ អ៊ីចឹងទីមួយចៅក្រមអាចសួរបញ្ជាក់ឲ្យច្បាស់ទៅលើចំណុចនេះ ឬក៏អាចបដិសេធឯកសារនេះចោលតែម្តង។ បាទសូមអរគុណ។

[១៤:០៤:០២]

**លោក វីល្លៀម ស្មីត៖**

លោក លោកស្រីចៅក្រម នេះគឺជាហេតុផលមួយដែលខ្ញុំ ដែលថានៅសប្តាហ៍ក្រោយ គឺយើងនឹងមានសវនាការទៅលើបញ្ហាមួយនេះ ដែលថាទាក់ទងទៅនឹងបុគ្គលដែលអាចបង្ហាញពីយថាភាពនៃឯកសារនេះ ហើយនៅឱកាស ហើយៗឱកាសនេះយើងធ្វើការសាកសួរគាត់ដោយសារគាត់ធ្លាប់ជាប្រធានមន្ទីរស-២១ ប្រហែលជាគាត់អាចជួយបាន។ ប៉ុន្តែតាមការពិតដែលថា ដោយសារតែគាត់មិនមានឱកាសពីមុនមកនោះ ដូច្នេះវាហាក់ដូចជាមិនយុត្តិធម៌នោះទេ ដែលសម្រាប់គ្រប់ភាគីទាំងអស់មិនអាចបង្ហាញអំពីយថាភាពនៃឯកសារនេះ។ ទោះបីថាគាត់ ថាស្គាល់ ឬក៏មិនស្គាល់។ ប៉ុន្តែបញ្ហាសំខាន់ យើងមិនចាំបាច់លើកពិភាក្សានៅថ្ងៃនេះទេ។ ប៉ុន្តែខ្ញុំសូមស្នើថានៅក្នុងករណីនេះ យើងគួរតែលើកយកការពិភាក្សាពេញលេញទៅទុកនៅសប្តាហ៍ក្រោយ។ ធ្វើៗដូច្នេះ គឺថាអាចឲ្យថាគាត់មានឱកាសមួយនៅក្នុងពេលនេះ។ បានន័យថា នេះគឺជាបញ្ហាមួយ ដែលថាសំណាង ជារឿងរ៉ាវសំណាង ពី

ព្រោះថាអាចថាគាត់ធ្លាប់ស្គាល់ ឬក៏គាត់មិនធ្លាប់ស្គាល់។ បានន័យថាអាចថាគាត់ដឹង ឬក៏គាត់មិនដឹងពីឯកសារពីនេះ។ សូមអរគុណ។

[១៤:០៥:១៩]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:០៥:៥៥]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចអនុញ្ញាតឲ្យសាក្សីទុកឯកសារនេះនៅក្នុងដៃ ហើយនិងឲ្យតំណាងសហព្រះរាជអាជ្ញាបន្តការតាំងសួរដេញដោល ចំពោះសាក្សីរូបនេះ។

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** សាក្សី លោកនិយាយថា លោកមិនដែលបានឃើញពីមុនទេ ប៉ុន្តែលោកស្គាល់ថាវាជាឯកសារ ស-២១។ តើលោកអាចពន្យល់បានដែរឬទេ ថាតើលក្ខណៈពិសេសអ្វីខ្លះនៃឯកសារនេះ ដែលធ្វើឲ្យលោកសន្និដ្ឋាន ថាវាជាឯកសាររបស់មន្ទីរស-២១?

[១៤:០៦:៥៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសង្កេតឃើញថា គឺសង្កេតឃើញថាមានបញ្ហានេះ ដូចជាកើតពីមុនមកដែរ គឺថាព្រះរាជអាជ្ញាបង្ហាញឯកសារដែលមានលេខកូដ ដែលៗបង្ហាញទៅដល់សាក្សី ហើយដើម្បីឲ្យសាក្សី គាត់បង្ហាញថាគាត់ស្គាល់ពីលេខកូដហ្នឹង គឺគាត់ដឹងថាឯកសារហ្នឹងមកពីណា។ ដូច្នេះ ខ្ញុំស្នើថា ព្រះរាជអាជ្ញាលើកក្រោយ នៅពេលដែលសួរសំណួរបែបនេះ គួរតែគ្របដណ្តប់ ឬក៏បិទបាំងនូវលេខកូដ ដើម្បីកុំឲ្យសាក្សីគាត់ស្គាល់លេខកូដនេះ។ ដើម្បីឲ្យគាត់-- ដើម្បីកុំសាក្សីដឹងថាឯកសារនេះទទួលបានមកពីអង្គភាព ឌី.ស៊ី.ខេម។ ខ្ញុំមិនចង់និយាយអ្វីឲ្យច្រើននោះទេ។ សូមអរគុណ។

[១៤:០៧:៤៦]

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាបន្តការសួរដេញដោល!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោក លោកស្រីចៅក្រម។ ខ្ញុំដឹងអំពីលេខកូដនេះ ហើយនិងខ្ញុំពិនិត្យ។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** លោកសាក្សីទាក់ទងទៅនឹងឯកសារនេះផ្ទាល់ បានន័យថា លក្ខណៈពិសេសនៃឯកសារនេះ ថាតើលោកអាចជម្រាបអង្គជំនុំជម្រះបានដែរឬទេ ថាហេតុអ្វីបានជាលោកអាចស្គាល់ថា ឬក៏លោកអាចដឹង ថាឯកសារនេះជារបស់ស-២១?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ សូមគោរពលោកប្រធាន។ ឯកសារនេះ វាជាទម្រង់ការងារមួយរបស់ ស-២១ ដែលយូរៗ ពេលកុនការម្ដងៗខាងលើឲ្យសរុប។ តើបុគ្គលណាដែលត្រូវគេឆ្លើយដាក់ប៉ុន្មាននាក់? នេះវាមានជាហូរហែ។ ដូច្នេះនៅក្នុងនេះ មានតែមិត្ត ឆន ហៃ ទេ នៅមន្ទីរប-១ ដែលត្រូវគេឆ្លើយដាក់ពីរនាក់។ ក្រៅពីនោះ អ្នកផ្សេងទៀតត្រូវគេឆ្លើយដាក់ម្នាក់ៗ។ នេះជាទម្រង់ការងាររបស់មន្ទីរស-២១ ដែលយើងខ្ញុំស្គាល់ច្បាស់។

ហើយសូមបញ្ជាក់ជូនអង្គប្រជុំ ជូនលោកប្រធានថា លេខកូដនេះ វាជួយឲ្យខ្ញុំយល់ ហើយនិងបំភ្លឺតុលាការបាន ថាឯកសារនេះ វាអត់ចេញពីស-២១ ទេ វានៅនឹងស-២១ បានជាគ្មានស៊ីញ៉េខ្ញុំ។

**ស៖** សូមអរគុណ។ នៅពេលដែលលោកនិយាយថា តារាងមួយនេះ គឺបង្កើតនៅស-២១។ តើតារាងបែបនេះ ធ្វើការគណនាថាតើមានអ្នកផ្ដល់ចម្លើយសារភាពប៉ុន្មាន? ហើយតើអ្នកដែលឆ្លើយដាក់គេហ្នឹងវាមានប៉ុន្មាននាក់ តើមែនដែរឬទេ?

[១៤:១០:១៧]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន នៅក្នុងតារាងពីរសន្លឹកនេះ អ្នកដែលត្រូវគេឆ្លើយដាក់មាន៣០នាក់ ហើយមានតែម្នាក់គត់នៅក្នុងលេខរៀងទី១៤ បានត្រូវបានគេឆ្លើយដាក់ពីរនាក់។ ម្នាក់អ្នកឆ្លើយដាក់ឈ្មោះ ស្រី ដួង ម្នាក់ទៀតដែលឆ្លើយដាក់ឈ្មោះ មល់ ភូរិ ហៅ ភឿន ឆ្លើយដាក់លេខរៀងទី១៤។ ឯចំណែកអ្នកដែលឆ្លើយដាក់គេហ្នឹងទាំងអស់ មួយ, ពីរ, បី, បួន, ប្រាំៗនាក់។

**ស៖** ហេតុអ្វីក៏បញ្ជីនេះមានចំណងជើងថា "ក្រសួងការបរទេស" ហើយមានឈ្មោះ២៩នៅក្នុងបញ្ជីនេះ? ហើយក្នុងហ្នឹងមានតួនាទី ព្រមទាំងអាសយដ្ឋាន ហេតុអ្វីក៏តារាងនេះ បញ្ជីនេះមានចំណងជើងថា "ក្រសួងការបរទេស" ទៅវិញ?

[១៤:១១:៤៨]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន។ ក្រសួងការបរទេសនេះ គឺអ្នកឆ្លើយដាក់គេ និងអ្នកត្រូវគេឆ្លើយដាក់ គឺសុទ្ធតែមនុស្សនៅក្នុងក្រសួងការបរទេស។

**ស៖** ថាតើមានអ្វីកើតឡើងចំពោះតារាងមួយនេះ? តើមានអ្វីកើតឡើងដែរ ឬមួយក៏អត់មានអ្វីកើតឡើងទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន។ តារាងនេះវាអត់ទាន់ផ្ញើទៅដល់ដៃអចិន្ត្រៃយ៍ទេ។ ដូច្នេះគ្មានអ្វីកើតឡើងទេ។ ឯចំណែកបុគ្គលនៅក្នុងលេខរៀងទី៩ នេះក៏នៅរស់។

**ស៖** តើអ្នកណាជាអ្នករៀបចំបញ្ជីនេះនៅមន្ទីរស-២១?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន។ កូនចៅខ្ញុំខាងសួរចម្លើយច្រើន ហើយឯកសារនេះគេអត់ទាំងស៊ីញេផង។ ដូច្នេះខ្ញុំមិនអាចកំណត់បានថា អ្នកណាជាអ្នករៀបចំទេ។

**ស៖** ថាតើអ្នកណាស្នើឲ្យមានការវិភាគអំពីការឆ្លើយសារភាព ហើយនិងការវិភាគអំពីអ្នកដែលត្រូវគេឆ្លើយដាក់ នៅតាមរបៀបបែបនេះ?

**ឆ៖** របៀបបែបនេះ តាំងពីសម័យ សុន សេន។ ខ្ញុំជឿថា ការដែលយើងខ្ញុំទៅប្រជុំនៅថ្ងៃ១៦ ខែកញ្ញា ១៩៧៦ នេះ គ្នាលើសពី៣០នាក់ ត្រូវបានគេសរុបតាមរបៀបនេះ។ ហើយគេជ្រើសរើសយកតែប៉ុន្មាន ២៩នាក់ចេញ។ ដូច្នេះពេលនេះ បញ្ជាពីខាងលើមក នៅក្នុងពេលដែលចម្លើយហ្នឹងវាហូរហែទៅហើយ បញ្ជាពីខាងលើមកឲ្យយើងធ្វើរបៀបនេះម្តង។ ក៏ប៉ុន្តែដល់ក្រោយមក មិនដឹងយ៉ាងម៉េចបានៗជាតារាងនេះមិនត្រូវបានបញ្ជូនទៅលើ ហើយអ្នកដែលធ្វើការសរុបនេះ ក៏មិនបានចុះហត្ថលេខាបញ្ជូនឲ្យមកខ្ញុំ។ តារាងដែលធ្វើរបៀបនេះច្រើន មិនមែនតិចទេ ហើយបើតាមខ្ញុំចាំតារាងទីមួយ គឺអាតារាងដែលយើងយកទៅពិភាក្សាគ្នានៅថ្ងៃ១៦ ខែ៩ ឆ្នាំ១៩៧៦។

**ស៖** ដូច្នេះ ដើម្បីឲ្យច្បាស់ថាតើព័ត៌មានដែលមាននៅក្នុងបញ្ជីនោះ ថាតើព័ត៌មាននេះត្រូវបញ្ជូនផ្ទាល់ទៅមេកោយរបស់លោក ឬមួយក៏អត់នោះទេ?

**ឆ៖** ខ្ញុំបានបញ្ជាក់ហើយ ភស្តុតាងដែលថាឯកសារនេះ វាមិនចេញផុតពីស-២១ វាមានពីរ

សំខាន់មានពីរ តែតាមពិត យើងអាចនិយាយបានថាមានបីផង។ ព្រោះអ្នកដែលសរុបចម្លើយនេះ ក៏អត់មានឈ្មោះស៊ីញ៉េ។ ក៏ប៉ុន្តែសំខាន់ គ្មានចំណារខ្ញុំ សរសេរជូនទៅខាងលើ បើខ្ញុំជូនទៅខាងលើ គឺមានចំណារខ្ញុំហើយ “គោរពជូនបង”។ អត់ ហើយដល់អត់ TSL នេះវាបញ្ជាក់ថាឯកសារនេះ គេប្រមូលពីទួលស្លែង មិនមែនប្រមូលពីអចិន្ត្រៃយ៍ទេ មន្ទីរមជ្ឈិមទេ។ ដូច្នេះ ឯកសារនេះអត់បានជូនទៅខាងលើទេ។

[១៤:១៦:៤០]

**ស៖** ដូច្នេះ តើលោកអាចសម្រេចបានដែរឬទេ ថាតើបញ្ជីឈ្មោះ ឬក៏ឈ្មោះបុគ្គលទាំងអស់នេះនឹងត្រូវបញ្ជូនទៅលើ ឬក៏អត់?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន។ បញ្ជីនេះអត់បញ្ជូនទៅលើទេ។

**ស៖** ហេតុអ្វីបានបញ្ជីនេះ គេមិនបញ្ជូនទៅថ្នាក់លើ?

**ឆ៖** បញ្ហាច្បាស់លាស់ពេកអ៊ីចឹងឆ្លើយមិនរួចទេ ប៉ុន្តែខ្ញុំគ្រាន់ជូនជាការសង្កេត។ មានតែលេខរៀងទី១៤មួយទេ ដែលមានមនុស្សឆ្លើយដាក់ពីរនាក់។ ឯក្រៅពីនោះ សុទ្ធតែមានមនុស្សឆ្លើយដាក់ម្នាក់ៗទាំងអស់។ នេះយើងសង្កេតឃើញប៉ុនន៉ុង។ ដូច្នេះបញ្ជូនទៅខាងលើ ក៏ប្រហែលជាខាងលើពិបាកពិចារណា ម្ល៉ោះហើយខ្ញុំផ្អាកទុកចោល មិនបញ្ជូនបញ្ជីនេះទៅ។

**ស៖** ដូច្នេះ យើងយល់ច្បាស់ថា ប្រហែលជាមិនមែនក្នុងករណីមួយនេះទេ ប៉ុន្តែជាទូទៅបានន័យថា តើលិខិតដែលគេនិយាយអំពីអ្នកដែលគេឆ្លើយដាក់ហ្នឹង គេបញ្ជូនទៅមេកោយហ្នឹងញឹកញាប់ប៉ុនណាដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន។ ឯកសារជាចម្លើយផ្ទាល់ខ្លួនម្នាក់ៗផ្ញើទៅជាប់លាប់ ក៏ប៉ុន្តែក្នុងករណីខ្លះ មេឲ្យសរុបបែបនេះ។ ដូច្នេះមិនច្រើនពេកទេ។

[១៤:១៩:១០]

**ស៖** ដូច្នេះ នៅពេលដែលលិខិតនេះ ប្រសិនបើតារាងនេះត្រូវបានចុះហត្ថលេខា ហើយបញ្ជូនទៅក្រៅ តើលោកដឹងទេថា តើតារាងបែបនេះនឹងត្រូវបញ្ជូនទៅអ្នកណាដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន។ បើសិនជាឯកសារដែលបញ្ជូនទៅខាងលើ ខ្ញុំត្រូវតែបញ្ជូនទៅអចិន្ត្រៃយ៍មជ្ឈិមបក្ស។ ដំបូង គឺបញ្ជូនទៅ សុន សេន ចាប់តាំងពីថ្ងៃ១៥ ខែសីហា ១៩៧៧ មកខ្ញុំបញ្ជូនទៅ នួន ជា។

**ស៖** សូមអរគុណ។ ហើយសំណួរចុងក្រោយរបស់ខ្ញុំទៅលើបញ្ហាមួយនេះ គឺថាតើមានគោលនយោបាយដែរឬទេ ដែលចែងថា តើមានពេលប៉ុន្មានដង ឬមានប៉ុន្មាននាក់ដែលត្រូវឆ្លើយដាក់មុនពេលដែលត្រូវវាយការណ៍ទៅមេកោយរបស់លោក? បានន័យថាតើមនុស្សម្នាក់ត្រូវឲ្យគេឆ្លើយដាក់ប៉ុន្មានដងដែរ ទើបត្រូវវាយការណ៍ទៅលើ?

[១៤:២០:៥១]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន។ ឯកសារសារភាពរបស់បុគ្គលផ្ញើទៅទាំងអស់។ តែការសរុបបែបនេះយូរៗម្តង។ ដូច្នេះកាលណាបើឆ្លើយដាក់តិចពេកអ៊ីចឹង ខ្ញុំមិនបញ្ជូនទៅ ឬក៏ថាមេមិនទារអាហ្នឹងក៏វាជាបញ្ហាម្យ៉ាង។

**ស៖** សូមអរគុណ។ ខ្ញុំសូមបញ្ចប់ឯកសារមួយនេះ តើលោកអាចនិយាយបានដែរឬទេ ថាតើមនុស្សប្រភេទណានៅក្នុងក្រសួងការបរទេស ដែលៗត្រូវបានគេបញ្ជូនមកមន្ទីរស-២១?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន។ មនុស្សដែលគេបញ្ជូនមកមន្ទីរស-២១ គឺមនុស្សដែលមានចម្លើយ ហើយអចិន្ត្រៃយ៍ និងម្ចាស់អង្គភាពសម្រេចចាប់។ នុ៎ងទើបបានបញ្ជូនមកដល់មន្ទីរស-២១។

**ស៖** សូមអរគុណ។ តើលោកអាចនិយាយបានដែរឬទេ ថាតើការងារជាក់លាក់បែបណារបស់បុគ្គលិកនៅក្រសួងការបរទេស ដែលត្រូវគេបញ្ជូនមកមន្ទីរស-២១? តើមនុស្សដែលមានការងារជាក់លាក់បែបណា ដែលគេបញ្ជូនមកមន្ទីរស-២១នោះ?

[១៤:២៣:១២]

**ឆ៖** ខ្ញុំដូចគ្មានឃើញក្រឹត្យក្រមអ្វី ក្រៅអំពីក្រឹត្យក្រមដែលខ្ញុំវាយការណ៍ទាំងពីរនេះទេ។ ទីមួយគឺមានចម្លើយសារភាព ដែលស-២១ជូនទៅ។ ទីពីរ គឺអចិន្ត្រៃយ៍បញ្ជូនទៅឲ្យម្ចាស់អង្គភាពរួមចំណែកសម្រេច។ កាលណាគេចំណែកទាំងពីរនេះ គេសម្រេចហើយបានៗគេបញ្ជូនមកស-២១ នេះជាក្រឹត្យក្រមទូទៅ។ ដូចគ្មានឃើញក្រឹត្យក្រមអីក្រៅពីនេះទៀត ដើម្បីនឹងជម្រាបតុលាការទេ។

**ស៖** សូមអរគុណ។ យើងសូមបញ្ចប់ឯកសារមួយនេះ។ លោកបានបញ្ជាក់ពីកាលលើកមុនថា នួន ជា បានបញ្ជូន បានប្រាប់លោកថា ឲ្យដកឈ្មោះ ខៀវ សំផន ចេញពីចម្លើយសារភាពមួយ ដើម្បីកុំឲ្យវាមានបញ្ហា ដើម្បីកុំឲ្យវាមាន-- ប្រសិនបើមិនដូច្នេះទេលោកនឹងត្រូវធ្វើទូត។ តើលោកចាំអំពីសក្ខីកម្មមួយនេះដែរឬទេ?

**ធ៖** ជម្រាបប្រសាសន៍លោកប្រធាន។ មុននឹងខ្ញុំធ្វើសក្ខីកម្មនេះជូនការិយាល័យសហចៅក្រមស៊ើបអង្កេត។ ខ្ញុំបាននិយាយហូរហែ ជាពិសេសខ្ញុំបានប្រាប់ គ្រីស្ទប៉ែស្ទ៍ ទៅទៀតព្រោះវាចេញពីព្រឹត្តិការណ៍ជាក់ស្តែងមួយដែលកើតឡើង។ ព្រឹត្តិការណ៍នេះ ខ្ញុំចាំអត់ភ្លេចទេ។ ដូច្នេះសក្ខីកម្មរបស់ខ្ញុំវាចេញពីព្រឹត្តិការណ៍ជាក់ស្តែងមួយហ្នឹង។ ពេលនេះ ក៏ខ្ញុំអាចនិយាយបាន ពីម្សិលមិញក៏ខ្ញុំអាចនិយាយបាន ទៅថ្ងៃមុខទៀតក៏ខ្ញុំអាចនិយាយបាន។ ដូច្នេះសក្ខីកម្មនេះ វាចេញពីព្រឹត្តិការណ៍ជាក់ស្តែង។ ខ្ញុំអត់មានភ្លេចទេ។

**ស៖** សូមអរគុណ។ ប៉ុន្តែថាតើតាមដែលលោកយល់ ថាតើ នួន ជា គាត់ចង់មានន័យយ៉ាងដូចម្តេចដែរ នៅពេលដែលគេនិយាយថា នឹងបញ្ជូនលោកទៅធ្វើការទូត? តើអាឃ្លាមួយហ្នឹងវាមានន័យយ៉ាងដូចម្តេចដែរចំពោះលោក?

[១៤:២៦:០៥]

**ធ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ក្នុងប្រវត្តិ ណាត ដែលតុលាការបានដឹង។ ណាត មុនដំបូងនៅខាងយោធាទេ ដល់ក្រោយមកគេដកពីយោធាយកទៅធ្វើទូត។ កែ គឹមហួត ពីដើមគាត់ធ្វើលេខានៅនែតំបន់មួយនៅខាងពាយព្យ គេដកគាត់យកមកធ្វើទូត។ ឆាយ គឹមហ៊ី ពីដើមនៅថាមពល ដកយកទៅធ្វើទូត។ ដូច្នេះពាក្យធ្វើទូតហ្នឹង គឺ គេត្រៀមខ្លួនឲ្យសម្រាប់អ្នកទុំងមានលទ្ធភាពចូលមកស-២១ ទោះយូរ ឬឆាប់ ដើម្បីកុំឲ្យមនុស្សនេះទៅបំផ្លាញកម្លាំងរបស់គេ ផែនការរបស់គេ។ នេះន័យរបស់វាពិតប្រាកដ អ៊ីចឹង។ ហើយសូមបញ្ជាក់បន្ថែមថានៅពេលដែល បងនួន គាត់និយាយអ៊ីចឹងជាមួយខ្ញុំគាត់ដកខ្លួនថយបន្តិចវិញ។ គាត់ដកខ្លួនថា អ្ហះ! វាមិនស្អីទេ ធ្វើទូតក៏វាសប្បាយដែរ។ អាហ្នឹងវាមានន័យអ៊ីចឹងនេះ។

[១៤:២៧:២០]

**ស៖** តើលោកដឹងដែរឬទេ ថានៅពេល-- ប្រសិនបើលោកទៅខាងទូតនុំង តើវាជា-- តើវាមានលក្ខណៈអវិជ្ជមាន ឬថាតើវាជាការដែលប្រែប្រួលអវិជ្ជាមាន ឬមួយក៏វិជ្ជាមាន? បានន័យថា នៅពេលដែល ណាត គាត់ទៅផ្នែកខាងទូតហ្នឹងតើវាជាអ្វីមួយដែរ ដែលបង្ហាញថានឹងមានបញ្ហាកើតឡើងមែនឬក៏មិនមែន?

**ធ៖** ខ្ញុំសូមបញ្ជាក់ថា ណាត ភ័យខ្លួនតាំងពីអង្គការដកចេញពីស-២១ ម្ល៉េះ។ នៅស-២១ ណាត មានកម្លាំងកាន់កាប់មួយវរសេនាធំ។ ដកចេញពី ស-២១ ណាត ទៅនៅៗជំនួយការមជ្ឈិមអត់

មានកម្លាំងកាន់ក្តាប់ទេ។ ដូច្នេះមនុស្សយើងតែអត់កម្លាំងក្តាប់បានន័យថា បក្សអត់ជឿទុកចិត្តទេ។ លែងជឿទុកចិត្តហើយ។ ដូច្នេះទៅធ្វើទូតផុតកម្លាំងក្តាប់។ ដូច្នេះបានន័យថា បក្សលែងជឿទុកចិត្តហើយ។ នេះជាបញ្ហាជាក់ស្តែង ដូច្នេះម្នាក់ៗតែដល់នុំងភ័យ។ តែមិនដឹងដោះស្រាយយ៉ាងម៉េច ធ្វេចភ្នែកទ្រាំដល់ថ្ងៃចប់។

**ស៖** អ៊ីចឹងផ្នែកទូតហ្នឹង ថាតើពាក្យត្រឹមត្រូវ ឬក៏ពាក្យដែលថាមានជាលក្ខណៈផ្លូវការហ្នឹងតើការទូតហ្នឹងគេប្រើពាក្យអ្វីដែរ ជាពាក្យផ្លូវការ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ពាក្យ "ទូត" នេះប្រើជាផ្លូវការអ៊ីចឹងដដែល។ ក៏ប៉ុន្តែបុគ្គលដែលគេមិនជឿទុកចិត្ត គេដកធ្វើម៉េចឲ្យផុតពីកម្លាំង ដូច្នេះនិយាយពីមុខមាត់ទៅទូតហ្នឹងវាមានលក្ខណៈមានមុខមាត់បន្តិច នេះគឺសូមបញ្ជាក់ជូនអង្គជំនុំជម្រះប៉ុណ្ណេះ។

**ស៖** ដូច្នេះជាទូទៅកាលណាយើងនិយាយទូត គឺវាពាក់ព័ន្ធទៅនឹងការបរទេស។ ថាតើមានទំនាក់ទំនងអ្វីរវាងក្រសួងការបរទេសជាមួយនឹងផ្នែកទូតនេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន។ ក្រសួងការបរទេស វាមេលើទូត។ នេះបើតាមខ្ញុំយល់ក្រឹត្យក្រមជាទូទៅលើសកលលោក។

**ស៖** លោកចង់បញ្ជាក់ថាផ្នែកការទូត គឺជាផ្នែកមួយនៃក្រសួងការបរទេសឬ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន។ ក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ វាជាម្ចាស់អនុវត្តគោលនយោបាយការទូតរបស់បក្សកុម្មុយនីស្តកម្ពុជា។

**ស៖** ប៉ុន្តែលោកយោងទៅនោះ បាននិយាយថាធ្វើទូតហ្នឹង តើជាផ្នែកមួយនៃការទូតនៅក្នុងក្រសួងការបរទេស ឬក៏វានៅខាងក្រៅក្រសួងការបរទេស? ដូច្នេះដើម្បីឲ្យច្បាស់ចំណុចនេះ។

[១៤:៣១:៤៧]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំអត់យល់សំណួរនេះទេ។ សូមបញ្ជាក់ឲ្យស្រួល។

**ស៖** លោកបាននិយាយខាងដើមថា មនុស្សមួយចំនួនត្រូវបានបញ្ជូនផ្នែកការទូត ហើយលោកបាននិយាយពីរឿង ណាត ហើយនិងមនុស្សមួយចំនួនទៀត។ ខ្ញុំសួរលោកថា តើពាក្យថា "ទូត" ហ្នឹងដែលគេបញ្ជូនមនុស្សទៅហ្នឹង តើអាផ្នែកហ្នឹងនៅក្រសួងការបរទេស ឬក៏វានៅកន្លែងផ្សេងក្រៅពីក្រសួងការបរទេស?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ទូតវាជាមនុស្សដែលក្រសួងការបរទេសចាត់តាំងឲ្យចេញទៅតំណាងប្រទេសកម្ពុជាប្រជាធិបតេយ្យ។ ក៏ប៉ុន្តែជំនាន់នុ៎ង គេយកមនុស្សខ្លះដែលគេមិនឲ្យក្តាប់កម្លាំង គេមិនទុកចិត្ត តែមិនទាន់ឯកសារគ្រប់គ្រាន់ដើម្បីចាប់ គេឲ្យទៅធ្វើការទូត គេឲ្យទៅធ្វើទូត។ ដូច្នេះទៅធ្វើទូត វាផុតអំពីកម្លាំងសម្រាប់បះបោរប្រឆាំងនឹងគេ។ ដូច្នេះទូតដែលគេយកទៅដាក់ទណ្ឌកម្ម ហើយនិងទូតដែលគេបញ្ចេញទៅ អាហ្នឹងវាផ្សេង។ ដូចមិត្ត ជាង, ពេជ ថូ អ៉ន៉ែ ពេជ ជាង គេឲ្យធ្វើទូតនៅប៉េកាំងរហូត។ បងយ៉ែម ព្រឹកមិញ ស៊ឹម សុន នេះ គេឲ្យធ្វើទូតនៅកូរ៉េខាងជើងរហូត។ នេះជាទូតពិតប្រាកដដែលគេចាត់តាំងទៅ។ ក៏ប៉ុន្តែទូតនេះ ក្រោយនេះ ដូចយ៉ាង ណាត អីៗនេះ គេចាត់តាំងធ្វើម៉េចឲ្យដកចេញពីកម្លាំងសិន។ នេះជាវិធីគេមួយ។ ដូច្នេះសរុបមកវិញ ក្រសួងការបរទេស វាចាត់តាំងទូត។ ទូត ពិតប្រាកដ និងទូតដែលគេយកមកផ្តើលជើងចោលសិន។ ឯចំណែកការងារទូតរបស់ក្រសួងការបរទេស គឺវាជាការអនុវត្តមាគ៌ានយោបាយការទូតរបស់បក្សកុម្មុយនីស្តកម្ពុជា។

[១៤:៣៤:៣២]

**ស៖** សូមអរគុណលោក លោកស្រីចៅក្រម ខ្ញុំមើលម៉ោងឃើញថា ម៉ោងពីរសាមសិបប្អូននាទី តើលោកប្រធានចង់សម្រាក។ ប៉ុន្តែខ្ញុំមានសំណួរខ្លីមួយពីអយ្យការសុំស្នើមួយម៉ោងកន្លះនៅថ្ងៃចន្ទដើម្បីបញ្ចប់ ដោយសារថាមានបញ្ហាថ្មីផុសឡើងនៅក្នុងការពិនិត្យឯកសារ ហើយនិងមួយម៉ោងកន្លះនេះ គឺថាយើងខ្ញុំអាចបញ្ចប់បានបាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

អរគុណលោកប្រធាន។ យើងខ្ញុំសូមជំទាស់ទៅនឹងសំណើរបស់ព្រះរាជអាជ្ញា។ ប៉ុន្តែខ្ញុំ-- ថ្ងៃមុនខ្ញុំមិនជំទាស់ ប៉ុន្តែបើសិនជាគាត់អះអាងថា ផ្អែកលើការជំទាស់នេះ គាត់សុំបន្ថែម ក្រោយពីបីបួនប្រាំថ្ងៃមកនេះ គឺថាមានការសួរដដែលៗដោយសហព្រះរាជអាជ្ញា។ មានករណីខ្លះដែលសហព្រះរាជ-អាជ្ញាបានប្រើពេលហ្នឹងដើម្បីសង្ខេប ដើម្បីឲ្យសេចក្តីសន្និដ្ឋានរបស់គាត់។ ប៉ុន្តែគឺច្រើនជាងពេលសមស្រប ហើយគាត់មិនប្រើពេលគាត់ដោយប្រសិទ្ធភាពទេ។ យើងជំទាស់ចំពោះសំណើគាត់នេះ ប្រសិនបើគាត់មានប្រាំមួយថ្ងៃហើយជាមួយសាក្សីនេះ។ គប្បីតែគាត់បានបញ្ចប់ ហើយប្រើពេលដោយមានប្រសិទ្ធភាពក្នុងការពិនិត្យសាក្សី។ ហើយបើសិនជាការជំទាស់នោះដកចេញ គឺថាវាត្រូវដកចេញ

ដោយសារថាសំណួរជាច្រើនដែលគាត់សួរមិនត្រឹមត្រូវ អ៊ីចឹងយើងសូមជំទាស់។

[១៤:៣៦:១៥]

ថ្ងៃចន្ទគប្បីតែផ្តល់ទៅឲ្យដើម្បីបណ្តឹងរដ្ឋប្បវេណី ថ្ងៃអង្គារគប្បីតែមេធាវីការពារក្តីដើម្បីចាប់ផ្តើម។ សូមឲ្យអង្គជំនុំជម្រះរក្សាកាលវិភាគ ដើម្បីឲ្យយើងបញ្ចប់សាក្សីនេះមុនពេលតុលាការសម្រាកសវនាការ ដោយសារថាថ្ងៃចន្ទនោះ គឺថាគាត់នឹងជម្រាបថា យើងត្រូវការទៀត។ ហើយក្នុងរយៈពេលសម្រាកសប្តាហ៍យើងត្រូវការពីរម៉ោងទៀត បីម៉ោងទៀត បន្តទៀត។ នៅចំណុចខ្លះយើងនឹងត្រូវធ្វើដំណើរទៅមុខឲ្យបានឆាប់តែប៉ុណ្ណោះ។

សូមអរគុណ។

[១៤:៣៦:៤៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំបាទកត់សម្គាល់ឃើញមួយចំនួន ទាក់ទងនឹងសំណួររបស់សហព្រះរាជអាជ្ញា គឺថាគាត់បានលើកឡើងនូវសំណួរដែលមិនជាប់ពាក់ព័ន្ធទៅនឹងសាច់រឿងក៏មាន ហើយអនុញ្ញាតឲ្យសាក្សីឆ្លើយនូវចំណុចដែលមិនជាប់ពាក់ព័ន្ធនឹងសំណួរក៏មាន។ អ៊ីចឹងធ្វើឲ្យពេលវេលាហ្នឹងវាអស់ វាបាត់ច្រើន។ អ៊ីចឹងបើសិនជាអនុញ្ញាតឲ្យតំណាងអយ្យការសួរច្រើន ខ្ញុំគិតថាប្រហែលពុំមានអីថ្មីលើសពីនេះទៀតទេ។ បាទ សូមអរគុណ។

[១៤:៣៧:១៧]

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជំទាស់ទៅនឹងមតិដែលលើកឡើងរួចហើយ គឺថាសហព្រះរាជអាជ្ញា គឺថាបានប្រើពេលទៅតាមហ្នឹង ដោយមានប្រសិទ្ធភាពហើយ។ ការដែលគាត់ថាបែបនោះ គឺមិនសមស្របទេ ប៉ុន្តែយើងមានការលំបាក នៅពេលដែលយើងមានសាក្សី ឬក៏ភាគីផ្សេងៗដែលយើងមិនបានជួបពីមុន ដែលគាត់មកតុលាការ។ នេះជាបញ្ហាដ៏សំខាន់ ហើយគាត់នឹងមិនមកត្រឡប់វិញទេ

គឺលើកលែងតែថ្ងៃចន្ទ។ ខ្ញុំសូមតែមួយម៉ោងកន្លះទេ គឺមិនមែនពីរម៉ោងបីម៉ោងដូចមេធាវីការពារថានោះទេ។ ដូច្នេះដើម្បីៗឲ្យយើងមានការច្បាស់លាស់ ហើយដោយសារគាត់ជាសាក្សីដ៏សំខាន់ យើងអាចនឹងសុំពេលតែមួយម៉ោងកន្លះទៀតតែប៉ុណ្ណោះបាទ។

[១៤:៣៨:១៧]

**ប្រធានអង្គជំនុំ៖**

សូមៗអញ្ជើញមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**កញ្ញា លី ម៉ាញឿន៖**

សូមជម្រាបសួរលោក លោកស្រីចៅក្រម។ ដើមបណ្តឹងរដ្ឋប្បវេណីនេះ សូមជម្រាបថា អាចជាបញ្ហាដ៏ចម្បងចំពោះភាគីទាំងអស់ដែលថា ដើម្បីបណ្តឹងរដ្ឋប្បវេណីនឹងរីករាយប្រសិនបើផ្តល់ពេលមួយម៉ោងទៅឲ្យសហព្រះរាជអាជ្ញា ដែលជាពេលដែលយើងទទួលបានពីអង្គជំនុំជម្រះ។ សូមអរគុណ។

[១៤:៣៨:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយអនុរក្សមន្ទីរឃុំឃាំងអញ្ជើញសាក្សីទៅកាន់បន្ទប់រង់ចាំសម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៩ នាទី ដល់ម៉ោង ១៥:០០ នាទី)*

[១៤:៥៩:៣៤]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងបន្តផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ អង្គជំនុំជម្រះសូមសម្រេចនៅលើការស្នើសុំពេលវេលាអម្បាញ់មិញនេះ។ ទីមួយ គឺមិនយល់ព្រមតាមសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញាទេ ដែលស្នើសុំរយៈពេលមួយម៉ោងកន្លះសម្រាប់ថ្ងៃស្អែកព្រឹកស្អែក អ៎! ព្រឹកថ្ងៃចន្ទ ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១២ នោះ។ ប៉ុន្តែអង្គជំនុំជម្រះទទួលយកនូវការចែករំលែកពេលវេលាដែលខាងក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានចែករំលែកពេលវេលាមួយម៉ោងជូនទៅខាងតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសនៅក្នុងការតាំងសំណួរ។ ដូច្នេះ ពេលវេលានេះអង្គជំនុំជម្រះទទួលយល់ព្រមតាមចំណាត់ការរបៀបនេះ។ ហើយដូច្នេះសហព្រះរាជអាជ្ញា គឺនៅព្រឹកថ្ងៃចន្ទសប្តាហ៍ក្រោយ គឺមានពេលមួយម៉ោងក្នុងការសួរដេញដោល ចំពោះសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលជាពេលវេលាអង្គជំនុំជម្រះបានចែកឲ្យទៅខាងក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

[១៥:០១:៣០]

មួយទៀត អង្គជំនុំជម្រះសូមកត់សម្គាល់អំពីមតិយោបល់មួយចំនួនដែលបានលើកឡើងថា ការសួរដេញដោល តាំងសំណួររបស់តំណាងសហព្រះរាជអាជ្ញាមិនសំខាន់ ឬក៏មានការច្រំដែល។ បញ្ហានេះអង្គ-- ឬក៏មិនមានការពាក់ព័ន្ធបញ្ហានេះ អង្គជំនុំជម្រះសូមជម្រាបថា អង្គជំនុំជម្រះកត់សម្គាល់ឃើញថាសំណួរដែលតំណាងសហព្រះរាជអាជ្ញាបានសួរក្នុងអំឡុងពេលកន្លងមកនេះចំពោះសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច។ អង្គជំនុំជម្រះយល់ឃើញថា មានការពាក់ព័ន្ធទៅនឹងអង្គហេតុដែលអង្គជំនុំជម្រះដាក់ឲ្យធ្វើសវនាការយ៉ាងពិតប្រាកដ។ ទោះបីយ៉ាងនេះក៏ដោយ ក៏អង្គជំនុំជម្រះក៏ទទួលស្គាល់ពិតថាមានសំណួរមួយចំនួនក៏ជាគ្រាន់តែជាការលំបាកនៅក្នុងការយល់ ហើយបញ្ហានេះយើងដឹងទាំងអស់គ្នាហើយ សូម្បីតែសាក្សីខ្លួនគាត់ក៏តែងតែបង្ហាញអំពីការស្តាប់មិនយល់នូវសំណួរដែរ ហើយសូមឲ្យតំណាងសហព្រះរាជអាជ្ញាតាំងសំណួរសាជាថ្មី ហើយរៀបសំណួរឲ្យបានត្រឹមត្រូវ ដើម្បីគាត់យល់បាន។

[១៥:០២:៣៧]

ហើយបញ្ហាមួយទៀត គឺមេធាវីជាតិការពារក្តីលោក ខៀវ សំផន បានលើកឡើងពីការដែលតាំងសំណួរមិនពាក់ព័ន្ធ ឬក៏ក្រៅអង្គហេតុ។ អង្គជំនុំជម្រះធ្វើការកត់សម្គាល់ឃើញថា អំឡុងពេលដេញដោលចំពោះសាក្សីរូបនេះមិនទាន់មានឃើញសំណួរណាមួយដែលក្រៅអង្គហេតុទេ ឬក៏មិនពាក់ព័ន្ធទេ ហើយភាគីក្រុមមេធាវីការពារក្តីទាំងបីក្រុម ក៏មិនមានការជំទាស់ទៅលើសំណួរណាមួយដែលខ្លួនលើក

ឡើងអំពីមូលហេតុថា សំណួរនោះគឺក្រៅអង្គហេតុដែរ។

បាទ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីមានឱកាសក្នុងការបន្តការតាំងសំណួរដេញដោលចំពោះសាក្សី កាំង ហ្កេកអ៊ាវ។

សូមអញ្ជើញ!

[១៥:០៣:៤៩]

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងព្យាយាមតាំងសំណួរឲ្យច្បាស់លាស់។

**សួរដោយ លោក វីល្លៀម ស្មីត៖**

**ស៖** លោកសាក្សី មុនពេលដែលយើងឈប់សម្រាកលោកបានបញ្ជាក់ថា មានបុគ្គលមួយចំនួនត្រូវបានគេបញ្ជូនទៅផ្នែកការទូត ដើម្បីតាមដាន។ ថាតើការទូតហ្នឹង វាមានទីតាំងជាជាក់លាក់ដែរឬទេ? ថាតើវាមានទីតាំងកន្លែងណាមួយជាក់លាក់ដែរឬទេ?

[១៥:០៤:៣២]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ក្រសួងការបរទេស វាមានទីតាំងជាក់លាក់របស់គេ។ គ្រាន់តែខ្ញុំមិនដឹងថា ទីនោះ-- កន្លែងនោះនៅឯណា? ផ្ទាល់ខ្លួនខ្ញុំៗមិនដឹង។ ប៉ុន្តែ ខ្ញុំឃើញសំណួរ ដូចជាច្រឡំពាក្យ "ការទូត" ហើយនិង "អ្នកទូត ធ្វើទូត"។ ដូច្នេះបើនិយាយពីធ្វើទូតគេៗចាប់បញ្ចូលទៅ វាមានលក្ខខណ្ឌពីរ។ ទូតពិតប្រាកដរបស់គេ ហើយនិងទូតដែលគេដកចេញអំពីអង្គភាពដើម ដើម្បីឲ្យមនុស្សនោះក្តាប់កម្លាំង។ ហ្នឹងខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ តើលោកដឹងដែរឬទេ ថាតើមានមនុស្សប៉ុន្មាននាក់ដែលគេដាក់ទៅក្នុងផ្នែកទូតនោះ?

[១៥:០៥:៤២]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន។ មនុស្សដែលគេដកចេញមិនឲ្យក្តាប់កម្លាំងយកទៅដាក់ខាងការទូតមាន បើតាមខ្ញុំចាំ។ ស៊ុន ទី ហៅ ទាញ ចាប់មកស-២១ ហើយ។ កែ គឹមហួត ហៅ ម៉ន ហៅ សុត ក៏ចាប់មកស-២១ដែរ។ អ៊ិន លន ហៅ ណាត ក៏ចាប់មកស-២១ ដែរ។ ឆាយ គឹមហ៊ី ហៅ ហុក ក៏ចាប់មកស-២១ដែរ។ ហើយក្រៅពីនោះ អាចមានអ្នកផ្សេងទៀត ដែលខ្ញុំចាំមិនបាន

ហើយមិនស្គាល់គេច្បាស់លាស់។

**ស៖** ដូច្នេះ បុគ្គលដែលលោកបានលើកឈ្មោះឡើងនោះ ចុងក្រោយត្រូវគេយកមកស-២១ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាន៍លោកប្រធាន ត្រឹមត្រូវហើយ។

**ស៖** ថាតើអ្នកណាជាប្រធានផ្នែកទូត បានន័យថាអ្នកណាជាមេកោយរបស់ផ្នែកទូតនោះ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន។ មេរបស់ផ្នែកទូត ខ្ញុំស្គាល់តែមេធំបំផុត គឺ អៀង សារី ឧបនាយករដ្ឋមន្ត្រីទីមួយ។

[១៥:០៧:២៤]

**ស៖** តើលោកដឹងដែរឬទេ ថាតើមានមនុស្សប៉ុន្មាននាក់ដែលគេបញ្ជូនមកធ្វើទូត?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ទូតដែលគេចាត់តាំង តាំងពីដើមដំបូងអើយរហូតចុងបញ្ចប់ ខ្ញុំស្គាល់តែពីរនាក់ហ្នឹង គឺ ពេជ ជាង ទូតនៅចិន ហើយនិងម្នាក់ទៀត ស៊ឹម សុន ទូតនៅកូរ៉េ ក្រៅពីនោះមានផ្សេងទៀត ខ្ញុំមិនដឹង។

**ស៖** សូមអរគុណ។ ថាតើមនុស្ស ឬក៏បុគ្គលដែលមកពីអង្គភាពផ្សេងៗគ្នា តើគេមកស-២១ ដោយរបៀបបាន គឺថាតើអ្នកណាចាប់ខ្លួនពួកគាត់ អ្នកណានាំពួកគាត់មកស-២១?

**ឆ៖** អ្នកដែលបញ្ជូនមកស-២១ មានពីរប្រភេទ ម្យ៉ាងគេបញ្ជូនមកឲ្យស-២១ ចាប់។ ដូចយ៉ាង កុយ ធួន, ម៉ែន សាន ហៅ យ៉ា ជាដើម។ ប៉ង់ ខ្លួនឯងហ្នឹង គេបញ្ជូនមកឲ្យចាប់។ ម្យ៉ាងទៀត គេចាប់ហើយគេបញ្ជូនមកឲ្យ ដូចយ៉ាង វន វ៉េត ហើយនិងផ្សេងទៀតភាគច្រើន គេចាប់ហើយ គេបញ្ជូនមកឲ្យ នេះមានពីរប្រភេទហ្នឹង។

[១៥:០៩:៣០]

**ស៖** បុគ្គលដែលត្រូវបានគេចាប់មកពីមន្ទីរផ្សេងៗគ្នា ថាតើអ្នកណាជាអ្នកនាំពួកគាត់មកមន្ទីរ ស-២១ តើបុគ្គលិកស-២១ ជាអ្នកទៅនាំផ្ទាល់ ឬក៏បុគ្គលិករបស់មន្ទីរហ្នឹងជាអ្នកនាំយកមកឲ្យ?

**ឆ៖** បុគ្គលិករបស់មន្ទីរស-២១ ទៅនាំមកតិចណាស់។ ភស្តុតាងដែលនៅសល់ មិនមែនជាភស្តុតាង គឺឯកសារដែលនៅសល់សម្រាប់យើងទាំងអស់គ្នាយល់ គឺឯកសារថ្ងៃ១៦ ខែកញ្ញា ៧៦ នេះមួយ។ ហ្នឹងគឺស-២១ ទៅនាំមក ហើយខ្ញុំមាន តាមបញ្ជារបស់មេបញ្ជូនមនុស្សទៅទទួលពីខាងបាត់ដំបងមកមួយលើកពីរ។ ហើយក្រៅពីនោះ គេនាំមកៗ គឺម្ចាស់អង្គភាពរបស់គេ គេនាំមក។ ហើយ

មួយរយៈកាលចុងក្រោយនេះ ភាគច្រើនចាប់ចេញពីស-៧១ គឺមិត្តលីន ឲ្យគេ-- គាត់នាំមក។

**ស៖** សូមអរគុណ។ នៅក្នុងតារាងដែលលោកបង្ហាញដល់សហចៅក្រមស៊ើបអង្កេត គឺជាតារាងដែលបង្ហាញពីរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្ដកម្ពុជា ហើយនៅក្នុងតារាងមួយនោះ លោកបង្ហាញអំពីបឹងត្របែក តើលោកអាចពន្យល់បានដែរឬទេ? តើបឹងត្របែកហ្នឹងសំដៅលើអ្វី?

[១៥:១១:៣៨]

**ឆ៖** អរគុណ។ បឹងត្របែកនេះ ហើយនិងមន្ទីរផ្សេងទៀតមួយចំនួន ជាកន្លែងដែលគេសម្រាប់ទុកពួករណសិរ្ស តាមដានហើយលត់ដំក្នុងការងារពលកម្ម។ តាមដំណឹងដែលខ្ញុំទទួលបាន គឺមួយភាគធំគឺពួកបញ្ញាជនអស់នេះ គេឲ្យរៀនធ្វើដងកណ្ដៀវ។ ដូច្នេះ ជាសមាសភាពរណសិរ្សដែលគេចាំចាប់កំហុសដែលគេតាមដានមើលកំហុស។ ដូច្នេះ ពួកនេះមានចម្លើយបន្តិចបន្តួចតែពីស-២១ ទៅគេចាប់យកមកហើយ។ ដូច្នេះ បឹងត្របែកជាមជ្ឈមណ្ឌលអប់រំកសាងខ្លួនសាថ្មីសម្រាប់ពួករណសិរ្សនេះឯង។ មេខាងបឹងត្របែកនេះ អង្កាល់ពីជំនាន់មុនខ្ញុំស្គាល់ម្នាក់ ស្មានតែ ក-១០ នេះវានៅបឹងត្របែកនេះទាំងមូល គឺឈ្មោះមិត្ត មិន មីន ហៅ ព្រំ។ ហ្នឹងខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹងពីរឿងបឹងត្របែក។

**ស៖** នៅពេលដែលលោកនិយាយថា អ្នកៗ សមាសភាពរណសិរ្សត្រូវបានគេនាំមកហ្នឹង តើលោកសំដៅលើអ្នកណាដែរ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន។ អ្នករណសិរ្សហ្នឹងគឺមនុស្សដែលនៅជាមួយសីហនុ កាលពីជំនាន់ឆ្នាំ៧០, ៧៥ មួយចំនួនបានចេញទៅធ្វើទូត មួយចំនួនអត់ទេ អត់បានចេញទេ។ ដូច្នេះពួកនេះចូលមកវិញក្នុងឋានៈជាសមាជិករណសិរ្ស គេហៅថា សមាជិករបស់រណសិរ្សរួបរួមជាតិកម្ពុជា ឬក៏ជាសមាជិករបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ហើយគេយកទៅទុកតាមដានលត់ដំនៅក្នុងទីនោះ។ ក្នុងសមាសភាពជាការមិនច្បាស់លាស់ គេមិនអាចចាត់ទុកជាសត្រូវ ជាខ្មាំង តែក៏គេមិនប៉ានចាត់ទុកជាមិត្តពេញលក្ខណៈ គេតាមដាន។ សូមអស់ប៉ុណ្ណោះ សូមអរគុណ។

[១៥:១៤:២៦]

**ស៖** ថាតើបឹងត្របែកមានទំនាក់ទំនងអ្វីដែរជាមួយនឹងក្រសួងការបរទេស?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន បឹងត្របែកក៏ដូចជាមន្ទីរអប់រំកសាងខ្លួនសាជាថ្មីទាំងអស់របស់បក្សកុម្មុយនីស្ដកម្ពុជា។ ទាក់ទងនឹងក្រសួងការបរទេសកម្រិតណា ខ្ញុំក្លាប់មិនបានទេ។ ខ្ញុំក្លាប់បានតែម្យ៉ាង គឺគណៈកម្មាធិការមន្ទីរអប់រំកសាងខ្លួនសាថ្មីនេះ ជាគណៈកម្មាធិការ

របស់បក្ស វាជាសមាជិកបក្សសុទ្ធសាធ ដែលទៅគ្រប់គ្រងពួកសមាសភាពរណសិរ្ស តាមដានពួករណសិរ្ស។ ឧទាហរណ៍ នៅបឹងត្របែកនេះ មន្ទីរក-១០ គ្រប់គ្រងដោយមិត្ត មិន មីន ហៅ ព្រំ។ ឯចំណែក ក-១៧ នៅបឹងត្របែកនេះដែរ គ្រប់គ្រងដោយមិត្ត ស៊ីម ឈ្មោះដើម អ៊ុក សារ៉ន។ ដូច្នេះឯណាផ្សេងទៀតយ៉ាងម៉េចខ្ញុំមិនដឹងទេ ក៏ប៉ុន្តែអារឿងសមាសភាពរណសិរ្ស ទាក់ទងនឹងក្រសួងការបរទេសយ៉ាងម៉េចក៏ខ្ញុំក្តាប់មិនបានដែរ។ មិនមានរឿងរ៉ាវអីយល់ ដើម្បីបញ្ជាក់ជូនអង្គជំនុំជម្រះទេ។

[១៥:១៥:៤៨]

**ស៖** សូមអរគុណ។ ថាតើមនុស្សដែលគេឃុំនៅបឹងត្របែក តើពួកគាត់ទាំងអស់ចុងក្រោយត្រូវគេបញ្ជូនមកស-២១ ដែរឬទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន បើតាមខ្ញុំក្តាប់បាន ឯកសារដែលមនុស្សចូលមកស-២១ មានមួយចំនួនហើយ ក៏ប៉ុន្តែអាចមានមួយចំនួនទៀត ហើយប្រហែលជាច្រើនផង មិនត្រូវបានបញ្ជូនមកស-២១ ទេ។

**ស៖** ថាតើលោកស្គាល់ទេ ថាតើអ្នកណាឈ្មោះ វ៉ាន់ ពីនី?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន។ វ៉ាន់ ពីនី នេះ ឈ្មោះនៅក្នុងបឹងត្របែកឈ្មោះ ទិត ពីដើមកជាអគ្គលេខាធិការសមាគមទូទៅនៃនិស្សិតខ្មែរ ជំនាន់ខ្ញុំរៀនឆ្នាំ១៩៦៤-៦៥ បង្កើតសមាគមមួយឈ្មោះ "សមាគមទូទៅនៃនិស្សិតខ្មែរ"។ ដូច្នេះ វ៉ាន់ ពីនី នេះ ខ្ញុំស្គាល់ពីមុនមក។

**ស៖** ថាតើគាត់ធ្វើការនៅក្នុងក្រសួងការបរទេសដែរឬទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ចម្លើយ វ៉ាន់ ពីនី ខ្ញុំក្តាប់មិនបានទេ ខ្ញុំអត់បានអានហើយ អត់បានចាំផង ច្រើនពេក រឿងរ៉ាវច្រើនពេក។ ដូច្នេះខ្ញុំចាំមិនច្បាស់ ខ្ញុំមិនអាចសរុបជូនបានទេ។

**ស៖** សូមអរគុណ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ៧៥ ដល់ឆ្នាំ១៩៧៩ ថាតើលោកធ្លាប់ជួបលោក អៀង សារី ដែរឬទេ?

[១៥:១៨:៣៩]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ជាមួយនឹងបងវ៉ាន់ អៀង សារី នេះ ខ្ញុំគ្មានបានជួបគ្នាផ្ទាល់មាត់និយាយទេ។ ខ្ញុំឃើញគាត់ពីចម្ងាយតែពីរដងគត់។ ម្តងនៅក្នុងបូរីកីឡា គាត់មិនបានចូលរួមក្នុងបុណ្យនុំងទេ តែគាត់ទៅ ឯកសណ្ឋានហ្នឹងគាត់ស្លៀកពាក់អូវែរ ហើយខោនេះ អត់មាន

អារពីក្នុងផង។ ម្តងទៀត គឺនៅថ្ងៃ០៦ មករា ១៩៧៩ នេះពេលដែលខ្ញុំចេញពីធ្វើការនៅពុទ្ធកវិទ្យាល័យព្រះសុរាម្រិតមក ឃើញឡាន បងវ៉ាន់ នេះគេបើក-- គាត់បានបើកតាមផ្លូវសីហនុទៅមាត់ទន្លេ ខ្ញុំជិះម៉ូតូពីមាត់ទន្លេមកផ្លូវមុន្នីវង្ស ឃើញពីចម្ងាយឃើញក្នុងឡានអឺចឹង។ ងាកមើលទៅឃើញគ្នាអឺចឹង។ ដូច្នេះគ្មានបាននិយាយចូលគ្នា គ្មានបានអីទាំងអស់។

**ស៖** សូមអរគុណ។ ថាតើនៅពេលដែលលោកឃើញគាត់នៅបូរីកីឡានោះ តើគាត់កំពុងធ្វើអ្វី?

**ឆ៖** អរគុណ។ ថ្ងៃនោះ គាត់ដើរនៅសាល-- ក្រៅសាលមីទ្ទិង ខ្ញុំទៅធ្វើមីទ្ទិង មិនដឹងជាមីទ្ទិងបុណ្យ ដូចជាមីទ្ទិងបុណ្យ១៧ មេសា ប៉ុនមិនដឹងឆ្នាំណាភ្លេចហើយ។ គាត់ដើរនៅក្រៅមីទ្ទិង ក្រៅផ្លូវការមិនទាំងស្លៀកពាក់ឯកសណ្ឋានខោខ្មៅ អាវខ្មៅនឹងគេផង។

**ស៖** ថាតើលោកអាចនិយាយថាទេ តើទំនាក់ទំនងរវាង នួន ជា និង អៀង សារី មានទំនាក់ទំនងរបៀបណាដែរ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំក្តាប់មិនបានទេ រឿងគេចាស់ៗ។

**ស៖** ថាតើ នួន ជា ធ្លាប់និយាយអំពី អៀង សារី ដែរឬទេ?

[១៥:២១:១៣]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន បងនួន និយាយអំពី បងវ៉ាន់ តែមិនចំឈ្មោះទេ។ ក្នុងករណីតែមួយគត់ គឺចាប់ ចៅ សេង។ បងនួន ហាមខ្ញុំ ថាបើក្រសួងការបរទេសគេឲ្យអ្នកណាទៅទាក់ទងសួរមិត្តពីរឿង ចៅ សេង មិត្តកុំប្រាប់។ ទុកឲ្យគេមកសួរខ្ញុំ។ នេះ បងនួន មាននិយាយពីរឿង បងវ៉ាន់ តែមួយម៉ាត់គត់ក្នុងករណី ចៅ សេង នេះឯង។ សូមជម្រាបប្រសាសន៍លោកប្រធាន មានតែប៉ុណ្ណឹង។

**ស៖** ហេតុអ្វីបានជាមានតែមួយករណីហ្នឹង?

**ឆ៖** អ៎!ៗៗ ឈប់! ករណីមួយទៀត ពីរឿងខ្ញុំព្រឹកមិញនិយាយហើយ។ ពីរឿងមានខ្លាំងឆ្លើយដាក់មិត្ត មិញ កូនបង្កើតរបស់ បងវ៉ាន់ នេះ ហើយនិងមិត្ត ពឿន កូនបង្កើត-- កូនប្រសាររបស់ បងវ៉ាន់ នេះ។ ខ្ញុំទៅរាយការណ៍សុំយោបល់ បងនួន សួរថាតើស្តាប់ចម្លើយខ្លាំងតទៅទៀត ឬមិនស្តាប់? គាត់សើចចំអកឲ្យខ្ញុំ។ ហ្នឹងករណីហ្នឹងមួយទៀត។ ក៏ប៉ុន្តែក៏មិនចេញឈ្មោះចំ បង អៀង សារី ដែរ។ នេះករណីពីរហ្នឹង។

**ស៖** សូមអរគុណ។ លោកបាននិយាយពីខាងដើមមកថា នៅពេលដើមនៃរបបកម្ពុជាប្រជា

ធិបតេយ្យលោកបានស្តាប់ឮវិទ្យុដែលផ្សព្វផ្សាយអំពីឈ្មោះរបស់ជនមហាក្បត់ ថាតើលោកបាននិយាយដែរឬទេ?

[១៥:២៣:៣១]

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន បញ្ហានេះខ្ញុំនិយាយជាហូរហែ។ ខ្ញុំជឿថានៅមុខសហចៅក្រមស៊ើបអង្កេតក៏ខ្ញុំនិយាយ ប៉ុន្តែសវនាការនេះដូចជាអត់មានបាននិយាយទេ ក្នុងសវនាការ ០០១ ខ្ញុំក៏ដូចជាមិនបាននិយាយទេ ឬក៏និយាយដែរមិនដឹងទេ។ ប៉ុន្តែខ្ញុំនិយាយហូរហែ។

**ស៖** ថាតើលោកអាចប្រាប់យើងដោយសង្ខេបបានដែរឬទេ ថាតើលោកបានស្តាប់ឮអ្វីខ្លះនៅតាមការផ្សាយរបស់វិទ្យុនោះ?

**ឆ៖** ការផ្សាយតាមវិទ្យុហ្នឹងនៅពេលរៀបឈ្មោះហើយ គឺបើតាមខ្ញុំចាំ ផ្សាយក្នុងខែកុម្ភៈ ១៩៧៥ ថា បដិវត្តន៍ ឬក៏ចលនាតស៊ូ កាលនោះមិនដឹងគេហៅអីទេ ដូចជាហៅថា រណសិរ្សរួបរួមជាតិកម្ពុជាអីចឹង។ សម្រេចឲ្យតែបុគ្គលប្រាំពីររូបគត់ ប្រឈមនឹងតុលាការ ដែលជាជនមហាក្បត់។ គេហៅថាមហាក្បត់។ ហ្នឹងក៏គាត់រាប់ឈ្មោះទៅ ឯចំណែកប្រជាជនក្រៅពីនោះ អ្នកផ្សេងទៀតក្រៅពីនោះ យើងអត់គិតគួរជាទោសពៃរ៍អីទេ។ នេះខ្លឹមសារប៉ុណ្ណឹង។

[១៥:២៥:១៤]

**លោក វីណ្ឌៀម ស្មីត៖**

លោក លោកស្រីចៅក្រម តើខ្ញុំអាចដាក់ឯកសារនៅចំពោះមុខសាក្សីបានដែរឬទេ? គឺ D80/1។ គឺសំណុំរឿង-- គឺដែលមាន-- គឺឯកសារ D108/4.3/1 ឬក៏ហៅឯកសារ E3/117។ ដូច្នេះ ខ្ញុំសូមស្នើដាក់ឯកសារហ្នឹងនៅអេក្រង់ទូរទស្សន៍។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីតុលាការយក-- ទទួលយកឯកសារពីតំណាងសហព្រះរាជអាជ្ញាជូនសាក្សីពិនិត្យ។

[១៥:២៦:២៤]

**សួរដោយលោក វីណ្ឌៀម ស្មីត៖**

**ស៖** សាក្សីសូមលោកពិនិត្យមើលទៅលើឯកសារនោះ។ គឺជាប្រតិចារឹកនៃការផ្សព្វផ្សាយវិទ្យុ គឺវិទ្យុ អេស.អាយ.ប៊ី.អេស ចុះថ្ងៃ២៦ ខែកុម្ភៈ ឆ្នាំ៧៥ ដែលនិយាយអំពីការប្រាស្រ័យទាក់ទងនៅថ្ងៃ

២៤, ២៥ ខែកុម្ភៈ ដែលនិយាយអំពីសមាជលើកទីពីររបស់រណសិរ្សបង្រួបបង្រួមជាតិកម្ពុជា នៃកងកម្លាំងបដិវត្តន៍កម្ពុជា។ លោកសាក្សីសូមលោកពិនិត្យមើលទៅលើឯកសារទាំងនោះ ហើយជម្រាបមកយើង ថាតើឯកសារហ្នឹងលោកស្គាល់ដែរឬទេ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្លឹមសារទាំងអស់នេះ ខ្ញុំឮតាមវិទ្យុ ក៏ប៉ុន្តែឯកសារនេះខ្ញុំមិនដែលបានឃើញទេ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការដកយកឯកសារចេញពីដៃសាក្សី ហើយនិងឲ្យដកចេញពីអេក្រង់ទូរទស្សន៍។

**លោក វីល្លៀម ស្មីត៖**

លោកចៅក្រមទោះបីថាគាត់មិនដែលឃើញឯកសារហ្នឹងពីមុនក៏ដោយ ប៉ុន្តែគាត់ដឹងអំពីខ្លឹមសារនៃឯកសារនេះ។ ដូច្នេះខ្ញុំស្នើថា ខ្ញុំអាននូវកថាខណ្ឌមួយចំនួន ដើម្បីឲ្យផ្ទៀងផ្ទាត់ថាតើវាត្រូវជាមួយនឹងអ្វីដែលគាត់ចាំតាមរយៈការផ្សព្វផ្សាយវិទ្យុ តើបានដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកមេធាវីជាតិការពារក្ដីឲ្យលោក ខៀវ សំផន!

[១៥:២៨:៤០]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ តើខ្ញុំបាទសូមអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាយកចំណុច *ផារ៉ាក្រាហ្វ* ណា? ផ្នែកណា? ដែលលោកបម្រុងអាននឹង ឲ្យមើលមេធាវីអាចសុំមើលជាមុនសិន មុននឹងឲ្យទៅសាក្សីបានទេបាទ?

**លោក វីល្លៀម ស្មីត៖**

លោក លោកស្រីចៅក្រម គឺកថាខណ្ឌ១ ហើយនិងបុព្វកថា-- ហើយនិងកថាខណ្ឌមួយដែលទៀតដែលនិយាយពាក់ព័ន្ធទៅនឹងជនមហាក្បត់ទាំងប្រាំពីរ ដើម្បីឲ្យខ្ញុំផ្ទៀងផ្ទាត់ ថាតើសាក្សីគាត់ចាំហើយនិងអាចបញ្ជាក់ទៅលើខ្លឹមសារនៃឯកសារនេះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ លោកមេធាវីអន្តរជាតិការពារក្ដីលោក ខៀវ សំផន!

**លោក អាកទ្បូរ វែកគែន៖**

បាទ សូមអរគុណ។ ខ្ញុំគ្រាន់តែចង់ដឹងថា តើរបៀបចោទសំណួរធម្មតាដែលថា ត្រឹមត្រូវហ្នឹងគឺថាតើយើងត្រូវអានឯកសារភ្លាមហ្នឹង ហើយដើម្បីផ្ទៀងផ្ទាត់ ចោទសំណួរទៅសាក្សីហ្នឹង? តើដើម្បីឲ្យដឹងថាគាត់ចាំអីខ្លះ? ព្រោះអីថាគាត់ចាំអំពីអ្វីដែលបាន-- ព័ត៌មានដែលបានផ្សព្វផ្សាយនៅក្នុងវិទ្យុនោះ។ អ៊ីចឹង ខ្ញុំគិតថាមិនបាច់នេះឯកសារអី អានឯកសារអីទេ គ្រាន់តែសួរគាត់ថា តើលោកចាំអ្វីខ្លះនៅក្នុងការផ្សាយព័ត៌មាននុ៎ង?

**លោក វីណ្ឌៀម ស្មីត៖**

ខ្ញុំគ្រាន់តែចង់ចោទសួរសំណួរជាក់លាក់ពីរបីប៉ុណ្ណោះ ដើម្បីសួរទៅរូបគាត់។

**ប្រធានអង្គជំនុំ៖**

ការចោទសំណួរដូចជាអង្គជំនុំជម្រះបានសម្រេចរួចហើយ នៅលើឯកសារទាំងឡាយដែលដាក់មកបង្ហាញចំពោះមុខសាក្សី ហើយសាក្សីបានបញ្ជាក់ថា ខ្លួនមិនដែលបានឃើញឯកសារហ្នឹងពីមុនមកទេ។ ដកឯកសារចេញ ហើយភាគីដែលមានបំណងក្នុងការប្រើប្រាស់ឯកសារនោះអាចដកស្រង់នូវបញ្ហានៅក្នុងខ្លឹមសារនៃឯកសារដែលខ្លួនយល់ឃើញថា មានប្រយោជន៍នៅក្នុងការដេញដោលសម្រាប់ភាគីខ្លួន ចំពោះសាក្សីអាចប្រើប្រាស់សិទ្ធិនេះបានក្នុងការដេញដោល។ ប៉ុន្តែអំមិញនេះ គឺវាផ្ទុយ បានន័យថាលោកចង់អាននូវខ្លឹមសារ រួចបញ្ជាក់ទៅសាក្សី។ ការអានដូច្នេះ អង្គជំនុំជម្រះមិនអនុញ្ញាតទេ។

[១៥:៣១:៤៣]

**លោក វីណ្ឌៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ គោលដៅនៃការចោទសួរហ្នឹង គឺគ្រាន់តែដើម្បីអះអាង ដើម្បីបញ្ជាក់ ថាតើឯកសារនេះពិតជាកំណត់ត្រានៃវិទ្យុផ្សាយសំឡេងដែលគាត់បានស្តាប់ឮតែប៉ុណ្ណោះ។ ដូច្នេះខ្ញុំសូមជម្រាបថា ដើម្បីបង្ហាញថាឯកសារនេះ គឺវាមានយថាភាព ហើយវាមានតម្លៃគ្រប់គ្រាន់ដែលអាចដាក់នៅចំពោះមុខអង្គជំនុំជម្រះ។ ដូច្នេះ ខ្ញុំគ្រាន់តែចង់បង្ហាញបែបនេះ។ ដូច្នេះ ខ្ញុំគិតថាអាចនឹងលើកនូវឃ្លា ឬក៏ប្រយោគមួយចំនួន ដើម្បីឲ្យសាក្សីគាត់អាចយល់ អាចអាន ដើម្បីឲ្យគាត់អាចដឹង។ ដូច្នេះគាត់អាចនឹងបញ្ជាក់បានទៅលើអ្វីដែលគាត់បានស្តាប់ឮ ដូចនឹងអ្វីដែលបានសរសេរនៅក្នុងឯកសារនេះ។ ហេតុដូច្នេះហើយទើបខ្ញុំស្នើសុំដាក់ត្រឹមតែឃ្លាខ្លី ឬមួយក៏ខ្ញុំអាចនឹងរៀបរាប់ និយាយរៀបរាប់ឡើងវិញក៏អាចបានដែរ។

[១៥:៣២:៤៣]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី!

**លោក អាកឡូវ វ៉េកគែន៖**

បាទ ខ្ញុំគិតថា សហព្រះរាជអាជ្ញាប្រហែលជាធ្វើជាមិនយល់បទអន្តរាគមន៍របស់ខ្ញុំអម្បាញ់មិញនេះហើយ។ បើសិនជាគាត់អានឯកសារនេះ អង្គជំនុំជម្រះនោះមិនអាចដឹងថា តើសក្ខីកម្មពិតប្រាកដរបស់សាក្សីនេះវាយ៉ាងម៉េចនោះទេ។ អ៊ីចឹង ខ្ញុំគិតថា ជារឿងធម្មតាទេ ដែលយើងត្រូវតែសួរថា គាត់ដឹងពីអ្វីខ្លះទាក់ទងនឹងព័ត៌មានដែលគាត់បានស្តាប់នៅក្នុងវិទ្យុនោះ? នៅពេលដែលគាត់ប្រាប់យើងហើយៗប្រហែលជាអង្គជំនុំជម្រះអាចអនុញ្ញាតឲ្យសហព្រះរាជអាជ្ញានិយាយរំឭកការចងចាំរបស់សាក្សីបាន។

[១៥:៣៣:៣៨]

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញៗ!

រឿងនេះមិនធ្ងន់ធ្ងរទេ គ្រាន់តែវិធីសួរទេនេះ គឺសួរតាំងសំណួរទេ។ របៀបសួរអំពីការចងចាំនូវព័ត៌មានមួយចំនួនដែលធ្លាប់ គាត់ធ្លាប់មានបទពិសោធន៍ ឬក៏ជួបប្រទះពីមុនមក ហើយបន្ទាប់មកសួរដេញដោល។ អ៊ីចឹងលើការបច្ចេកទេស លើបច្ចេកទេសក្នុងការតាំងសំណួរ របៀបរៀបចំនូវសំណួរដែលសួរៗនោះ។ បញ្ហាក៏ហាក់ដូចជាមិនទំនងដែរ យើងបានប្រាប់ព្រឹកមិញហើយ ជម្រាបភាគីរួចហើយនៅក្នុងការដេញដោល ភាគីនីមួយៗមាន ឬបុគ្គលម្នាក់ៗដែលចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីតែងតែមានចំណេះដឹងផ្ទាល់ខ្លួន និងបទពិសោធន៍ផ្ទាល់ខ្លួននៅក្នុងបច្ចេកទេសនៃការសួរដេញដោល ឬក៏វិធីសាស្ត្រនៃការសួរដេញដោល។ ហើយភាគីទាំងពីរគឺមានផលប្រយោជន៍ផ្ទុយគ្នា ដោយភាគីម្ខាងជាភាគីដែលមានមុខងារខាងចោទប្រកាន់ និងគាំទ្រការចោទប្រកាន់ ហើយភាគីម្ខាងទៀតគឺភាគីដោះសាដោះបន្ទុកឲ្យរួចផុតពីបទចោទប្រកាន់ ឬក៏ឲ្យស្រាល។ អ៊ីចឹងវិធីគឺខុសគ្នា។ ការកេងចំណេញ ការដកហូតនូវខ្លឹមសារ សូម្បីតែឯកសារតែមួយនេះក៏អាចជ្រើសរើសដកហូត ដកស្រង់នូវផលប្រយោជន៍ខាងដាក់បន្ទុកក៏មាន ដោះបន្ទុកក៏មានក្នុងសាក្សីម្នាក់ក៏ដូចគ្នាដែរ។ អាចសាក្សីដាក់បន្ទុក ទាំងដាក់បន្ទុកឬក៏ដោះបន្ទុកទាំងស្រុង ប៉ុន្តែមានសាក្សីខ្លះក៏គាត់បានដឹងអំពីបញ្ហាអាចជាភស្តុតាងដាក់បន្ទុក ហើយក៏អាចជាភស្តុតាងដោះបន្ទុកផងក្នុងករណីខ្លះ។ អ៊ីចឹងវាអាស្រ័យទៅលើបច្ចេកទេស ឬក៏វិធីសាស្ត្រក្នុង

ការដេញដោល វាអាស្រ័យទៅលើមុខងាររបស់ភាគី។

**លោក វីណ្ឌៀម ស្មីត៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។

[១៥:៣៥:៤៣]

**សួរដោយលោក វីណ្ឌៀម ស្មីត៖**

**ស៖** លោកសាក្សី ទាក់ទងទៅនឹងនឹងការផ្សាយវិទ្យុ តើលោកអាចនិយាយដោយជាក់លាក់ថា តើលោកចាំថាលោកបានឮអ្វីខ្លះ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ពីឆ្នាំ១៩៧៥ ខែកុម្ភៈ មកដល់ឥឡូវវាជាងសាមសិបប្លាយឆ្នាំមកហើយ។ ថ្វីត្បិតតែព័ត៌មាននេះធ្វើឲ្យខ្ញុំរំភើប ប៉ុន្តែខ្លឹមសារ ខ្ញុំចាំបានតែពីរគត់។ ទីមួយ គឺរណសិរ្សរួបរួមជាតិកម្ពុជា ឲ្យតែមនុស្សប្រាំពីរនាក់ គាត់ប្រឈមនឹងតុលាការ មិនមែននិយាយថាកម្ទេចទេ គឺប្រឈមនឹងតុលាការ។ ឯទីពីរកំណត់ជាអ្នកផ្សេងទៀត រណសិរ្សរួបរួមជាតិកម្ពុជាមិនប្រកាន់ទោសពៃរ៍អ្វីទេ។ ខ្ញុំរំភើបដែរ ឮអ៊ីចឹង។ ខ្ញុំជឿថា ផែនការនេះថ្វីត្បិតតែមិនចេញពីគោលគំនិតផ្តើមរបស់ ខៀវ សំផន ក៏ដោយ ខ្ញុំជឿថាវាចេញពី ប៉ុល ពត មេធំ មិនមែន ខៀវ សំផន ទេ។ ក៏ប៉ុន្តែខ្ញុំជឿថា គេនឹងអនុវត្តយ៉ាងនេះ ព្រោះគេធានាលើឆាកអន្តរជាតិរួចមកហើយ។ នេះខ្ញុំចាំបានតែប៉ុណ្ណឹង។ រហូតដល់ឥឡូវនេះ ចាំបានតែប៉ុណ្ណឹង។ ហើយខ្លឹមសារដែលស្តាប់វិទ្យុហ្នឹង ក៏ច្បិចយកតែប៉ុណ្ណឹងឯង។

[១៥:៣៧:៣០]

**ស៖** ថាតើលោកដឹងទេ អ្នកណា គឺជាអ្នកនិពន្ធអត្ថបទដែលគេយកទៅចាក់ផ្សាយនោះ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន គ្មានការផ្សព្វផ្សាយអ្វីដ៏ធំដុំបែបនេះ ដោយមិនចេញពី ប៉ុល ពត នោះទេ។ នេះជាក្រឹត្យក្រមរបស់បក្សកុម្មុយនីស្តកម្ពុជា គឺចេញពី ប៉ុល ពត។

**ស៖** ទាក់ទងទៅនឹងជនក្បត់ ថាតើការប្រកាសតាមវិទ្យុនោះ គឺនិយាយដូចម្តេច ថាតើគេនឹងយកជនក្បត់នោះទៅធ្វើអ្វី?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមនិយាយម្តងទៀតថា នៅក្នុងខ្លឹមសារនេះ នៃសេចក្តីប្រកាសនេះ បើតាមខ្ញុំចាំ គេអត់និយាយថា យកទៅកម្ទេចទេ គេអត់យកទៅសម្លាប់ទេ គឺឲ្យប្រឈមនឹងតុលាការ តែបុគ្គលប្រាំពីរនាក់ទេ។

**ស៖** ថាតើសេចក្ដីប្រកាសនោះ គេសំដៅទៅលើអ្នកណាខ្លះ ដែលថាជាជនមហាក្បត់នោះ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន។ នៅពេលដំបូងៗ ខ្ញុំចាំ ឥឡូវវង្វេង រាប់បាន តែខ្លះ តែក៏អាចខុសផង ត្រូវផងក៏មិនដឹង។ ដូច្នេះ បើចាំបាច់ឲ្យខ្ញុំរាប់ ក៏ថាបាន ខ្ញុំអាចរាប់ជូនបាន តែប្រាកដជាមិនទៀង។

**ស៖** តើលោកអាចនឹកឃើញឈ្មោះខ្លះដែរឬទេ បើសិនលោកនឹកឃើញ សូមលោកបញ្ជាក់?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន បើតាមខ្ញុំចាំ មិនដឹងត្រូវ ឬខុសទេ ទីមួយគឺ លន់ នល់, ទីពីរគឺ សិរិមតៈ, ទីបីគឺ ចេង ហេង, ទីបួនគឺ អ៊ិន តាំ, ទីប្រាំគឺ ឡុង បូរ៉េត, ទីប្រាំមួយគឺ ស្វស្ដែន ហ្វៃណង់ដែស ហើយទីប្រាំពីរ មិនដឹងអ្នកណា លន់ ណុន ឬក៏អ្នកណាមិនដឹងទេ។

[១៥:៤០:២៧]

**ស៖** តើលោកបានឮទេ ថាក្រោយមកអ្នកទាំងប៉ុន្មាននាក់ដែលលោករៀបរាប់អំមិញនេះជួបនឹងជោគវាសនាយ៉ាងដូចម្ដេចដែរ?

**ឆ៖** អរគុណ។ លន់ នល់ អ្នកណាក៏ដឹងដែរ។ គាត់អញ្ជើញទៅនៅអាមេរិកតាំងពីថ្ងៃ០១ មេសា ១៩៧៥។ ហើយ លន់ នល់ អ៊ំ សូមទោស! ប្អូនគាត់ លន់ ណុន ចូលមក ដល់ក្រោយមកបាត់ដំណឹងក្រោយជម្លៀស ក្រោយ ១៧មេសា បាត់ដំណឹង។ ឯចំណែក ឡុង បូរ៉េត ស្អីៗខ្ញុំបាត់ដំណឹង។ ដល់ក្រោយមកបានព័ត៌មានខ្លះបន្តិចបន្តួចថា កងទ័ព ទៅអូសយក សិរិមតៈ ហើយនិង ឡុង បូរ៉េត យកមកកម្ទេចនៅនឹងមុខស្ថានទូតបារាំង។ ប៉ុន្តែព័ត៌មាននេះ ពិត ឬមិនពិតមិនដឹងទេ ក្រៅផ្លូវការទេ។ ដូច្នេះ អ្នកផ្សេងទៀត ខ្ញុំមិនដឹងទេ។ មិនដឹងយ៉ាងម៉េចយ៉ាងម៉ាទេ។ ប៉ុន្តែច្បាស់មែនទែន គឺ លន់ នល់ គាត់ទៅបាត់ហើយ។

[១៥:៤១:៥៤]

**ស៖** សូមអរគុណ។ តើលោកដឹងពីសមាជដោយតំណាងរបស់រណសិរ្សរួបរួមជាតិកម្ពុជាចាប់ពីថ្ងៃទី២៤-២៥ ខែកុម្ភៈ ឆ្នាំ១៩៧៥ ដែរឬទេ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំអត់ដឹងទេ។ ប្រសិនបើខ្ញុំ ពេលនោះខ្ញុំឮតាមវិទ្យុ ក៏ខ្ញុំមិនជឿថាជាសមាជពិតដែរ។ ខ្ញុំនៅតែយល់ថា ជាសមាជឧបកិច្ចដែល ប៉ុល ពត ឧបកិច្ចឡើង ដើម្បីឲ្យមានជាទម្រង់មួយវាមានលក្ខណៈហ៊ឹកហ៊ាក់បន្តិចខាងនយោបាយ។

**លោក វីល្លៀម ស្មីត៖**

សូមអរគុណ។ មុននឹងបញ្ចប់ការពិភាក្សាល្ងាចនេះ ខ្ញុំចង់បង្ហាញឯកសារជូនលោកមើលពីរបី ហើយសូមឱ្យលោក-- ឯកសារ D43/IV ឧបសម្ព័ន្ធ៥៨ ខ្ញុំមានឯកសារជាក្រដាស។ ខ្ញុំសូមអនុញ្ញាតបង្ហាញសាក្សីនូវឯកសារនេះ ហើយនិងសូមបង្ហាញលើអេក្រង់ផងដែរបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជូនទៅសាក្សីពិនិត្យ!

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** លោកសាក្សីឯកសារនេះ គឺមានចំណងជើងថា “ចម្លើយសារភាពរបស់ អេង ម៉េង ហៅ ឆុន” គឺធ្វើការនៅក្រសួងថាមពលបាទ។ អេង ម៉េងហ៊ាង ហៅ ឆុន បាទ។ តើលោកធ្លាប់បានឃើញឯកសារនេះ ពីមុនដែរឬទេ?

[១៥:៤៤:១៣]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ខ្ញុំសូមជម្រាបលោកប្រធាន។ សូមបញ្ជាក់ខុសពីសំណួររបស់សហព្រះរាជអាជ្ញាបន្តិច ចំណងជើងចម្លើយ អេង ម៉េងហ៊ាង ហៅ ឆុន (ថាមពល) នេះជាអក្សរខ្ញុំ។ ពិតប្រាកដជាអក្សរខ្ញុំ។ ដូច្នេះវាជាឯកសារ ស-២១ អត់ប្រកែកបានទេ។ ឯកសារនេះ ខ្ញុំឃើញនៅពេលធ្វើសវនាការសំណុំរឿងលេខ០០១ ខ្ញុំបានពន្យល់បញ្ហានេះរួចហើយ។ ដូច្នេះ ខ្ញុំរង់ចាំសំណួរផ្សេងទៀត របស់សហព្រះរាជអាជ្ញាអំពីបញ្ហាឯកសារនេះ។

**ស៖** សូមអរគុណ។ សូមលោកអានចំណារទីមួយ ហើយសូមបញ្ជាក់ថា តើលោកជឿថាអ្នកណាជាអ្នកធ្វើចំណារនេះបាទ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ចំណារនៅលើនេះមានពីរ។ ចំណារមួយនៅក្នុងប្រអប់ពណ៌ក្រហម ចំណារមួយទៀតនៅជ្រុងខាងស្តាំ ខាងលើ។ ឥឡូវសូមលោកប្រធានបញ្ជាក់សហព្រះរាជអាជ្ញាតើគាត់សួរខ្ញុំឱ្យពន្យល់ចំណារណា?

[១៥:៤៦:២២]

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញាបញ្ជាក់សំណួរឡើងវិញ ចំណារមួយណា ពីព្រោះមានចំណារពីរដែលសាក្សី

កត់សម្គាល់ ហើយមិនដឹងថាឆ្លើយចំណារមួយណាទេ តបនឹងសំណួររបស់លោកតំណាងសហព្រះរាជអាជ្ញា។

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** សូមលោកអានចម្លើយ អំ ចំណារនៅទំព័រ ERN00174392។ បាទចំណារជាអក្សរក្រហមបាទ។

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន។ ចំណារជាអក្សរក្រហមនេះ ជាចំណាររបស់មេខ្ញុំ សុន សេន។

**ស៖** សូមលោកអានចំណារហ្នឹងបាទ។

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ខ្ញុំសូមអានចំណារនេះដូចតទៅ៖ សំខាន់ ហើយឆូតពីក្រោមពីរទៅទៀត ស្នើ សញ្ញាស្មើ ក្រសួងពិនិត្យប្រញាប់ ដើម្បីដកវាឲ្យអស់ ទើបចូលទៅក្តាប់ក្រសួងពាណិជ្ជកម្ម និង-- ក្រសួងពាណិជ្ជកម្ម និងស្ពឺទេ មើលមិនដាច់ទេ។

[១៥:៤៨:៣៧]

**ស៖** តាមដែលលោកដឹងថាតើ ដែលថាអ្នកណាដែលនៅក្រសួងនោះ ដែលត្រូវពិនិត្យឯកសារបាទ-- ចំណារនេះ បាទពិនិត្យប្រញាប់ហ្នឹង?

**ឆ៖** អរគុណ។ សូមជម្រាបលោកប្រធាន ក្រសួងដែល អេង ម៉េងប៊ាង ធ្វើការនេះគឺក្រសួងថាមពល។

**ស៖** ទាក់ទងទៅនឹងការណែនាំថាតើអ្នកណាដែលនៅក្នុងក្រសួងនោះ ដែលជាអ្នកត្រូវពិនិត្យឯកសារនេះ? ហើយចម្លើយសារភាពហ្នឹងបាទ?

**ឆ៖** ជាគោលការណ៍ នេះខ្ញុំនិយាយថាជាគោលការណ៍ គឺលេខាក្រសួងថាមពលត្រូវពិនិត្យ។

**ស៖** តើលោកចង់និយាយថាក្រសួងថាមពល ឬក៏ក្រសួងពាណិជ្ជកម្ម?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី!

[១៥:៥០:៤២]

**លោក អាកទ្វរ វែកគែន៖**

សូមអរគុណលោកប្រធាន ខ្ញុំមិនយល់សំណួរចុងក្រោយនេះទេ។ ក្រសួងៗដែលសហព្រះរាជអាជ្ញាបានលើកឡើងអម្បាញ់មិញនេះ គឺថាដូចមិនដែលឮទេ។ ខ្ញុំមិនយល់ទេ ថាហេតុអីបានសួរនាំមុខទៅកាន់សាក្សីយ៉ាងដូច្នេះ?

**ប្រធានអង្គជំនុំ៖**

ជំទាស់គ្មានប្រសិទ្ធភាពបាទ។ សាក្សីអាចឆ្លើយនឹងសំណួរដែលសួរដោយសហព្រះរាជអាជ្ញានេះ ព្រោះមានពាក្យពីរនៅទីនេះ មានពាក្យ "ថាមពល" ហើយនិងមានពាក្យថា "ក្រសួងពាណិជ្ជកម្ម"។

**លោក កាំង ហ្គេកអ៊ាវ៖**

ប្រធាន! ឲ្យសហចៅក្រមសួរម្តងទៀត ព្រោះវង្វេងហើយ។

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញា តាំងសំណួរចុងក្រោយរបស់លោក ចំពោះសាក្សីសាជាថ្មីម្តងទៀត!

[១៥:៥១:៤៥]

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** សំណួរនោះថា តើអ្នកណាជាអ្នកត្រូវពិនិត្យចម្លើយសារភាពនេះ? ជាក្រសួងថាមពល ឬក៏ក្រសួងពាណិជ្ជកម្ម? តាមអ្វីដែលលោកដឹងកាលពីសម័យនោះ។

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ បទបញ្ហានេះចេញទៅផ្ទាល់ដល់ក្រសួងថាមពល ហើយអ្នកដែលមានសិទ្ធិពិនិត្យតាមដាន ហើយរាយការណ៍ជូនបក្ស គឺលេខាក្រសួងថាមពល។ ក៏ប៉ុន្តែក្នុងពាក្យនេះ វាមានក្រសួងពាណិជ្ជកម្មមួយទៀត។ ខ្ញុំសូមនិយាយជាក់ស្តែង អេង ម៉េងប៊ាង ហៅ ឆុន នេះជាមនុស្សរបស់ កុយ ធួន។ ដូច្នេះខ្សែរបស់ កុយ ធួន សំខាន់គឺមាននៅក្នុងក្រសួងពាណិជ្ជកម្មផង និងក្រសួង ថាមពលផង។ ប៉ុនបទបញ្ហានេះវាចេញទៅក្រសួងថាមពលទេ។ នេះខ្ញុំសូមរាយការណ៍ជូនប៉ុណ្ណេះ។

[១៥:៥៣:០៧]

**លោក វីល្លៀម ស្មីត៖**

សូមអរគុណ។ ខ្ញុំបានបញ្ចប់ជាមួយឯកសារនេះហើយ ហើយខ្ញុំសូមអនុញ្ញាតតុលាការដើម្បីដាក់ជូនឯកសារចំពោះលោកគឺ IS5.30 បាទ។ បាទ ជាលិខិតមួយដែលមានកំណត់ដៃនៅលើនោះ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីតំណាងអយ្យការជូនសាក្សីពិនិត្យ!

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** សូមលោកសាក្សីមើលឯកសារនេះ ហើយជម្រាបតុលាការថាតើលោកបានអានឯកសារនេះពីមុនដែរឬទេ?

**ឆ៖** គោរពលោកប្រធាន ឯកសារនេះជាឯកសារស-២១។ ខាងក្នុងបានច្បាស់ គឺទំព័រ៩២២។ ទំព័រ៩២២ នេះជាអក្សរដៃរបស់ខ្ញុំ “ហ៊ូ នឹម = ភាស់ (I) ពេលមិនទាន់សារភាពសោះ”។

**ស៖** ទាក់ទងទៅនឹងចំណារទីមួយ ដូចជាកំណត់ហេតុនៅក្នុងទំព័រ 0008922 សូមលោកអញ្ជើញអានកំណត់ដៃនោះបាទ។ នៅទំព័រទី១ នៅខាងឆ្វេងដៃ ខាងលើបាទ។

**ឆ៖** អរគុណ។ ខ្ញុំសូមអនុញ្ញាត លោកប្រធានសួរទៅសហព្រះរាជអាជ្ញា។ តើខ្ញុំ-- លោកឲ្យខ្ញុំ 921 ឬ922?

**ស៖** សូមឲ្យលោកអាន ខ្ញុំជឿថានៅ 00008923 ដែលថាទំព័រចុងក្រោយ ជាកំណត់-- បាទជាចំណារផ្ទាល់ដៃនៅលើខាងទំព័រចុង គឺជាសរសេរផ្ទាល់ដៃទេ ចំណារហ្នឹងបាទ។

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ចំណារនៅផ្នែកខាងឆ្វេង ខាងក្រោមជាអក្សរដៃរបស់ខ្ញុំពិតប្រាកដ។ “រាយការណ៍មួយច្បាប់ជូនជាព័ត៌មាន អំ! បានៗរាយកាយការណ៍មួយច្បាប់ជូនព័ត៌មាន។ ឌុច ១១ មេសា ១៩៧៧”។

[១៥:៥៧:១០]

**លោក គង់ សំអុន៖**

លោកប្រធាន!

**ប្រធានអង្គជំនុំ៖**

អញ្ជើញ លោកមេធាវី!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ សូមលោកព្រះរាជអាជ្ញាបញ្ជាក់ថា តើលោកចង់ឲ្យសាក្សីអានទំព័រណាពិតប្រាកដ ពីព្រោះអម្បាញ់មិញនេះដូចសាក្សីអានទំព័រទី១ ទំព័រដំបូង ហើយប៉ុន្តែបញ្ចាំងនៅក្នុង *ស្គ្រីន* នេះទៅជាទំព័រទី៣ វិញបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ អាចច្រឡំបន្តិច ប៉ុន្តែលើកដំបូង គឺតំណាងសហព្រះរាជអាជ្ញាមានប្រសាសន៍ អ៊ីចឹងមែនហើយ។ ប៉ុន្តែគាត់បញ្ជាក់ចុងក្រោយ គាត់បាននិយាយច្បាស់ហើយ គឺលើឯកសារទំព័រទី៣ នេះ។ ហើយគាត់បានប្រាប់លេខ ERN ជាក់ច្បាស់ហើយ។ អ៊ីចឹងអាចមានការភ័ន្តច្រឡំបន្តិច។ ត្រឹមត្រូវហើយនេះ គឺគាត់បញ្ជាក់កែសម្រួលនូវអ្វីដែលគាត់បានធ្វើ ឆ្លើយតបទៅនឹងការសំណើសុំបញ្ជាក់ឲ្យច្បាស់របស់សាក្សី។

សូមអញ្ជើញ លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបន្ត!

[១៥:៥៩:១៦]

**សួរដោយលោក វីណ្សៀម ស្មីត៖**

**ស៖** បាទ អរគុណ គឺ 00008923 បាទ គឺអក្សរសរសេរផ្ទាល់ដៃ។ តើលោកយល់ស្របទេ ថាសំបុត្រហ្នឹង គឺសរសេរមកពី ហ៊ូ នឹម តើត្រូវឬទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន អត្ថបទដែលសរសេរតាំងពីទំព័រ៩២៣ រហូតដល់ទំព័រ៩២៤នេះ ជាអក្សររបស់ ហ៊ូ នឹម។

**ស៖** ថាតើពេលដែលគាត់សរសេរហ្នឹង គាត់សរសេរនៅពេលដែលគាត់ជាប់ឃុំនៅស-២១ ឬ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន។ ហ៊ូ នឹម សរសេរនេះ គឺនៅពេលដែលគាត់ចូលមកដល់មន្ទីរស-២១ បានមួយថ្ងៃ។

[១៥:៥៩:៣៧]

**ស៖** ហើយនេះជាសំបុត្រ សូមលោកអានចំណារថា បញ្ជាក់ថាតើគាត់សរសេរសំបុត្រនោះទៅណា នៅក្នុងប្រអប់ក្រហមខាងលើបាទ?

**ឆ៖** អរគុណ។ សូមគោរពលោកប្រធាន ខ្ញុំសូមអានចំណងជើង មិនមែនជាចំណងជើងទេ ទិសដែល ហ៊ូ នឹម សរសេរសំបុត្រទៅ។ "គោរពអង្គការបក្សកុម្មុយនីស្តកម្ពុជាលើសពីជីវិតខ្ញុំ។ គោរពបងប៉ុល, បងនួន, បងវ៉ាន់, បងវន, សមមិត្តខៀវ, សមមិត្តហែម ជាទីគោរព ស្នេហា"។ នេះគឺមានន័យប៉ុណ្ណឹង។ ខ្ញុំសូមចប់ការអាននេះ។

**ស៖** សូមអរគុណ។ ហើយខ្ញុំសួរសំណួរចុងក្រោយសម្រាប់ថ្ងៃនេះ តើលោកអាចអាន-- សូមលោកបញ្ជាក់ថាឈ្មោះមិនបដិវត្តន៍របស់ បងប៉ុល គឺជាអ្នកណា? តើ ប៉ុល ពត ឬ?

**ឆ៖** អរគុណ។ ជម្រាបប្រសាសន៍លោកប្រធាន ប៉ុល នេះគឺ ប៉ុល ពត។

**ស៖** ចុះ បងនួន ជាអ្នកណា?

[១៦:០១:៤៣]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន បងនួន គឺ នួន ជា។

**ស៖** ចុះ បងវ៉ាន់ ជាអ្នកណា?

**ឆ៖** បងវ៉ាន់ គឺ អៀង សារី។

**ស៖** ចុះ បងវន?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន បងវន គឺ វន វ៉េត។

**ស៖** ចុះសមមិត្តខៀវ?

**ឆ៖** សមមិត្តខៀវ គឺ សុន សេន។

**ស៖** ហើយអ្នកណាជា សមមិត្តហែម?

**ឆ៖** សមមិត្តហែម គឺ ខៀវ សំផន។

**លោក វីល្លៀម ស្មីត៖**

សូមជម្រាបលោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំបញ្ចប់សំណួររបស់ខ្ញុំសម្រាប់ថ្ងៃនេះបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណតំណាងសហព្រះរាជអាជ្ញា។ អរគុណសាក្សី។ កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះឃើញថាដល់ពេលសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការនឹងលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី០២ ខែមេសា ឆ្នាំ២០១២ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

[១៦:០៣:១៥]

ដោយនៅសប្តាហ៍ក្រោយនេះ ទំនងជាពេញមួយសប្តាហ៍គឺកិច្ចដំណើរការក្នុងការស្តាប់សក្ខីកម្មសាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច នឹងបន្ត។ ដូច្នេះ អង្គជំនុំជម្រះអញ្ជើញសាក្សី កាំង ហ្គេកអ៊ាវ អញ្ជើញ

មកផ្តល់សក្ខីកម្មជាបន្តសម្រាប់សប្តាហ៍ក្រោយ។

អនុរក្សមន្ទីរឃុំឃាំងនាំសាក្សីទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយឲ្យនាំគាត់មកកាន់បន្ទប់សវនាការនេះនៅព្រឹកថ្ងៃចន្ទ ទី០២ ខែមេសា ឆ្នាំ២០១២ ឲ្យបានត្រឹមម៉ោងប្រាំបួនព្រឹក។ ដូចគ្នាអនុរក្សមន្ទីរឃុំឃាំងបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនិងឲ្យនាំពួកគាត់មកកាន់បន្ទប់សវនាការនេះនៅព្រឹកថ្ងៃចន្ទ ទី០២ ខែមេសា ឆ្នាំ២០១២ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៤ នាទី)*